# សង្កេតការណ៍ ១១

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែឧសភា ឆ្នាំ២០១២



# រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទី របស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## មាតិកា

ការធ្វើសេចក្តីថ្លែងការណ៍របស់ នួន ជា ២
ការសួរដេញដោលសាក្សី កាំង ហ្កេកអាវ ហៅ ឌុច ៦
នួន ជា ធ្វើសេចក្តីថ្លែងការណ៍ឆ្លើយតប ចំពោះការផ្តល់សក្ខីកម្មរបស់ ឌុច ៥០

ក្រុមសង្កេតការណ៍ :
ឆាយ ឈុនលី, ឌី សុជាតា,
លឹម ជ័យរ័ត្ន និង ចាន ប្រាថ្នា

ហ៊ូ នឹម (រូបកណ្តាល) និង ចៅ សេង (រូបឆ្វេង)
រូបថតនេះ ហ៊ូ នឹម បានផ្ញើជូន ចៅ សេង នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៤



ឌុច ក្នុងបន្ទប់សវនាការ ឡើងធ្វើជាសាក្សីក្នុងសំណុំរឿង០០២
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)

# សវនាការលើសំណុំរឿង០០២ ៖ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ថ្ងៃទី១៩ ខែមីនា ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

*ឆាយ ឈុនលី, ឌី សុដាតា, ចាន ប្រាថ្នា និង លីម ជ័យទត្ត*

## សេចក្តីផ្តើម

ថ្ងៃទី១៩ ខែមីនា ដល់ថ្ងៃទី១៨ ខែមេសាឆ្នាំ២០១២ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការដើម្បីស្តាប់ការសួរដេញដោលលើអង្គហេតុដែលត្រូវយកមកជំនុំជម្រះនៅក្នុងវគ្គទីពីរ ។ អង្គហេតុដែលត្រូវយកមកពិភាក្សានៅក្នុងសវនាការវគ្គទីពីរ រួមមានរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗគឺ នួន ជា អៀង សារី និង ខៀវ សំផន ។ តាមការគ្រោងទុក អង្គជំនុំជម្រះមានបំណងស្តាប់ចម្លើយរបស់ជនជាប់ចោទ នួន ជា ប៉ុន្តែដោយសារជនជាប់ចោទ នួន ជា បង្ហាញជំហរមិនឆ្លើយតបនឹងសំណួររបស់ភាគីទាក់ទងនឹងអង្គហេតុដែលត្រូវយកមកជំនុំជម្រះនៅក្នុងវគ្គទីពីរនេះ ហើយស្នើសុំអង្គជំនុំជម្រះធ្វើសេចក្តីថ្លែងការណ៍ ។ អង្គជំនុំជម្រះបានសម្រេចតាមសំណើរបស់ជនជាប់ចោទ នួន ជា ដោយអនុញ្ញាតឲ្យ នួន ជា អាចឡើងធ្វើសេចក្តីថ្លែងការណ៍ ។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានកោះហៅ កាំង ហ្គេកអ៊ាវ ហៅ ឌុច មកធ្វើជាសាក្សីនៅក្នុងសំណុំរឿង០០២ ដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ ។ គួរកត់សម្គាល់ថា ថ្វីត្បិតតែនៅក្នុងករណីសំណុំរឿង០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានអង្គជំនុំជម្រះសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ប៉ុន្តែអង្គជំនុំជម្រះចាត់ទុកថា ឌុចគឺជាសាក្សីដ៏សំខាន់មួយរូបសម្រាប់សំណុំរឿង០០២ដោយសារឌុចមានការយល់ដឹងច្រើនពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ហេតុដូច្នេះហើយ ទើបនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកោះហៅទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច ឲ្យមកធ្វើជាសាក្សីសម្រាប់សំណុំរឿង០០២ ។ ការផ្តល់សក្ខីកម្មរបស់



នួន ជា



អៀង សារី



ខៀវ សំផន

ឌុច ចំពោះការសាកសួរដេញដោលដោយអង្គជំនុំជម្រះ និងភាគី នៅក្នុងសវនាការបានបញ្ចប់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ។ អង្គជំនុំជម្រះបានបញ្ជាក់ថាអាចនឹងមានការកោះហៅ ឌុច ចូលមកធ្វើជាសាក្សីសាជាថ្មីទៀត ទាក់ទងនឹងអង្គហេតុនៅវគ្គបន្ទាប់នៃសវនាការប្រសិនបើចាំបាច់ ។

បន្ទាប់ពី ឌុច បានបញ្ចប់ការផ្តល់សក្ខីកម្មជនជនជាប់ នួន ជា បានស្នើសុំអង្គជំនុំជម្រះដើម្បីធ្វើសេចក្តីថ្លែងការណ៍តបចំពោះការផ្តល់សក្ខីកម្មរបស់ ឌុច នៅអំឡុងពេលសវនាការ ។ អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យ នួន ជា ធ្វើសេចក្តីថ្លែងការណ៍នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ បន្ទាប់ត្រឡប់ពីការឈប់សម្រាកថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ។

សូមបញ្ជាក់ថា សវនាការស្តាប់សក្ខីកម្មរបស់ ឌុច ចាប់ផ្តើមដោយការសួរសំណួរអំពីអត្តសញ្ញាណរបស់សាក្សីពីសំណាក់ប្រធានអង្គជំនុំជម្រះ បន្ទាប់មកភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យធ្វើការសាកសួរតាមលំដាប់លំដោយ ដោយចាប់ផ្តើមពីសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយគឺក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុម ។

## I. ការធ្វើសេចក្តីថ្លែងការណ៍របស់ នួន ជា

តាមការគ្រោងទុករបស់អង្គជំនុំជម្រះ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា គឺមិនមែនជារបៀបវារៈដែលត្រូវយកមកពិភាក្សាឡើយ ។ របៀបវារៈដែលគ្រោងទុកសម្រាប់សវនាការថ្ងៃទី១៩នោះ គឺអង្គជំនុំជម្រះមានបំណងស្តាប់ការផ្តល់ចម្លើយរបស់ នួន ជា ដែលនឹងត្រូវចោទសួរដោយចៅក្រមនៃអង្គជំនុំជម្រះ និងភាគីផ្សេងៗទៀត ។ ផ្ទុយទៅវិញ កាលវិភាគរបស់អង្គជំនុំជម្រះត្រូវបានផ្លាស់ប្តូរដោយសារតែជនជាប់ចោទ នួន ជា បានផ្លាស់ប្តូរជំហរពីការផ្តល់ចម្លើយជូនអង្គជំនុំជម្រះមកជាការធ្វើសេចក្តីថ្លែងការណ៍វិញ

### ១) ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា

បន្ទាប់ពីប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បង្គាប់ឲ្យនាំជនជាប់ចោទ នួន ជា មកអង្គុយនៅតុឈើរាងវង់ក្រចកសេះដើម្បីធ្វើការសួរដេញដោលលើអង្គហេតុដូចបានគ្រោងទុក លោកមេធាវី ម៉ៃឃើល ផេស្តមេន បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនធ្វើសេចក្តីថ្លែងការណ៍មួយដែលនឹងត្រូវចំណាយពេលប្រហែល១៥នាទី ។ សេចក្តីថ្លែងការណ៍នេះជនជាប់ចោទ នួន ជា អះអាងថាមានខ្លឹមសារស្របនឹងអង្គហេតុដែលអង្គជំនុំជម្រះមានបំណងយកមកពិភាក្សាដូចដែលបានគ្រោងទុក ។

បន្ទាប់ពីបានស្តាប់ការអះអាងបែបនេះ អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ។ ខាងក្រោមនេះ គឺជាសេចក្តីថ្លែងការណ៍ទាំងស្រុងរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងបន្ទាប់ពីទទួលបានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះ ៖

"សូមគោរព ពុកម៉ែ បងប្អូនរួមជាតិទាំងអស់ក្នុងទីនេះទូទាំងប្រទេស និងក្រៅប្រទេស! សូមគោរពលោកប្រធានជាទីគោរព! យើងទាំងអស់គ្នានៅទីនេះប្រកាសថា ស្វែងរកយុត្តិធម៌ និងការពិតជូនប្រជាជនកម្ពុជាទាំងមូល ក៏ប៉ុន្តែការពិតនៅទីនេះមិនបានបម្រើដល់រូបភាពប្រវត្តិសាស្ត្រមួយពេញលេញ និងត្រឹមត្រូវសម្រាប់ឲ្យប្រជាជនកម្ពុជាយល់ដឹងពីអ្វីដែលនៅពីក្រោយហេតុការណ៍ដែលបានកើតឡើងនោះទេ ។ ខ្ញុំនៅតែប្រៀបធៀបអ្វីដែលតុលាការកំពុងតែដេញដោលនេះ គឺជាខ្លួនក្រពើ តែមិនយកក្បាល និងកន្ទុយដែលជាបំណែកសំខាន់ក្នុងការបម្រើដល់សកម្មភាពរាល់ថ្ងៃរបស់វាមកពិភាក្សា ឬក្នុងន័យម្យ៉ាងទៀតគឺថាឫសគល់ និងបច្ច័យរបស់វាគឺជាអ្វីដែលបានកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ តែតុលាការនេះមិនយកមកពិចារណា ។

លោក លោកស្រីចៅក្រមជាទីគោរព! តើអង្គជំនុំជម្រះនេះអាចយកមកពិចារណាពីសកម្មភាពរបស់ខ្ញុំ ដោយមិនពិចារណាដល់កាលៈទេសៈនយោបាយ សង្គម និងបរិបទប្រវត្តិសាស្ត្រទូលំទូលាយជាងនេះ នៅពេលដែលកម្ពុជាប្រជាធិបតេយ្យចូលកាន់អំណាចដូចម្តេចទៅ? យើងត្រូវតែពិនិត្យនូវរបបដ៏ពុករលួយ ភាពអត់ឃ្លាន ការបំផ្លិចបំផ្លាញ ភាពក្រីក្រ ការស្លាប់បាត់បង់ជីវិត អំពើពុករលួយ ភាពវឹកវរ និងអំពើហិង្សានៅប្រទេសកម្ពុជានៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងត្រូវតែពិនិត្យផងដែរពីការទម្លាក់គ្រាប់បែករបស់អាមេរិកដែលមិនគ្រាន់តែសម្លាប់ប្រជាជនស្លូតត្រង់កម្ពុជារាប់សែននាក់ប៉ុណ្ណោះទេ តែថែមទាំងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា និងស្បៀងផងដែរ ។ យើងត្រូវតែ

ពិនិត្យស្ថានភាពដ៏អាក្រក់របស់ប្រទេសកម្ពុជាទាំងមូលនៅមុនខែមេសា ឆ្នាំ១៩៧៥ ដែលទទួលរងនូវការបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ និងដោយគ្មានដំណើរការសុខាភិបាល ។ ទាំងនេះសុទ្ធតែជាអង្គហេតុទាក់ទងដ៏ត្រឹមត្រូវជាក់លាក់មួយសម្រាប់តុលាការនេះត្រូវតែពិចារណាឲ្យបានពេញលេញ និងម៉ត់ចត់បំផុត ។ ជាងនេះទៅទៀត នៅពេលវាយតម្លៃពីអំពើរបស់ខ្ញុំ គេត្រូវពិនិត្យបញ្ហាបន្ថែមថាតើប្រទេសរបស់ខ្ញុំត្រូវបានបំផ្លាញដោយយន្តហោះទម្លាក់គ្រាប់បែកបេ៥២ដែរឬអត់? នៅពេលវាយតម្លៃនូវអំពើរបស់បុគ្គលណាម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យថាតើគាត់គ្រប់គ្រងទីក្រុងដែលស្រស់ឆើតឆាយឬអត់? ឬក៏ជាទីក្រុងដែលធ្លាក់ចូលក្នុងការអត់ឃ្លានទៅហើយនោះ? នៅពេលវាយតម្លៃអំពើរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យមើលបញ្ហាថាតើប្រទេសជិតខាងមួយ ដែលក្នុងករណីនេះគឺប្រទេសវៀតណាមពិតជាបានព្យាយាមបន្តនយោបាយឈ្លានពានវាតទី លេបទឹកដី និងបំបាត់ពូជសាសន៍មកលើប្រទេសកម្ពុជាដែរឬអត់? និយាយដោយសង្ខេបទៅ យើងមិនអាចយល់ពីអំពើនិងការខកខានរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានទេ ប្រសិនបើយើងមិនបានពិនិត្យមើលបរិបទខាងប្រវត្តិសាស្ត្រ សង្គមសាស្ត្រដែលត្រូវបានអនុវត្តនោះឡើយ ។

លោក លោកស្រីចៅក្រម! អង្គជំនុំជម្រះសាលាដំបូងអាចកែតម្រូវនូវចំណុចខ្វះខាតទាំងនេះ ដោយអនុញ្ញាតឲ្យមានការស្តាប់ចម្លើយសាក្សីមួយចំនួនដែលក្រុមយើងខ្ញុំបានស្នើសុំ ។ ខ្ញុំចង់ស្តាប់ចម្លើយសាក្សីដែលស្ថិតនៅទីក្រុងភ្នំពេញ នៅមុនការចាប់កំណើតរបបកម្ពុជាប្រជាធិបតេយ្យដើម្បីឲ្យគាត់ពន្យល់សវនាការ និងសាធារណៈជនថាតើស្ថានភាពនៅក្នុងទីក្រុងភ្នំពេញនៅពេលនោះវាពិតជាអាក្រក់យ៉ាងដូចម្តេច? ខ្ញុំចង់ស្តាប់ការផ្តល់សក្ខីកម្មរបស់មន្ត្រីយោធាអាមេរិកនៅពេលនោះដើម្បីបានឮការវាយតម្លៃរបស់ពួកគេលើការខូចខាតដែលបណ្តាលមកពីការវាយប្រហារដោយគ្រាប់បេ៥២របស់គាត់ ។ មិនតែប៉ុណ្ណោះ ខ្ញុំចង់ស្តាប់ចម្លើយសាក្សីដទៃទៀតដែលអាចផ្តល់បរិបទពាក់ព័ន្ធទៅនឹងសកម្មភាពនានាដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងមូល ជាពិសេសយុវជនជំនាន់ក្រោយ ដើម្បីឲ្យយល់ដឹងថាអ្វីជាអំពើ និងអ្វីមិនមែនជាអំពើរបស់កម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសូមស្នើថា ប្រធានបទប្រវត្តិសាស្ត្រដូចខាងក្រោមនេះ ត្រូវតែលើកយកមកពិភាក្សាដេញដោលក្នុងសវនាការមួយជាសាធារណៈ៖

១) ការទម្លាក់គ្រាប់បែករបស់សហអាមេរិកយ៉ាងដំណំមកលើប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៦៥ - ១៩៧៣ និងទាំងការរាប់ចំនួនប្រជាជនស៊ីវិលដែលបានស្លាប់ដោយសារការទម្លាក់គ្រាប់បែកនេះ និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធមានដូចជាផ្លូវថ្នល់ ប្រព័ន្ធទូរគមនាគមន៍ និងលទ្ធភាពផលិតខាងកសិកម្មជាដើម ។

២) គ្រោះទុរភិក្ស និងការអត់ឃ្លាន ដែលបានកើតឡើងទ្រង់ទ្រាយធំនៅក្នុងប្រទេសកម្ពុជា រួមទាំងទីក្រុងភ្នំពេញផង នៅមុនខែមេសា ឆ្នាំ១៩៧៥ ព្រមទាំងការគិតគូរផងដែរអំពីចំនួនជនភៀសខ្លួនអំពីលក្ខខណ្ឌរស់នៅ និងមូលហេតុដែលនាំឲ្យមានការរត់ចោលផ្ទះ ។

៣) បរិមាណអាហារដែលមាននិយាយឲ្យចំ គឺអង្ករនៅទីក្រុងភ្នំពេញនៅភ្លាមៗមុនខែមេសា ឆ្នាំ១៩៧៥ និងលទ្ធភាពខាងកសិកម្មសម្រាប់រយៈពេលខ្លី និងវែងនៅក្នុងអំឡុងពេលនោះ ។

៤) អំពីវិស័យសុខាភិបាលនៅខែមេសា ឆ្នាំ១៩៧៥ និងជំនួយមនុស្សធម៌អន្តរជាតិដែលអាចមាននៅក្នុងអំឡុងឆ្នាំ១៩៧០ ដល់១៩៧៥ ដោយរាប់បញ្ចូលទាំងជំនួយដែលផ្តល់ឲ្យដោយសហរដ្ឋអាមេរិកផង និង

៥) ពីតួនាទីពាក់ព័ន្ធរបស់វៀតណាមមកលើប្រទេសកម្ពុជាជាពិសេសកម្ពុជាប្រជាធិបតេយ្យ ។

លោក លោកស្រីចៅក្រមជាទីគោរព! បញ្ហាទាំងនេះមិនមែនជាប្រធានបទដែលខ្ញុំទើបតែលើកមកនិយាយក្នុងពេលនេះទេ មេធាវីរបស់ខ្ញុំក៏បានស្នើដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតឲ្យស៊ើបអង្កេតទៅលើប្រធានបទដ៏សំខាន់ទាំងនេះសម្រាប់ការពិត និងមានប្រយោជន៍នេះដែរ តែភាពលម្អៀងនិងការព្រងើយកន្តើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានបំពេញនូវសំណើដ៏មានប្រយោជន៍ទាំងនេះទេ ។ នេះគឺជាការខាតបង់មួយយ៉ាងធំធេងនិងធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះតុលាការនេះយ៉ាងខ្លាំងដែរ ។ ភាពលម្អៀងរបស់តុលាការមួយនេះដែលធ្វើការ

ស៊ើបអង្កេតសម្រាប់តែការដាក់បន្ទុកដើម្បីផ្គាប់ចិត្តការិយាល័យសហព្រះរាជអាជ្ញា គឺជាការអាម៉ាស់មួយដែលយើងទាំងអស់គ្នាដឹងព្រួ និងមិនអាចទទួលយកបាន ។ រឹតតែច្បាស់ទៅទៀតនោះនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ចៅក្រមស៊ើបអង្កេតមិនមានសរសេរមួយឃ្លាណាសោះទាក់ទងនឹងប្រធានបទខាងលើនេះ ហើយដូចតែគ្នាទេនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាក៏ខកខានមិនបានលើកឡើងពីប្រធានបទនេះដែរ ។ ដូចដែលខ្ញុំបាននិយាយហើយ ដោយមានបញ្ហាពីសហចៅក្រមស៊ើបអង្កេត មេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យស៊ើបអង្កេតដោយឯករាជ្យនោះទេ ។ អាស្រ័យហេតុនេះហើយ យើងខ្ញុំមានតែពឹងផ្អែកតែទៅលើសហចៅក្រមស៊ើបអង្កេតនេះតែប៉ុណ្ណោះ ។ យើងខ្ញុំបានធ្វើសំណើសុំឲ្យមានការស៊ើបអង្កេតលើបញ្ហាបរិបទទាំងនេះឲ្យបានទូលំទូលាយជាច្រើនដងប៉ុន្តែសំណើរបស់ខ្ញុំមិនដែលត្រូវបានយកមកពិចារណាទាល់តែសោះ ។ ការប្រព្រឹត្តរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមកលើសំណើរបស់យើងខ្ញុំបានបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតគ្មានបានជួយអ្វីសោះដល់ខ្ញុំ ធ្វើឲ្យខ្ញុំរហូតមកដល់ពេលនេះមានតែបាតដៃទទេឡើងមកតទល់ក្នុងសវនាការនេះ ។ ខ្ញុំសង្ឃឹមថាអង្គជំនុំជម្រះសាលាដំបូងនេះមិនដូចការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ហើយរំពឹងថាលោក លោកស្រីចៅក្រមនឹងប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការស្វែងរកការពិតមានប្រយោជន៍ និងយុត្តិធម៌ ។ អាស្រ័យដោយហេតុផលខាងលើនេះ ខ្ញុំសូមស្នើដល់អង្គជំនុំជម្រះ ៖

១) សុំបន្តផ្នែកបរិបទប្រវត្តិសាស្ត្រនៅមុនឆ្នាំ១៩៧៥ ដូចដែលបានរៀបរាប់ខាងលើឲ្យបានម៉ត់ចត់ទូលំទូលាយដើម្បីឲ្យជាតិខ្មែរ និងបរទេសយល់ឲ្យបានច្បាស់លាស់ ហើយបើសិនជាអង្គជំនុំជម្រះនៅតែបន្តទៅផ្នែកមួយទៀតនោះ ខ្ញុំនឹងពិចារណាប្រើសិទ្ធិនៅស្ងៀមរបស់ខ្ញុំ ។

២) សូមឲ្យមានការស្តាប់សាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយមេធាវីរបស់ខ្ញុំបន្ថែមទៀតដើម្បីជួយដល់តុលាការនេះសម្រេចបាននូវយុត្តិធម៌មួយពិតប្រាកដដែលអាចទទួលយកដោយគ្រប់ភាគី និង

៣) តាមច្បាប់កម្ពុជា ខ្ញុំសុំស្នើដល់អង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំមានសិទ្ធិដាក់ឯកសារភស្តុតាងថ្មីរហូតដល់ចប់ដំណើរការជំនុំជម្រះក្តី ។ នេះជាអ្វីដែលខ្ញុំស្នើឡើងនៅក្នុងថ្ងៃនេះ ។

បញ្ហាមួយទៀត ខ្ញុំសុំអនុញ្ញាតលោកប្រធានមេត្តាផ្តល់នូវចម្លើយខ្លះៗនូវអ្វីដែលខ្ញុំបានស្នើដោយផ្ទាល់មាត់នៅទីនេះកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ។ តើសំណើរបស់ខ្ញុំនេះដែលត្រូវបានលើកយកមកពិភាក្សាដោយអង្គជំនុំជម្រះដែរឬទេ? ព្រោះវាមានរយៈពេលជិតមួយខែមកហើយតាំងពីសំណើនេះត្រូវបានលើកឡើង តែរហូតមកដល់ពេលនេះ ខ្ញុំមិនទាន់បានចម្លើយណាមួយពីអង្គជំនុំជម្រះសោះ ។ សូមលោកប្រធានមេត្តាផ្តល់ចម្លើយដោយអនុគ្រោះ សូមអរគុណ!»

បន្ទាប់ពីប្រកាសសម្រាក៤៥នាទីក្រោយពី នួន ជា ធ្វើសេចក្តីថ្លែងការណ៍ អង្គជំនុំជម្រះបានឆ្លើយតបទៅ នួន ជា ថាសំណើទាំងបួនចំណុចដែល នួន ជា បានស្នើសុំ គឺជាសំណើចាស់ដែលមេធាវីនិងជនជាប់ចោទធ្លាប់លើកឡើងកាលពីមុន ហើយសំណើខ្លះត្រូវបានអង្គជំនុំជម្រះដោះស្រាយរួចហើយ គឺសល់តែសំណើមួយទៀតប៉ុណ្ណោះដែលអង្គជំនុំជម្រះកំពុងតែពិចារណា ។

បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះបានសួរអំពីគោលជំហររបស់ជនជាប់ចោទ នួន ជា ថា តើខ្លួនមានបំណងឆ្លើយតបនឹងសំណួរដែលចៅក្រម និងភាគីផ្សេងៗនឹងសាកសួរដែរឬទេ? ជាការឆ្លើយតប ជនជាប់ចោទ នួន ជា បានបញ្ជាក់ថាខ្លួននឹងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយខ្លួននឹងពិចារណាឆ្លើយនឹងសំណួរប្រសិនបើខ្លួនយល់ថាសមស្រប ។ នួន ជា បានបន្ថែមថា “ខ្ញុំគិតថាខ្ញុំគួរតែត្រូវបានផ្តល់ឱកាសពន្យល់ទៅប្រជាជនកម្ពុជាថា ការជម្លៀសប្រជាជនចេញពីភ្នំពេញ គឺពិតជាត្រឹមត្រូវ និងជាការចាំបាច់តាមច្បាប់អន្តរជាតិ» ។ ដោយសារជនជាប់ចោទ នួន ជា បង្ហាញគោលជំហរមិនឆ្លើយតបនឹងសំណួរ លោកប្រធានអង្គជំនុំជម្រះបានសម្រេចប្តូរមកស្តាប់សក្ខីកម្មរបស់ ឌុច នៅពេលរសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ វិញ ។

## ២) បញ្ហាជុំវិញការធ្វើសេចក្តីថ្លែងការណ៍របស់ នួន ជា

ដូចបានបញ្ជាក់ជូនរួចមកហើយថា ប្រធានអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ធ្វើសេចក្តីថ្លែងការណ៍ដោយសារ នួន ជា ខ្លួនឯងបញ្ជាក់ថាសេចក្តីថ្លែងការណ៍របស់ខ្លួនគឺជាប់ពាក់ព័ន្ធនឹងអង្គ

ហេតុដែលអង្គជំនុំជម្រះគ្រោងនឹងយកមកពិភាក្សា ។ ប៉ុន្តែនៅពេលដែល នួន ជា ថ្លែងបានប្រមាណជាង១០ នាទីប៉ុណ្ណោះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិគឺ លោក ខេល លីសាក់ បានជំទាស់


ខេល លីសាក់

ដោយលោកបានអះអាងថា សេចក្តីថ្លែងការណ៍ដែល នួន ជា កំពុងតែធ្វើ គឺមិនស្របនឹងកម្មវត្ថុដែលអង្គជំនុំជម្រះគ្រោងនឹងធ្វើឡើយ ។ ពោលគឺមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាល តួនាទីរបស់ជនជាប់ចោទម្នាក់ៗ និងប្រព័ន្ធទំនាក់ទំនងការងារដែលនឹងត្រូវយកមកជំនុំជម្រះក្នុងវគ្គទី២ ។ ម្យ៉ាងវិញទៀត អង្គហេតុដែលទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាត្រូវបានលើកយកមកពិភាក្សាជាច្រើនរួចហើយនៅពេលសវនាការវគ្គទី១ ។ អង្គជំនុំជម្រះយល់ស្របជាមួយការលើកឡើងរបស់ លោក ខេល លីសាក់ និងបានសម្រេចហាមឃាត់មិនឲ្យជនជាប់ចោទ នួន ជា ធ្វើសេចក្តីថ្លែងការណ៍បន្តឡើយ ។ ភ្លាមៗនោះលោក ម៉ៃឃើល ជេស្តមេន ស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនធ្វើសេចក្តីថ្លែងការណ៍ឲ្យបានចប់ ដោយលោកបានអះអាងថា សេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនពិតជាមានការពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវជុំនុំជម្រះក្នុងវគ្គទី២ ។ សំណើនេះត្រូវបានអង្គជំនុំជម្រះបដិសេធ ។ បន្ទាប់មកលោក ជេស្តមេន បានស្នើសុំពេលវេលាចំនួន៥នាទីដើម្បីធ្វើការពិភាក្សាជាមួយកូនក្តីរបស់ខ្លួនអំពីផលវិបាកដែលកើតចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលហាមឃាត់មិនឲ្យ នួន ជា ធ្វើសេចក្តីថ្លែងការណ៍បន្ត ។ សំណើនេះក៏ត្រូវបានអង្គជំនុំជម្រះបដិសេធដែរ ដោយលោកប្រធានចៅក្រមបានលើកហេតុផលថារហូតមកដល់ពេលនេះមេធាវីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិភាក្សាជាមួយកូនក្តីរបស់ខ្លួន ។ បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះបានប្រគល់ភារកិច្ចជូនលោកស្រីចៅក្រម ស៊ីលវៀរ ខាត់


ស៊ីលវៀរ ខាត់ហ្វ្រាយត៍

ហ្វ្រាយត៍ ដើម្បីសួរជនជាប់ចោទ នួន ជា អំពីអង្គហេតុទាំងឡាយដូចបានគ្រោងទុកដោយអង្គជំនុំជម្រះ ។ លោកស្រីចៅក្រមបានចាប់ផ្តើមសួរដោយស្នើឲ្យជនជាប់ចោទ នួន ជា ធ្វើការបញ្ជាក់ឲ្យបានលម្អិតអំពីលក្ខន្តិកៈបក្សរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានអនុម័តក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយត្រូវបានយកមកប្រើក្រោយឆ្នាំ១៩៧៥ ។ ឆ្លើយតបទៅនឹងសំណូមពរនេះជនជាប់ចោទ នួន ជា បានលើកឡើងថា ខ្លួននឹងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ប្រសិនបើតុលាការមិនអនុញ្ញាតឲ្យលោកមេធាវី ជេស្តមេន មានពេល៥នាទីដើម្បីធ្វើការពិភាក្សាជាមួយខ្លួន ។ បន្ទាប់ពីជនជាប់ចោទ នួន ជា ប្រកាន់ជំហរបែបនេះអង្គជំនុំជម្រះបានធ្វើការពិភាក្សាគ្នា ហើយបានសម្រេចកែប្រែសេចក្តីសម្រេចដែលខ្លួនបានបដិសេធ ដោយសម្រេចផ្តល់រយៈពេល៥នាទីជូនលោក ជេស្តមេន ដើម្បីធ្វើការពិភាក្សាជាមួយ នួន ជា ។ បន្ទាប់ពីធ្វើការពិភាក្សាជាមួយកូនក្តីរបស់ខ្លួនប្រមាណជា៥ នាទី លោក ជេស្តមេន បានលើកឡើងថា "...ខ្ញុំបានពិភាក្សាជាមួយកូនក្តីរបស់ខ្ញុំ គាត់បានបញ្ជាក់ថា បើគាត់មិនបានធ្វើការប្រកាសបញ្ចប់នូវសេចក្តីថ្លែងការណ៍របស់គាត់ទេ គាត់នឹងមិនធ្វើការឆ្លើយតបនឹងសំណួរ

ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល ឬក៏អង្គហេតុដែលពាក់ព័ន្ធចាប់ពីឆ្នាំ ១៩៧៥ដល់ឆ្នាំ១៩៧៩ឡើយ” ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានសម្រេចលុបសេចក្តីសម្រេចរបស់ខ្លួនមួយទៀត ហើយបានសម្រេចឲ្យជនជាប់ចោទ នួន ជា ធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួនរហូតដល់ចប់ ។

បន្ទាប់ពីមានបញ្ហាជាច្រើនដូចបានរៀបរាប់ខាងលើ គឺមានការធ្វើកំណត់សម្គាល់ជាបន្តបន្ទាប់លើទង្វើរបស់ នួន ជា និងមេធាវីរបស់ខ្លួន ។

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺលោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត បានលើកឡើងថា លោកស្រីសូមបដិសេធចំពោះសំណើរបស់ នួន ជា ព្រោះអង្គហេតុដែលទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ ត្រូវបានលើកយកមកពិភាក្សារួចហើយ ហើយជនជាប់ចោទនិងមេធាវីការពារក្តីមានសិទ្ធិគ្រប់គ្រាន់ក្នុងការលើកឡើងពីបញ្ហានេះ ។ លោកស្រីមេធាវីបានបន្ថែមថា ការណ៍ដែលជនជាប់ចោទលើកឡើងពីសិទ្ធិមិនឆ្លើយតបនោះ គឺជាការគំរាមកំហែងដល់សវនាការ ពីព្រោះភាគីទាំងអស់មានបំណងចង់ឲ្យជនជាប់ចោទឆ្លើយ ។ ទោះបីជនជាប់ចោទមានសិទ្ធិនៅស្ងៀម ប៉ុន្តែក៏ត្រូវធ្វើការប្រៀបធៀបនឹងសិទ្ធិរបស់ភាគីផ្សេងៗទៀតដែរ ហើយជនជាប់ចោទមិនមានសិទ្ធិក្នុងដាក់លក្ខខណ្ឌចំពោះកិច្ចដំណើរការនីតិវិធីសវនាការឡើយ ព្រោះវាជាសិទ្ធិរបស់អង្គជំនុំជម្រះ ។

ចំណែកលោកប្រធានអង្គជំនុំជម្រះ និល ណុន បានកត់សម្គាល់ថា អាកប្បកិរិយារបស់មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា ដែលបានបញ្ចេញនៅអំឡុងពេលកិច្ចដំណើរការពិភាក្សា គឺជាអាកប្បកិរិយាមួយមិនសមរម្យ ។ បន្ថែមលើនេះ ក្នុងនាមអង្គជំនុំជម្រះទាំងមូល លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានធ្វើការកត់សម្គាល់ថា “...មេធាវីការក្តីបានជំរុញឲ្យកូនក្តីរបស់ខ្លួនធ្វើឲ្យអង្គជំនុំជម្រះមានការភាន់ច្រឡំ....អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មេធាវីរបស់នួនជាព្យាយាមនិងបង្ខំឲ្យអង្គជំនុំជម្រះផ្លាស់ប្តូរនូវរបៀបនៃការដឹកនាំនីតិវិធីរបស់ខ្លួន ឬក៏ចង់ក្រឡុកអង្គជំនុំជម្រះតាមរបៀបមិនសមរម្យ ។ អ្វីដែលបានប្រព្រឹត្តនេះ គឺផ្ទុយវិធាននៃករណីកិច្ចសាស្ត្រ ដែលមេធាវីនៅចំពោះមុខតុលាការនេះត្រូវតែអនុវត្ត ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមប្រកាសថាអាកប្បកិរិយារបស់មេធាវីដែលពាក់ព័ន្ធនេះគឺប៉ះពាល់ដល់វិធានករណីកិច្ចសាស្ត្រ ។ ដូចនេះអង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការចាត់វិធានការសមស្របដើម្បីឆ្លើយតបចំពោះការប្រព្រឹត្តបែបនេះ” ។

## II. ការសួរដេញដោលសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច

ការសួរដេញដោលសាក្សីកាំង ហ្គេកអ៊ាវ ហៅ ឌុច នៅថ្ងៃទី១៩ ខែមីនា ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ គឺចាប់ផ្តើមសួរសំណួរដោយប្រធានអង្គជំនុំជម្រះអំពីអត្តសញ្ញាណរបស់សាក្សី ឌុច ។ បន្ទាប់ មកសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុមត្រូវបានផ្តល់ឱកាសឲ្យសួរដេញដោល ឌុច អំពីអង្គហេតុទាំងឡាយដែល ឌុច បានដឹងពីរបបកម្ពុជាប្រជាធិបតេយ្យ ដូចជារចនាសម្ព័ន្ធរដ្ឋបាលប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជា ធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទទាំងបីរូប ។



កាំង ហ្គេកអ៊ាវ ហៅ ឌុច

### ១) ការផ្តល់សក្ខីកម្មរបស់ ឌុច ចំពោះការចោទសួររបស់ប្រធានអង្គជំនុំជម្រះ

មុននឹងប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញា ប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានសួរសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួននៅចំពោះមុខភាគីក្នុងសវនាការ ។ យោងតាមសក្ខីកម្ម ឌុច មានឈ្មោះដើមថា កាំង ហ្គេកអ៊ាវ កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពោវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។ មុនពេលចាប់ខ្លួន ឌុច

*រស់នៅភូមិអូរទន្ទឹម ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ។ ឌុច មានកូនបួននាក់ និងជាអ្នក ប្រតិបត្តិសាសនាគ្រិស្ត ។*

*មុនពេលផ្តល់សក្ខីកម្ម ឌុច ត្រូវបានអង្គជំនុំជម្រះតម្រូវឲ្យធ្វើសម្បថជាសាធារណៈនៅក្នុងសាលសវនាការតាមជំនឿរបស់សាសនាគ្រិស្តដោយយកដៃឆ្វេងដាក់លើព្រះគម្ពីរដៃស្តាំលើកឡើងលើ និងបានស្បថថា "ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនឹងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ" ។*

## ២) ការផ្តល់សក្ខីកម្មរបស់ ឌុច ចំពោះការចោទសួររបស់តំណាងសហព្រះរាជអាជ្ញា

*បន្ទាប់ពីទទួលបានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាជាតិគឺលោក សេង ប៊ុនឃាង បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ក្នុងការសាកសួរសាក្សី "ឌុច" ខ្លួននឹងសួរផ្តោតសំខាន់លើតួនាទីនិងភារកិច្ចរបស់សាក្សីក្នុងបក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយចំបងៗរបស់បក្ស ដែលរួមមានការជម្លៀសប្រជាជនដោយបង្ខំ ការកម្ទេចខ្មាំង និងការអប់រំកែប្រែ ពលកម្មដោយបង្ខំ និងការដាក់បទបញ្ជាក្នុងការរៀបអាពាហ៍ពិពាហ៍ ។ ចំណែកលោកព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត នឹងបន្តការសួរដោយផ្តោតសំខាន់លើរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ តួនាទីរបស់ជនជាប់ចោទទាំងបីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងចុងក្រោយ គឺការបង្ហាញឯកសារមួយចំនួនដល់សាក្សីដើម្បីសួរបញ្ជាក់ ។*

## ២.១) ការចោទសួរដោយតំណាងសហព្រះរាជអាជ្ញាជាតិចំពោះ ឌុច

*ដូចបានជម្រាបជូនអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានចំណាយពេលរបស់លោកស្ទើរតែទាំងស្រុងក្នុងការសួរអំពីតួនាទី និងភារកិច្ចរបស់សាក្សី ឌុច នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយរបស់បក្សដែលត្រូវបានអនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

### ២.១.១)តួនាទី និងភារកិច្ចរបស់ឌុចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា

*ការសិក្សាអប់រំ ការចូលរួមចលនាបដិវត្តន៍ ការទទួលការបណ្តុះបណ្តាលមនោគមន៍វិជ្ជា ការអនុវត្តភារកិច្ចក្នុងតួនាទីដែលបក្សបានប្រគល់ឲ្យ គឺជាបញ្ហាបឋមដែលលោក សេង ប៊ុនឃាង បានសួរ ឌុច យ៉ាងច្រើន ហើយដែល ឌុច បានផ្តល់សក្ខីកម្មដូចខាងក្រោម ។*

#### ក) ការសិក្សារៀនសូត្រ និងការចូលរួមចលនាបដិវត្ត

*បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បាក់ឌុប ឌុច បានចូលធ្វើជាគ្រូបង្រៀនគណិតវិទ្យានៅអាយុ២៣ឆ្នាំ ហើយមានទំនោរទៅពួកកុម្មុយនីស្តតាំងពីឆ្នាំ១៩៥៥មកម៉្លេះ គឺដោយសារពេលនោះមានបងប្អូននៅប្រទេសចិនប្រាប់ខ្លួនថា ម៉ៅ សេទុង បានដោះស្រាយជីវភាពរបស់ប្រជាជនដោយសារការធ្វើបដិវត្ត ។ ក្នុងអំឡុងខែតុលាឆ្នាំ១៩៦៤ឌុចបានសម្រេចចូលរួមចលនាបដិវត្ត ដោយសារពេលនោះមានការចាប់ខ្លួនអ្នកចែកផ្សាយខិតប័ណ្ណមួយចំនួន និងតាមរយៈការអានសៀវភៅចំរើន និងសៀវភៅមួយចំនួនទៀតដែលសរសេរដោយ ម៉ៅ សេទុង ។ នៅខែកក្កដា ឆ្នាំ១៩៦៧ ឌុច បានចូលរៀនវគ្គបណ្តុះបណ្តាលសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាប្រមាណជា២ខែ ដោយតម្រូវឲ្យសិក្សាអំពីលក្ខន្តិកៈរបស់បក្សដូចជាមាគ៌ាជាយុទ្ធសាស្ត្រ និងយុទ្ធវិធីប្រមូលកម្លាំងវណ្ណសិរ្ស ឯកសារទស្សនៈវណ្ណៈ និងការតស៊ូវណ្ណៈ និងឯកសារសតិអារម្មណ៍អង្គការវិន័យជាដើម ។ បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ ឌុច ត្រូវបានបញ្ចូលជាសមាជិករបស់បក្ស ហើយក្រោយមកត្រូវបានបក្សបញ្ជូនឲ្យទៅកសាងកម្លាំងនៅតាមជនបទ ។ បញ្ញាជនជាច្រើនទៀតក៏ត្រូវបានបក្សបញ្ជូនឲ្យទៅតាមមូលដ្ឋានដើម្បីរៀបចំនិងកសាងកម្លាំងកងឈ្លបដែរ ។ បន្ទាប់ពីរៀបចំកងឈ្លបបានមួយចំនួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៨ បក្សបានសម្រេចបើកការវាយប្រហារលើកងកម្លាំងរបស់ លន់ នល់ នៅប៉ុស្តិ៍ភូមិបាយដំរាំ ដើម្បីបើកការធ្វើសង្គ្រាមប្រជាជនជាផ្លូវការ ។*

#### ខ) តួនាទីរបស់ ឌុច នៅមន្ទីរម-១៣

*នៅថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៧១ ឌុច ត្រូវបាន វន វេត ចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរម-១៣ ដែលស្ថិតនៅក្នុងភូមិភាគនិរតី ។ ឌុច បានបញ្ជាក់ថា មន្ទីរនេះមានភារកិច្ចសួរចម្លើយ និងសម្លាប់គិញ ឬខ្មាំងដែលកងទ័ពបានចាប់និងបញ្ជូនមកពីសមរភូមិ ។ អ្នកដែលបក្សចាត់ទុកថាជាគិញ ឬខ្មាំង គឺទាហ៊ានរបស់ លន់ នល់*

និងប្រជាជនដែលរត់ចូលក្នុងតំបន់រំដោះ ។ ក្រោយការទម្លាក់គ្រាប់បែកឆ្នាំ ១៩៧៣ ប្រជាជនដែលធ្លាប់រស់នៅតំបន់រំដោះក៏ត្រូវបានចាត់ទុកថាជាខ្មាំងដែរ ។ សរុបមកគោលនយោបាយរបស់បក្សគឺអ្នកដែលរត់ចូលក្នុងតំបន់រំដោះត្រូវចាត់ទុកជាគិញឬខ្មាំងដែលត្រូវតែសួរចម្លើយ និងសម្លាប់ ។ រាល់ការសួរចម្លើយអ្នកទោសតែងតែប្រើទារុណកម្មក្រោមរូបភាពផ្សេងៗដូចជាវាយឆក់ខ្សែភ្លើង ប្រកក្បាលក្នុងថង់ប្លាស្ទិក និងបន្តក់ទឹកចូលក្នុងប្រមុះ ។ ឌុច បានបន្ថែមថានៅសម័យនោះគេប្រើពាក្យ "ដោះស្រាយ" ដែលមានន័យថា "កម្ទេច ឬសម្លាប់" ។

មន្ទីរម-១៣ ត្រូវបានគ្រប់គ្រងដោយមន្ទីរ៣០៥ ដែលមាន វន វេត ក្រោយមកគឺ សុន សេន ទទួលខុសត្រូវផ្នែកនគរបាល ដែលអ្នកទាំងពីរនេះមានតួនាទីជាសមាជិករបស់គណៈមជ្ឈិមនៅពេលនោះ ។ ក្នុងឋានៈជាប្រធានមន្ទីរម-១៣ ឌុច បានចូលរួមប្រជុំជាញឹកញាប់ជាមួយ វន វេត និង សុន សេន ។ ឌុច បានបញ្ជាក់ថា ជារៀងរាល់ឆ្នាំលេខារបស់គណៈភូមិភាគទាំងអស់បានកោះហៅកម្មាភិបាលនៅក្នុងមន្ទីរនិងនៅថ្នាក់ក្រោមទាំងអស់ឲ្យមកសិក្សារៀនសូត្រ បន្ទាប់ពីលេខាភូមិភាគទាំងនោះបានទៅរៀនជាមួយ ប៉ុល ពត ។ ឯកសារដែលយកមកបង្រៀនមានបីប្រភេទ គឺឯកសារនយោបាយ ឯកសារកម្ចាត់សតិអារម្មណ៍ និងឯកសារចាត់តាំង ។ បន្ថែមលើនេះទៀត ជាប្រចាំខែបក្ខជនទាំងអស់ត្រូវតែរៀនសូត្រគោលនយោបាយដែលបានកំណត់នៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ។ កម្មាភិបាលខ្មែរក្រហមណាដែលមានការភ័យព្រួយពីបញ្ហាសន្តិសុខផ្ទាល់ខ្លួនគឺសុទ្ធតែបានខិតខំរៀនសូត្រគោលនយោបាយដែលមានក្នុងទស្សនាវដ្ដីទង់បដិវត្តឲ្យបានចេះចាំស្ទាត់ដើម្បីជៀសវាងការប្រព្រឹត្តខុសមាគ៌ារបស់ បក្ស ។

នៅពេលតំណាងសហព្រះរាជអាជ្ញាបង្ហាញឯកសារទស្សនាវដ្ដីទង់បដិវត្តមួយច្បាប់ដើម្បីពិនិត្យ ឌុច បានលើកឡើងថាខ្លួនស្គាល់យ៉ាងច្បាស់ ហើយថែមទាំងបានរៀនសូត្រយ៉ាងយកចិត្តទុកដាក់អំពីគោលនយោបាយរបស់បក្សដែលបានកំណត់ក្នុងទស្សនាវដ្ដីនេះ ។ ឌុច បានពន្យល់ពាក្យ "ដណ្ដើមប្រជាជនពីខ្មាំង" ដែលបានសរសេរក្នុងទស្សនាវដ្ដីនេះថា "*ពេលវាយបែកតំបន់ណាមួយ គឺត្រូវប្រមូលប្រជាជនពីតំបន់នោះ ។ ពង្រីងប្រជាជនពីខ្មាំង ដើម្បីកុំឲ្យខ្មាំងមានកម្លាំងយោធា និងកម្លាំងសេដ្ឋកិច្ច*" ។

បន្ទាប់ពីសួរអំពីតួនាទី និងភារកិច្ចរបស់ ឌុច ជាច្រើនរួចមក តំណាងសហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះដើម្បីអនុញ្ញាតឲ្យខ្លួនមានសិទ្ធិដាក់ឯកសារមួយចំនួននៅចំពោះមុខសាក្សី ឌុច ដែលឯកសារទាំងនោះត្រូវបានធ្វើឡើងដោយ ឌុច ខ្លួនឯងផ្ទាល់ ។ សំណើសុំនេះធ្វើឡើងក្នុងគោលបំណងឲ្យ ឌុច អាចពិនិត្យមើលឯកសារដែលខ្លួនបានធ្វើដើម្បីជាជំនួយដល់ការចងចាំក្នុងការផ្ដល់សក្ខីកម្ម ។

សំណើនេះត្រូវបានមេធាវីការពារក្ដី នួន ជា គឺលោក ពេស្ដមេន ធ្វើការជំទាស់ដោយលោកបានលើកហេតុផលថា សាក្សីគប្បីឆ្លើយអ្វីដែលខ្លួននៅចងចាំតែប៉ុណ្ណោះ ។ ដូចនេះមិនគប្បីផ្ដល់ឯកសារណាមួយដែលជួយរំលឹកដល់សាក្សីក្នុងការធ្វើសក្ខីកម្មឡើយ ។ ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះគឺ លោកមេធាវី ខណាវ៉ាស់ តំណាងឲ្យជនជាប់ចោទ អៀង សារី បានបង្ហាញជំហរគាំទ្រចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ដោយលោកបានលើកឡើងថា តាមបទពិសោធរបស់លោកដែលធ្លាប់ធ្វើការនៅតុលាការអន្តរជាតិមួយចំនួន គឺជាទូទៅ សាក្សីត្រូវបានតុលាការអនុញ្ញាតឲ្យមានសិទ្ធិអាចពិនិត្យមើលឯកសារដែលខ្លួនបានធ្វើដើម្បីជាជំនួយដល់ការចងចាំ ។ បន្ទាប់ពីបានស្ដាប់ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីទាំងពីរក្រុម ប្រធានអង្គជំនុំជម្រះបានសម្រេចតាមសំណើរបស់សហព្រះរាជអាជ្ញា ពោលគឺអនុញ្ញាតឲ្យសាក្សីអាចពិនិត្យមើលរាល់ឯកសារដែលខ្លួនបានធ្វើកន្លងមកនោះ ។

### ក) តួនាទីរបស់ ឌុច នៅមន្ទីរសន្តិសុខស-២១

បន្ទាប់ពីសាក្សី ឌុច ផ្ដល់សក្ខីកម្មលម្អិតអំពីតួនាទីនិងភារកិច្ចរបស់ខ្លួននៅមន្ទីរម-១៣ តំណាងសហព្រះរាជអាជ្ញាជាតិបានបន្តសួរសំណួរជាច្រើនពាក់ព័ន្ធនឹងតួនាទីរបស់ ឌុច នៅមន្ទីសន្តិសុខស-២១ ។ ឆ្លើយតបនឹងសំណួរទាំងនេះឌុចបានផ្ដល់សក្ខីកម្មថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្លួនមានតួនាទីជាអនុប្រធាន និងក្រោយមកជាប្រធាននៃមន្ទីរស-២១ ។ មន្ទីរនេះស្ថិតក្រោមការគ្រប់គ្រងរបស់គណៈមជ្ឈិម ហើយមានតួនាទីសួរចម្លើយអ្នកទោស និងយកអ្នកទោសទៅសម្លាប់ ។ ក្នុងឋានៈជាប្រធាន មន្ទីរស-២១

ខ្លួនមានតួនាទីទទួលអ្នកទោសពិនិត្យចម្លើយសារភាព និងរាយការណ៍ឲ្យ សុន សេន ដែលជាថ្នាក់លើរបស់ខ្លួន ហើយក្រោយមករាយការណ៍ឲ្យ នួន ជា នៅពេលដែល សុន សេន ត្រូវបានបក្សបញ្ជូនទៅសមរភូមិនៅអ្នកលឿង ។

អ្នកទោសដែលបញ្ជូនមកមន្ទីរស-២១ រួមមានទាហានលន់ នល់ បញ្ញាជនកម្មាភិបាលខ្មែរក្រហម ប្រជាជនមូស្លីមសម័យអាវ៉ាប់ ខ្មែរឥស្សរៈ ប្រជាជនថៃដែលលួចចូលនេសាទខុសច្បាប់ កម្មករ រោងចក្រក្រដាសនៅចក្រអង្រែ ។ល ។ អ្នកទោសទាំងនេះត្រូវបានសួរចម្លើយដោយការធ្វើទារុណកម្ម ហើយបន្ទាប់មកត្រូវបានយកទៅសម្លាប់ ។

## ២.១.២) គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

ក្នុងការសួរដេញដោលអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា លោក សេង ប៊ុនឃាង បានផ្តោតសំខាន់លើការបង្កើតសហករណ៍ ការជម្លៀសប្រជាជន ការរៀបអាពាហ៍ពិពាហ៍ ការបោសសម្អាតខ្មាំង និងឯកសារគោលនយោបាយមួយចំនួនទៀតដែលបក្សកុម្មុយនីស្តកម្ពុជាបានយកមកប្រើប្រាស់ដើម្បីអប់រំកម្មាភិបាលខ្មែរក្រហម ។

### ក) ការបង្កើតសហករណ៍

ពាក់ព័ន្ធនឹងការបង្កើតសហករណ៍ ឌុច បានផ្តល់សក្ខីកម្មថា សហករណ៍ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាបង្កើតឡើងដំបូងបង្អស់ក្នុងឆ្នាំ១៩៧២ នៅខេត្តព្រះវិហារដើម្បីជាការពិសោធន៍ក្នុងការកសាងមូលដ្ឋានបដិវត្ត ។ ដោយការបង្កើតសហករណ៍មានអំណោយផលក្នុងការកសាងមូលដ្ឋានបដិវត្ត នៅឆ្នាំ១៩៧៣ បក្សបានសម្រេចបង្កើតសហករណ៍នៅគ្រប់តំបន់ទាំងអស់ដែលខ្លួនរំដោះបាន ។ បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចប្រកាសបង្កើតសហករណ៍នៅទូទាំងប្រទេសកម្ពុជា ។

ឌុច បានបន្ថែមថា សហករណ៍ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផលិតផលដែលប្រមូលបាននៅតាមមូលដ្ឋាននីមួយៗ និងជាកន្លែងសម្រាប់ចាត់ចែងការផារដល់ប្រជាជន ហើយក៏ជាកន្លែងដាក់ឲ្យប្រជាជនថ្មីស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំដោយប្រជាជនចាស់ដែរ ។ មធ្យោបាយផលិតកម្មទាំងអស់រួមមានស្រែ កម្លាំងមនុស្ស គោ ក្របី និងឧបករណ៍ផ្សេងៗទៀតគឺជាកម្មសិទ្ធិរបស់បក្ស ហើយត្រូវបានប្រមូល និងគ្រប់គ្រងដោយសហករណ៍ ប៉ុន្តែគណៈភូមិភាគជាអ្នកមានសិទ្ធិចាត់ចែងផលិតផលដែលសហករណ៍ប្រមូលបាន ។ ឌុច បានបញ្ជាក់បន្ថែមថា បក្សបានដាក់គោលនយោបាយបង្កបង្កើនផលស្រូវឲ្យបាន៣តោនក្នុងមួយហិចតា ដែលគោលនយោបាយនេះត្រូវបានផ្សព្វផ្សាយតាមវិទ្យុទៀតផង ។

ខណៈពេលដែល ឌុច ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបង្កើតសហករណ៍ ជនជាប់ចោទ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍មួយមានខ្លឹមសារថា *«គេមិនដែលយកឈើពុក ឈើរលួយ ឈើស្អុយមកឆ្លាក់ធ្វើព្រះ ឬមកទេសនាឲ្យពុទ្ធបរិស័ទស្តាប់នោះទេ»* ។ ក្នុងសេចក្តីថ្លែងការណ៍នេះ ជនជាប់ចោទ នួន ជា មិនបានបង្ហាញជំហរជំទាស់នឹងអង្គហេតុណាមួយដែល ឌុច បានធ្វើសក្ខីកម្មឡើយ ។ អ្វីដែល នួន ជា បានថ្លែងនេះ ទំនងជាមានបំណងវាយប្រហារលើកិត្តិយសរបស់ ឌុច ដែលត្រូវបានអង្គជម្រះតុលាការកំពូលផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។ ដាក់ស្តែងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានធ្វើការឆ្លើយតបភ្លាមៗថា *«លោក ឌុច ពេលនេះត្រូវបានទទួលស្គាល់ថាមានលក្ខណៈជាសាក្សី ហើយមិនត្រូវបានបដិសេធលក្ខណៈរបស់គាត់នោះទេ ដូចនេះគាត់មានសិទ្ធិពេញលេញក្នុងការឆ្លើយក្នុងឋានៈជាសាក្សី ។ ដូចនេះមិនត្រូវមានមតិណាដែលជាការវាយប្រហារលើសាក្សីឡើយ»* ។ បន្ថែមលើនេះ ប្រធានអង្គជំនុំជម្រះបានរំឭកដល់ នួន ជា ថា *«...ឌុច មិនមែនមកផ្តល់សក្ខីកម្មនេះដោយចិត្តឯងនោះទេ គឺអង្គជម្រះមិនត្រឹមតែកោះហៅនោះទេ គឺថែមទាំងបង្គាប់ឲ្យនាំខ្លួនមកបង្ហាញខ្លួននៅមុខអង្គជំនុំជម្រះទៀតផង គឺយើងប្រធានអង្គជំនុំជម្រះសាលាដំបូង ជាអ្នកកោះហៅ ជាអ្នកបង្គាប់ឲ្យនាំខ្លួនសាក្សីរូបនេះមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ»* ។

### ខ) ការជម្លៀសប្រជាជន

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន លោក សេង ប៊ុនឃាង បានសួរផ្តោតសំខាន់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញបន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាចូលកាន់កាប់ទីក្រុងភ្នំពេញ ។


ស្ត្រីនិងកូនៗរបស់គាត់ចាកចេញពីទីក្រុងភ្នំពេញជាមួយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គាត់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (រូបថត : រ៉ូឡង់ នើវើ)

ឆ្លើយតបនឹងការចោទសួររបស់តំណាងសហព្រះរាជអាជ្ញា ឌុច បានផ្តល់សក្ខីកម្មថា នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្លួនរស់នៅអមលាំងក្នុងឋានៈជាប្រធានមន្ទីរម-១៣នៅឡើយ ប៉ុន្តែខ្លួនបានដឹងពីការជម្លៀសនេះដោយសារមានប្រជាជនមួយ ចំនួនធំត្រូវបានជម្លៀសទៅអមលាំង និងតាមរយៈមិត្តភ័ក្តិរបស់ខ្លួនមួយចំនួនដែលបានឃើញការជម្លៀសប្រជាជនទៅតំបន់ផ្សេងៗ ។ ប្រជាជនត្រូវបានជម្លៀសចេញពីផ្ទះដោយបង្ខំ ហើយគ្មានសិទ្ធិជ្រើសរើសទីកន្លែងដែលខ្លួនចង់ទៅឡើយ ។ ហេតុផល ដែល ឌុច ហ៊ានអះអាងបែបនេះគឺដោយសារខ្លួនបានជួបមិត្តធ្លាប់រៀនជាមួយគ្នាម្នាក់ក្នុងទឹកមុខក្រៀមក្រំលាយឡំដោយទឹកភ្នែក ដោយសារត្រូវបានគេជម្លៀសបែកពីប្រពន្ធចេញទៅតាមទិសដៅផ្សេងគ្នា ហើយខ្លួនក៏ធ្លាប់បានឮឈ្មោះ ស៊ឹម ម៉ែល ហៅ ម៉ាន ដែលជាអ្នកបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយផ្ទាល់បាននិយាយប្រាប់ខ្លួនថា "ប្រជាជនដែលគេជម្លៀស បើមិនចេញគេបាញ់ ។ ដូចខ្ញុំអញ្ចឹង បើខ្ញុំដេញហើយមិនចេញនោះ ខ្ញុំបាញ់បញ្ចិតជើងឬក្បាល..." ។ ឌុច បានបន្ថែមថា នៅពេលជម្លៀសប្រជាជនការសម្រិតសម្រាំងសមាសភាពមិនល្អត្រូវបានធ្វើឡើង ហើយប្រជាជនដែលនៅសល់ត្រូវបានបញ្ជូនឲ្យទៅរស់នៅតាមសហករណ៍ដើម្បីធ្វើការត្រួតពិនិត្យតាមដាន និងទុកឲ្យធ្វើស្រែ ចម្ការ ។

ឌុច បានអះអាងថា ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បក្សកុម្មុយនីស្តកម្ពុជាមានផែនការណ៍ទុកជាមុនព្រោះខ្លួនធ្លាប់បានឃើញឯកសាររបស់បក្សមួយមានចំណងជើងថា "ឯកសារត្រៀមឈ្នះ" ដែលឯកសារនេះនិយាយពីផែនការជម្លៀសប្រជាជន ។ ជាងនេះទៅទៀត សហករណ៍នៅតាមមូលដ្ឋានបានត្រៀមខ្លួនជាស្រេចដើម្បីទទួលយកប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ។ ម្យ៉ាងវិញទៀត ការណ៍ដែលបក្សកុម្មុយនីស្តកម្ពុជាប្រកាសថា "នឹងមានការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក" ក្នុងកំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺជាការភូតភរតែប៉ុណ្ណោះ ពីព្រោះមិនមានសញ្ញាណណាមួយដែលអាចបញ្ជាក់ថាសហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែកនៅលើប្រទេសកម្ពុជាទៀតឡើយ ។

### គ) ការរៀបអាពាហ៍ពិពាហ៍

សំណួរជាច្រើនដែលតំណាងសហព្រះរាជអាជ្ញាសួរពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺក្នុងគោលបំណងចង់ដឹងថាតើប្រជាជននៅក្នុងសម័យនោះមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករដោយខ្លួនឯងដែរឬទេ?

ឆ្លើយតបនឹងការចោទសួរអំពីបញ្ហាទាំងនេះ ឌុច បានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាមិនបានហាមដាច់ខាតមិនឲ្យប្រជាជនចាស់ជ្រើសរើសយកប្រជាជនថ្មីធ្វើគូស្រករឡើយ ។ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយមួយក្នុងការជ្រើសរើសគូស្រករគឺ "មួយបូកមួយត្រូវតែស្មើពីរ" មិនអាច "មួយបូកមួយស្មើសូន្យ" ឡើយ ។ ដូចនេះការជ្រើសរើសគូស្រករត្រូវគិតពីបញ្ហាខ្មាំងរបស់បក្សដែលប្រការនេះធ្វើឲ្យប្រជាជនចាស់មិនហ៊ានជ្រើសរើសប្រជាជនថ្មីយកមកធ្វើជាគូស្រករនោះទេ ទោះបីមានការពេញចិត្តយ៉ាងណាក៏ដោយ ។ ម្យ៉ាងវិញទៀត ការជ្រើសរើសគូស្រករត្រូវមានការយល់ព្រមពីអង្គការ ។ ឌុច បានលើកពីបទពិសោធផ្ទាល់ខ្លួនក្នុងការជ្រើសរើសគូស្រករដែលពេលនោះគាត់អាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែថ្នាក់លើរបស់ប្តីប្រពន្ធទាំងពីរយល់ព្រម ចំណែកឪពុកម្តាយរបស់គាត់មិនមានសិទ្ធិសម្រេចឡើយ ។ បន្ថែមលើនេះទៀត ឌុច បានបញ្ជាក់ថា ក្នុងអំឡុងពេល

នៃរបបកម្ពុជាប្រជាធិបតេយ្យមានចម្រៀងអប់រំមួយមានខ្លឹមសារថា "ម៉ែឪបង្កើតមនុស្សបានតែម្នាក់ទេ អង្គការបដិវត្តន៍រំដោះបានមនុស្សមួយនគរ ដូច្នេះម៉ែឪអត់មានតួនាទីទេ អង្គការជាម៉ែឪ" ។

### ឃ) ការកំណត់ និងការបោសសម្អាតខ្មាំង

ទាក់ទងនឹងការកំណត់សត្រូវ ឬខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ឌុច បានផ្តល់សក្ខីកម្មថា មុនឆ្នាំ១៩៧៣ បក្សបានកំណត់ថាប្រជាជនដែលរត់ចូលក្នុងតំបន់រំដោះដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាត្រូវចាត់ទុកថាជាគិញ ឬជាខ្មាំង ។ ក្រោយមកបន្ទាប់ពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកក្នុងកំឡុងឆ្នាំ ១៩៧៣ ប្រជាជនដែលរស់នៅក្នុងតំបន់ដែលបក្សកុម្មុយនីស្តកម្ពុជារំដោះបានក៏ត្រូវបានចាត់ទុកថាជាខ្មាំងរបស់បក្សដែរ ។ ឌុចបានបញ្ជាក់យ៉ាងច្បាស់ថា ទិសដៅបោសសម្អាតខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា គឺសំដៅលើបុគ្គលទាំងឡាយណាដែលមានការជាប់ពាក់ព័ន្ធនឹងសហរដ្ឋអាមេរិក បន្ទាប់មកអ្នកដែលមានការជាប់ទាក់ទងជាមួយវៀតណាម (សំដៅដល់អតីតកម្មាភិបាលដែលធ្លាប់ជាប់ពាក់ព័ន្ធនឹងបក្សប្រជាជនបដិវត្តកម្ពុជា) ក្រោយមកទៀតកងកម្លាំងរបស់ កុយ ធួន និង កែ ពក ។ គោលនយោបាយនៃការបោសសម្អាតខ្មាំងបានចាប់ផ្តើមរីករាលដាលស្ទើរតែគ្រប់ក្រសួងទាំងអស់ ។

គួររំឭកសម្តីរបស់ ឌុច ដែលបានបញ្ជាក់ថា នៅក្នុងទស្សនាវដ្តីទង់បដិវត្តឆ្នាំ១៩៧៣ បក្សកុម្មុនីស្តកម្ពុជាបានកំណត់វណ្ណៈពិសេស១ចំនួនពីរ គឺវណ្ណៈមន្ត្រីរាជការ ប៉ូលីស ទាហ៊ាន របស់របបមុន និងវណ្ណៈលោកសង្ឃ ។ មូលហេតុដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកលោកសង្ឃថាជាវណ្ណៈពិសេស ពីព្រោះលោកសង្ឃបានយកទ្រឹស្តី "កម្មផល" មកអប់រំប្រជាជន ដែលធ្វើឲ្យប្រជាជនមានភាពស្ពឹកស្រពន់មិនចូលរួមធ្វើបដិវត្ត ។

បន្ទាប់ពីសួរយ៉ាងលម្អិតពាក់ព័ន្ធនឹងការកំណត់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា លោកតំណាងសហព្រះរាជអាជ្ញា សេង ប៊ុនយាង បានដាក់ឯកសារមួយចំនួនដើម្បីសួរបញ្ជាក់អំពីគោលនយោបាយរបស់បក្សក្នុងការបោសសម្អាតខ្មាំង ។ ឯកសារទាំងនោះរួមមានឯកសារស្តីពី "សេចក្តីរាយការណ៍របស់មន្ទីរក្រសួងស្តីពីការបោសសម្អាត" ឯកសារស្តីពី "មតិយោបល់របស់កម្មាភិបាលខ្មែរក្រហមនៅពេលកិច្ចប្រជុំស្តីពីការបោសសម្អាត" ។ ជាលទ្ធផលឌុចមិនស្គាល់ឯកសារទាំងនេះឡើយ ប៉ុន្តែសហព្រះរាជអាជ្ញាបានព្យាយាមឲ្យ ឌុច មើលខ្លឹមសាររបស់ឯកសារទាំងនេះដើម្បីធ្វើការប្រៀបធៀប និងឆ្លុះបញ្ចាំងពីខ្លឹមសារដែលមាននៅក្នុងឯកសារទាំងនោះជាមួយអង្គហេតុដែល ឌុច បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំង ។ ប៉ុន្តែករណីនេះត្រូវបានមេធាវីការពារក្តី អៀង សារី គឺ លោក ខណាវ៉ាស់ បានធ្វើការជំទាស់យ៉ាងខ្លាំងដោយលោកបានលើកឡើងថា តំណាងសហព្រះរាជអាជ្ញាមិនអាចតាំងសំណួរដើម្បីឲ្យសាក្សីបញ្ជាក់ពីយថាភាពរបស់ឯកសារដែលខ្លួនកំពុងតែបង្ហាញឡើយ ។ ម្យ៉ាងវិញទៀត ក្នុងករណីសាក្សីមិនស្គាល់ឯកសារណាមួយ តំណាងសហព្រះរាជអាជ្ញាមិនអាចយកខ្លឹមសាររបស់ឯកសារនោះមកសួរសាក្សីឡើយ ដោយលោកអះអាងថា ការធ្វើបែបនេះគឺដូចជាការ "បញ្ចុកដល់សាក្សីដើម្បីទទួលបានចម្លើយ" ។

## ២.២) ការចោទសួរដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិចំពោះ ឌុច

បន្ទាប់ពីលោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនយាង ចោទសំណួរទៅសាក្សីអំពីតួនាទី និងការកិច្ចរបស់សាក្សីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយមួយចំនួនដែលត្រូវបានអនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យរួចមក សហព្រះរាជអាជ្ញារងអន្តរជាតិគឺលោក វីល្លៀម ស្មីត បានបន្តការសួរសាក្សីអំពីរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពាក់ព័ន្ធនឹងអង្គហេតុនេះ លោក ស្មីត បានសួរផ្តោតជាបឋមលើលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងបន្ទាប់មកស្នើឲ្យសាក្សី ឌុច ពន្យល់ឯកសារមួយចំនួនដែលបង្កើតឡើងដោយរបប កម្ពុជាប្រជាធិបតេយ្យ ។

### ២.២.១) លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា

សំណួរពាក់ព័ន្ធនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាបញ្ហាសំខាន់ដែលលោក វីល្លៀម ស្មីត បានចោទសួរសាក្សីដើម្បីឲ្យអង្គជំនុំជម្រះ ក៏ដូចជាសាធារណជនបានយល់ពីដំណើរការប្រព្រឹត្តទៅរបស់បក្ស ។

ទាក់ទងនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ឌុច បាន

អះអាងថាលក្ខន្តិកៈនេះមានបីដំណាក់កាល គឺដំណាក់កាលទី១ អនុម័តនៅឆ្នាំ១៩៦០ ដំណាក់កាលទី២អនុម័តនៅឆ្នាំ១៩៧១ និងដំណាក់កាលទី៣អនុម័តនៅឆ្នាំ១៩៧៦ ហើយខ្លួនធ្លាប់បាន ឃើញ និងរៀនសូត្រដោយយកចិត្តទុកដាក់បំផុត ពីព្រោះបក្ខជន ទាំងអស់ត្រូវបានតម្រូវឲ្យរៀនពីលក្ខន្តិកៈបក្សទាំងអស់គ្នា ។ បក្ខជន គ្រប់រូបដែលមានការព្រួយបារម្ភពីបញ្ហាសន្តិសុខផ្ទាល់ខ្លួនគឺត្រូវតែ រៀនសូត្រពីលក្ខន្តិកៈបក្សឲ្យបានចេះចាំស្ទាត់ ដើម្បីជៀសវាងការ ប្រព្រឹត្តខុស ។ ឌុច បានបញ្ជាក់ថា លក្ខន្តិកៈបក្ស គឺជាឯកសារ មូលដ្ឋានគ្រឹះរបស់បក្សកុម្មុយនីស្តកម្ពុជាដែលក្នុងនោះចែកជាពីរ ផ្នែក គឺមួយផ្នែកនិយាយពីមាគ៌ានយោបាយរបស់បក្ស និងមួយ ផ្នែកទៀតនិយាយពីមាគ៌ាចាត់តាំង ។ លក្ខន្តិកៈដែលបក្សកុម្មុយ នីស្តកម្ពុជាប្រើក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺលក្ខន្តិកៈបក្ស ឆ្នាំ១៩៧៦ ដែលលក្ខន្តិកៈនេះមានលក្ខណៈស្ទើរតែដូចគ្នាទាំងស្រុង នឹងលក្ខន្តិកៈឆ្នាំ១៩៧១ ខុសប្លែកគ្នាត្រង់ថា លក្ខន្តិកៈបក្សឆ្នាំ ១៩៧៦ មានចែងលម្អិតជាងបន្តិចអំពីកងទ័ព ។


វីល្យៀម ស្មីត

លោក ស្មីត បានបន្តសំណួរទាក់ទងនឹងលក្ខន្តិកៈរបស់បក្ស កុម្មុយនីស្តកម្ពុជា ដែលមានចែងអំពីគោលការណ៍មួយចំនួនសម្រាប់ អនុវត្តជាទូទៅនៅក្នុងបក្ស ដោយលើកយកគោលការណ៍ឯករាជ្យ ម្ចាស់ការមកពិភាក្សាដេញដោល ។ទាក់ទងនឹងចំណុចនេះ ឌុចបាន បំភ្លឺថា គោលការណ៍នេះជាចំណុចដែលធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈខុសប្លែកពីបក្សកុម្មុយនីស្តផ្សេងៗទៀត ដោយសារ កម្ពុជានាពេលនោះ គឺឯករាជ្យពីចិន វៀតណាម និងសូវៀត ។ កម្ពុជាប្រកាន់យកតែអ្វីដែលខ្លួនមាន ជាក់ស្តែងមានជំហរកាន់កាប់ លើវាសនារបស់ខ្លួន និងបានអនុវត្តតាមអ្វីដែលម៉ាក្សបានសរសេរ ដោយមានការកែច្នៃខ្លះៗ ដើម្បីឲ្យត្រូវនឹងបរិបទរបស់ប្រទេស កម្ពុជានាពេលនោះ ។ ឌុច បានលើកឡើងថា "គ្មានមាគ៌ាណាឲ្យ យើងលើកបក្សតាមផលប្រយោជន៍របស់គេទេ យើងធ្វើទៅតាម ផលប្រយោជន៍របស់បក្សកុម្មុយនីស្តកម្ពុជា វណ្ណៈអធនកម្ពុជា ដោយខ្លួនយើង មិនមែនដោយចិន ឬដោយយួននោះទេ" ។ ឌុច បន្តថា គោលការណ៍ឯករាជ្យម្ចាស់ការត្រូវបានបង្រៀនដល់បក្ខជន ទាំងអស់ ហើយបក្ខជនទាំងនោះបង្រៀនបន្តនៅតាមអង្គភាព នីមួយៗទៀត ។

បន្ទាប់ពីលោក វីល្យៀម ស្មីត សួរបញ្ជាក់ពីអត្តសញ្ញាណនៃ លក្ខន្តិកៈទាំងបីដំណាក់កាលរបស់បក្សកុម្មុយនីស្តកម្ពុជារួចហើយ លោកបានស្នើឲ្យសាក្សីពន្យល់នូវចំណុចជាក់លាក់ដែលមានកំណត់ ក្នុងលក្ខន្តិកៈនោះដើម្បីធ្វើការប្រៀបធៀប និងជាការឆ្លុះបញ្ចាំង អំពីខ្លឹមសារនៅក្នុងលក្ខន្តិកៈនេះទៅនឹងការប្រព្រឹត្តជាក់ស្តែងដែល បានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឃ្លាមួយក្នុង ចំណោមឃ្លាជាច្រើននៅក្នុងលក្ខន្តិកៈបក្សដែលលោក វីល្យៀម ស្មីត សួរឲ្យសាក្សីពន្យល់នោះគឺ "បក្សបន្តដឹកនាំបដិវត្តសង្គមនិយម និង កសាងសង្គមនិយមតទៅមុខទៀតដោយផ្តាច់មុខ ដាច់ខាត និងគ្រប់ ផ្នែក" ។ ឆ្លើយតបនឹងសំណួរនេះ ឌុច បានលើកឡើងថា មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានដឹកនាំធ្វើបដិវត្ត ប្រជាជាតិប្រជាធិបតេយ្យ ហើយរហូតដល់ក្រោយថ្ងៃ១៧ ខែ មេសា ឆ្នាំ១៩៧៥ បក្សបានដឹកនាំបដិវត្តសង្គមនិយម និងកសាង សង្គមនិយមដែលជាមូលដ្ឋានគ្រឹះនៃមាគ៌ានយោបាយរបស់បក្ស កុម្មុយនីស្តកម្ពុជា ។ ឌុច បានពន្យល់យ៉ាងច្បាស់ថា "...បដិវត្តន៍ សង្គមនិយមមានន័យថា កម្មសិទ្ធិលើមធ្យោបាយផលិតកម្មទាំងអស់ គឺជារបស់បក្ស បក្សជាអ្នកចាត់ចែងកម្លាំងទាំងអស់ និងជាអ្នក កំណត់ផែនការសេដ្ឋកិច្ច (សេដ្ឋកិច្ចផែនការ) ។ "កសាងសង្គម និយម" មានន័យថា ធ្វើឲ្យសតិអារម្មណ៍របស់បុគ្គលម្នាក់ៗចាកផុត ពីគ្រួសារនិយម បក្ខពួកនិយម សន្តូតនិយម បុណ្យស័ក្តិនិយម" ។ "ពាក្យផ្តាច់មុខ" គឺបក្សកុម្មុយនីស្តកម្ពុជាដឹកនាំតែម្នាក់ឯងដោយ

ផ្តាច់មុខដែលមាន ប៉ុល ពត និង នួន ជា ជាអ្នកដឹកនាំ ។ "ពាក្យដាច់ខាត" គឺ ប៉ុល ពត និង នួន ជា ដឹកនាំបក្សដោយដាច់ខាតមិនរាថយ ។ "គ្រប់ផ្នែក" គឺនគរបាល យោធា សេដ្ឋកិច្ច ពាណិជ្ជកម្ម ដឹកនាំដោយ ប៉ុល ពត និង នួន ជា ។ ចំពោះការប្រជុំ "ទិតៀននិងស្វ័យទិតៀន"(ប្រជុំជីវភាព) ឌុច បានបញ្ជាក់ថា គឺជាមធ្យោបាយក្នុងការកសាងខ្លួន ។ អ្នកចូលរួមប្រជុំអាចធ្វើការទិតៀនអ្នកណាម្នាក់ ឬទិតៀនលើខ្លួនឯង ។ ជាគោលការណ៍ ការប្រជុំទិតៀនធ្វើឡើងជាប្រចាំខែ ហើយអ្នកចូលរួមប្រជុំទាំងអស់ត្រូវតែមានរបាយការណ៍ស្តីពីកំហុសរបស់បុគ្គលណាម្នាក់ដើម្បីធ្វើការទិតៀន ។ យោងតាមការកំណត់នេះ កម្មាភិបាលខ្មែរក្រហមម្នាក់ៗតែងតែចាំឃ្លាំមើលកំហុសរបស់កម្មាភិបាលខ្មែរក្រហមផ្សេងៗទៀត ដើម្បីបានរបាយការណ៍សម្រាប់រាយការណ៍នៅពេលប្រជុំទិតៀននេះ ។ សហព្រះរាជអាជ្ញាស្នើឲ្យសាក្សីធ្វើការពន្យល់ ដូចជាគោលការណ៍ ប្រជាធិបតេយ្យប្រមូលផ្តុំ មាគ៌ាទស្សនៈមហាជនចក្រពត្តិ ចលនាមហាជនជាដើម ហើយពាក្យទាំងនេះត្រូវបាន ឌុច ពន្យល់យ៉ាងក្បោះក្បាយ ។

ឌុច បញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតលក្ខន្តិកៈបក្សឡើង គឺដើម្បីយកទៅអនុវត្តន៍នៅទូទាំងប្រទេស ហើយនៅក្នុងលក្ខន្តិកៈបក្សនោះក៏មានចែងអំពីគោលការណ៍បក្ស លក្ខខណ្ឌក្នុងការចូលជាសមាជិកបក្ស វិន័យរបស់បក្ស និងបទបញ្ញត្តិផ្សេងៗទៀត ។

### ក) លក្ខណៈវិនិច្ឆ័យចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា

ឌុច បានបញ្ជាក់ថា លក្ខន្តិកៈបក្សនៅក្នុងឆ្នាំ១៩៧១ និង ១៩៧៦មានលក្ខណៈដូចគ្នាភាគច្រើន ។ ចំពោះលក្ខខណ្ឌនៃការជ្រើសរើសសមាជិកបក្សដែលមានចែង១០ខ ក៏មានលក្ខណៈដូចគ្នាដែរ ប៉ុន្តែលក្ខន្តិកៈទាំងពីរនេះខុសប្លែកពីលក្ខន្តិកៈបក្សនៅឆ្នាំ ១៩៦០ដែលការជ្រើសរើសសមាជិបក្សគឺគិតពីអតីតភាពនៃការធ្វើបដិវត្ត ។

ឌុច បានប្រាប់អង្គជំនុំជម្រះអំពីសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា (ស.យុវកក) ដែលជាអង្គការមួយសម្រាប់ជ្រើសរើសជនបដិវត្តពីអង្គការមហាជន ជនចម្រើនមកជាអង្គការសម្ព័ន្ធយុវកក ។ គេលត់ដំដាក់ភារកិច្ចមួយរយៈសិនទើបគេបញ្ចូលយុវកកមកជាបក្ខជន ។ ដូចនេះគេហៅថាជាអង្គការស្នូលរបស់បក្ស ។ អង្គការស្នូលនេះមានពីរគឺអង្គការស្នូល និងអង្គការបង្កោល ដែលអង្គការទាំងពីរនោះខុសគ្នា ។ បើនរណាមានមុខរបរជាអនុធន និងមានអាយុលើលពី១៨ឆ្នាំ គេមិនបញ្ចូលទៅក្នុងយុវកកទេ គេបញ្ចូលក្នុងអង្គការបង្កោល ។ ឌុច និយាយថា "រូបខ្ញុំផ្ទាល់មិនបានចូលទៅក្នុងយុវកកទេ គឺចូលទៅក្នុងអង្គការបង្កោលតែម្តង ព្រោះខ្ញុំមានលុយមានតំណែង និងមានអាយុលើសពី១៨ឆ្នាំទៅហើយ" ។ ឌុច ចូលក្នុងអង្គការស្នូលតាំងពីឆ្នាំ១៩៦៥ ហើយបានចូលជាសមាជិកត្រៀមនៅថ្ងៃទី២៥ ខែធ្នូឆ្នាំ១៩៦៧ ។

ឌុច បានលើកឡើងពីគោលការណ៍មួយចំនួនដើម្បីក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ។ គោលការណ៍ទាំងនោះត្រូវបានអនុវត្តនៅទូទាំងប្រទេស មានដូចជា ៖

**គោលការណ៍ប្រយុទ្ធល្អ និងជាប់ជានិច្ច ៖** ការប្រយុទ្ធល្អ គឺអាស្រ័យលើបរិបទសង្គម ។ ឌុច បានលើកឧទាហរណ៍ថា ខ្លួនធ្លាប់ជាសាស្ត្រាចារ្យបឋមភូមិនៅសាកលវិទ្យាល័យស្កន់ ។ ការប្រយុទ្ធល្អនិងជាប់ជានិច្ចនោះ គឺខណៈដែលខ្លួនជាសាស្ត្រាចារ្យ ខ្លួនបានធ្វើកម្មភាពពង្រីកខ្លួនដើម្បីបក្សជាប់ជានិច្ច ដោយការដឹកនាំសិស្សបាចខិត្តប័ណ្ណ ។ ការបាចខិត្តប័ណ្ណនេះធ្វើជាបន្តបន្ទាប់ និងធ្វើសកម្មភាពពង្រីកជួររបស់ខ្លួនជាប់បន្តបន្ទាប់ ព្រមទាំងពង្រីកសីលធម៌របស់បក្សដែលត្រឹមត្រូវ ស្លូតបូត ទន់ភ្លន់ជាមួយមហា ជន ។ ឌុច បានបន្តទៀតថា តាមការយល់ឃើញរបស់ខ្លួនគោលការណ៍ទីមួយនេះ ពិតជាអាចតម្រូវចំពោះការជ្រើសរើសត្រៀមចំពោះកងឈ្លបនិងកងការពារសម្ងាត់ ប៉ុន្តែដោយសារខ្លួនរស់នៅក្រៅការកសាងកងឈ្លប និងការកសាងកងការពារសម្ងាត់ ដូចនេះខ្លួនមិនបានជួបនឹងបញ្ហានេះទេ ។

**គោលការណ៍វណ្ណៈភាពល្អនិងវណ្ណៈភាពដើម** ៖ សមាជិកបក្សត្រូវមានវណ្ណៈភាពល្អជាពិសេស គឺមានជំហរកម្មករ ។ វណ្ណៈភាពល្អមានន័យថា សមាជិកបក្សត្រូវមានបើសំដៅទៅកសិករគឺកសិករកណ្តាល និងថ្នាក់ក្រោមបើកម្មករ គឺសំដៅកម្មករខស្សរាហកម្ម បើជាយុវជនសិក្សាគេសំដៅលើវណ្ណៈភាពម៉ែឪ ដែលជាកម្មករ ។ វណ្ណៈភាពក្រៅពីនេះ ត្រូវចាត់ទុកជាជម្រើសទីពីរនិងទីបី ។ កសិករថ្នាក់កណ្តាល និង កសិករកណ្តាលថ្នាក់លើ និងពួកអនុធនគេចាត់ទុក

ជាជម្រើសទីពីរ ។ រីឯជម្រើសទីបី គឺអ្នកផ្សេងទៀតក្រៅពីនោះ ។

**គោលការណ៍សីលធម៌រស់នៅល្អស្អាតស្អំ** : ស្អាតស្អំ គឺទី១ មិនស្រា ទីពីរមិនស្រី ទីបីមិនល្បែងពាលា ។ ស្អាតស្អំខាងនយោបាយមានពីរ គឺទី១) មិនមានសកម្មភាពចូលខ្មាំងបំផ្លាញបដិវត្តន៍ និងទី២) មិនមានបងប្អូននៅជាមួយខ្មាំង ។ ឌុច បានបញ្ជាក់ដោយភាពស្រពិចស្រពិលថា នៅក្នុងលក្ខន្តិកៈដែលតម្រូវអំពីគោលការណ៍នេះ ប្រហែលជាធ្វើឡើងនៅមុនឆ្នាំ១៩៧៥ ។ លោកបន្តថា ខ្មាំងក្នុងបរិបទនេះមានន័យថា មិនជាប់សកម្មភាពជាមួយនឹងមនុស្សនៃរបប លន់ នល់ ហើយក្រោយឆ្នាំ១៩៧៥ គោលការណ៍នេះផ្លាស់ប្តូរយ៉ាងណា គឺពិបាកនិយាយណាស់ ។

លក្ខន្តិកៈបក្សបានចែងអំពីការសម្រេចឲ្យចូលជាបក្ខជនដែលត្រូវឆ្លងកាត់ការពិនិត្យវិនិច្ឆ័យជាសមូហភាព ។ ការសម្រេចនេះធ្វើឡើងពីច្រើនថ្នាក់ ច្រើនកម្រិត នៃគណៈកម្មាការជ្រើសរើសដែលតម្រូវជាពិសេសសម្រាប់បុគ្គលនីមួយៗក្នុងការពិនិត្យពាក្យសុំ ។ នៅតាមមូលដ្ឋានត្រូវមានអង្គការបក្ស៣ ថ្នាក់សម្រាប់ពិនិត្យជាសមូហភាព គឺសាខាគណៈកម្មាធិការថ្នាក់ស្រុក គណៈកម្មាធិការបក្សតំបន់ និងគណៈកម្មាធិការបក្សភូមិភាគ ។ ចំពោះផ្នែកយោធាមានប្រាំថ្នាក់ គឺសាខា(អង្គការដឹកនាំកម្រិតទាបបំផុតរបស់បក្ស ឬកម្រិតមូលដ្ឋាន) អនុសេនាធំ គណៈកម្មាធិការវរសេនាតូច គណៈកម្មាធិការវរសេនាធំ គណៈកម្មាធិការកងពល និងគណៈកម្មាធិការស្នងការ ។ឌុចនិយាយថា នៅមុនឆ្នាំ១៩៧៥ មិនមាននរណាចង់ធ្វើជាបក្ខជនទេ ព្រោះវាមានបញ្ហាស្មុគស្មាញ ។ ប៉ុន្តែនៅក្រោយឆ្នាំ១៩៧៥ នរណាក៏ចង់ធ្វើជាបក្ខជនដែរ ។ ដូចនេះដើម្បីការពារការជ្រៀតចូលរបស់ខ្មាំង បក្សបានបង្កើតឲ្យមានគណៈកម្មាធិការច្រើនថ្នាក់ដើម្បីសម្រេចពីការទទួលយកបក្ខជននេះ ។ ការរៀបចំពាក្យស្នើជាបក្ខជនដែលជាសមាជិកពេញសិទ្ធិ ធម្មតាមិនមែនសាមីបុគ្គលជាអ្នកធ្វើដោយខ្លួនឯងទេ គឺសាខាជាអ្នករៀបចំឲ្យ ។ សមាជិកត្រៀមគ្មានសិទ្ធិឲ្យគេជ្រើសតាំងជាលេខាសាខាបានទេ គឺនៅក្រោមបង្គាប់គេស្តាប់គេ ។ សមាជិកត្រៀម គឺសំដៅយកអង្គការស្នូលរបស់បក្សដែលមានគុណធម៌គ្រប់គ្រាន់អាចឲ្យគេបញ្ចូលជាសមាជិកបក្សបាន ប៉ុន្តែបក្សមិនទាន់បានលត់ដំឲ្យស្គាល់ថាតើគុណធម៌ប្រយុទ្ធកម្រិតណា ទើបឲ្យនៅជាសមាជិកត្រៀមសិន ។ ឆ្លើយតបទៅសហព្រះរាជអាជ្ញា ឌុច បានពន្យល់ថា ចលនាក្តៅគឺចលនាយោធាប្រយុទ្ធស្លាប់រស់នៅសមរភូមិមុខ ចលនាប្រជាជនធ្វើការនៅក្នុងសហករណ៍ប្រយុទ្ធជាប់ជានិច្ច លើកទំនប់ជាដើម ចលនាមិនសូវក្តៅគឺចលនាមន្ទីរ ឧទាហរណ៍យុវជនធ្វើការនៅមន្ទីរនានា ។

### ១) វិន័យរបស់បក្ស

យោងតាមលក្ខន្តិកៈសមាជិកគ្រប់រូបត្រូវតែគោរពវិន័យរបស់បក្ស មិនថាបុគ្គលនោះមានតួនាទីជាអ្វីនោះទេ ។ ការគោរពវិន័យរបស់បក្សនេះ គឺជាការគោរពមាគ៌ានយោបាយរបស់បក្ស គោលជំហរ សតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំង និងលក្ខន្តិកៈរបស់បក្ស ។ ការគោរពវិន័យជាដាច់ខាតមានន័យថា ត្រូវតែធ្វើមិនអាចខានបាន និងមិនអាចធ្វើខុសបានឡើយ ។ បុគ្គលដែលត្រូវទទួលវិន័យ គឺបុគ្គលដែលជំទាស់មាគ៌ាឬជំហររបស់បក្ស ប្រឆាំងលក្ខន្តិកៈ ធ្វើឲ្យមានការបាក់បែកផ្ទៃក្នុងនិងឯកភាពរបស់បក្ស ការបង្កើតក្រុមហើយអនុវត្តការបំបែកបក្ស ឬប្រឆាំងនឹងបដិវត្ត មិនព្រមអនុវត្តភារកិច្ចរបស់បក្ស ធ្វើឲ្យបែកការសម្ងាត់ ធ្វើឲ្យបក្សទទួលរងគ្រោះ បំផ្លាញដល់ទ្រព្យសម្បត្តិរបស់បក្ស ប្រព្រឹត្តសីលធម៌ ឬពាលាអាវ៉ាសែ មិនប្រជុំជីវភាពបីខែជាប់ជាដើម ។ ទាំងនេះសុទ្ធតែជាបទល្មើសវិន័យ ដែលត្រូវតែទទួលការតិទៀន ឬព្រមាន ។ សាក្សី ឌុច បានលើកជាឧទាហរណ៍ចំពោះការតិទៀនថា នៅពេលដែល ណាត នៅមន្ទីរស-២១ណាត បានធ្វើខុសធ្ងន់ ពេលនោះ ឌុច នៅជាអនុលេខា ។ ឌុច និយាយថាខ្លួនមិនមានសិទ្ធិអ្វីតិទៀនធ្ងន់ធ្ងរទៅ ណាត ទេ គឺគ្រាន់តែរំឭកប៉ុណ្ណោះ ។ នេះហៅថាតិទៀន ។ ក្នុងការពន្យល់ពីទង្វើធ្ងន់ជាងនេះ ឬការព្រមាននោះ ឌុច បានលើកជាឧទាហរណ៍ទៀតថា មិត្តហ៊ីរ នៅមន្ទីរ សន្តិសុខស-២១ បានធ្វើឲ្យបែកការសម្ងាត់នៃចម្លើយសារភាព ។ ដូចនេះបក្សបញ្ឈប់មិត្ត ហ៊ីរ លែងឲ្យអានឯកសារនៅមន្ទីរស-២១តទៅទៀត ។ សាក្សីបានបញ្ជាក់ថា នេះជាការព្រមានហើយ ។ ការព្រមាន និងការអនុវត្តវិន័យអាចជាការដកហូតពីតំណែង ការចាប់ខ្លួន រហូតដល់ការកម្ទេចចោលទៀតផង ។

### ២.២.២) រចនាសម្ព័ន្ធរដ្ឋបាល

ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិប

*តេយ្យ លោកសហព្រះរាជអាជ្ញារងអន្តរ ជាតិបានសួរដេញដោល ឌុច ដោយផ្តោតជាសំខាន់លើសភាតំណាងប្រជាជនកម្ពុជា, ស្ថាប័នតុលាការ, គណៈប្រធានរដ្ឋ, គណៈកម្មាធិការមជ្ឈិម, មន្ទីរ៨៧០, ក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យ, រចនាសម្ព័ន្ធ រដ្ឋបាលថ្នាក់មូលដ្ឋាន និងយោធា ។*

### ក) សភាតំណាងប្រជាជនកម្ពុជា

*បន្ទាប់មកលោកសហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងការបោះឆ្នោតជ្រើសរើសសភាតំណាងប្រជាជន ។ ឌុច បានឆ្លើយតបនឹងសំណួរនេះថា នៅភ្នំពេញមានមណ្ឌលបោះឆ្នោតតែមួយទេ គឺនៅមុខស្ថានីយរាជាយស្ម័យយានដែលជាមណ្ឌលបោះឆ្នោតរបស់ខណ្ឌទួលគោក ហើយតំណាងរាស្ត្រដែលឈរឈ្មោះនៅមណ្ឌលនោះគឺបងទីពីរ នួន ជា រីឯអ្នកបោះឆ្នោតរួមមានបង ហែម (ខៀវ សំផន), សម្តេច សីហនុ, ប៉ែន នុត ។ ចំពោះកន្លែងផ្សេងទៀតមិនមានការបោះឆ្នោតទេ ដោយ ឌុច លើកឧទាហរណ៍ពីប្រពន្ធរបស់ ណាត (អតីតលេខាស-២១) ឈ្មោះថា មិត្ត គុណ ដែលមាននាទីប្រធានរោងចក្រ គឺតំណាងឲ្យខាងកម្មករ, មិត្ត សាយ មាននាទីជាគណៈកម្មាធិការឧស្សាហកម្មគឺតំណាងឲ្យកម្មករ, មិត្ត សោម ជំនួយការសេនាធិការ គឺតំណាងឲ្យខាងយោធា ។ ឌុច បានបន្តថា សភាតំណាងប្រជាជនធ្វើឡើងគ្រាន់តែតំណាងប៉ុណ្ណោះ មិនដែលមានការប្រជុំនោះទេ ។ ជាងនេះទៅទៀត មានសមាជិកខ្លះនៃសភានេះត្រូវបានចាប់មកស-២១ថែមទៀត ។*

### ខ) តុលាការ

*ទាក់ទងនឹងស្ថាប័នតុលាការនៃរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាគឺជាអ្នកក្តាប់អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។*

### គ) គណៈប្រធានរដ្ឋ

*រីឯគណៈប្រធានរដ្ឋឌុចបានបញ្ជាក់ថាគ្រាន់តែជាស្ថាប័នឧបកិច្ចប៉ុណ្ណោះគឺគ្មានអង្គភាពគ្មាន សកម្មភាពទេ ។ ស្ថាប័ននេះមាន ខៀវ សំផន ជាប្រធាន ប៉ែន នុត ជាអនុប្រធាន និងរស់ ញឹម ជាសមាជិក ។ លោកសហព្រះរាជអាជ្ញារង ស្មីត បានចោទសួរឌុចថា តើ រស់ ញឹម ជានរណា ។ ភ្លាមៗនោះ សំណួរនេះត្រូវបានមេធាវីការពារនួនជា គឺលោក ម៉ៃឃើល ផេស្តមេន ជំទាស់សាជាថ្មីទៀត ដោយបញ្ជាក់ថា សហព្រះរាជអាជ្ញាកំពុងតែព្យាយាមសួរសំណួរនាំមុខសាក្សី ។ មិនខុសពីការជំទាស់មុនៗ អង្គជំនុំជម្រះនៅតែបដិសេធការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា ដោយអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្តសួរសំណួររបស់ខ្លួន ។ ឌុច បានអះអាងថារស់ញឹមគឺជាលេខាគណៈកម្មាធិការភូមិភាគពាយ័ព្យ ក្រោយមកត្រូវបានចាប់ខ្លួនបញ្ជូនមកស-២១ ដោយសារតែមានគេឆ្លើយដាក់ ។*

### ឃ) ភារៈកិច្ចរបស់គណៈកម្មាធិការមជ្ឈិម

*លោកសហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានស្នើឲ្យ ឌុច អានមាត្រា២៣នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាដែលនិយាយពីភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម អត្ថន័យដែល ឌុច បានអានគឺៈ*

*“១) ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិមគឺអនុវត្តមាគ៌ានយោបាយរបស់បក្សនិងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទាំងមូល ។*

*២) ណែនាំអង្គការភូមិភាគតំបន់ស្រុកទាំងអស់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេសធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំងតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស ។*

*៣) គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ដោយក្តាប់ប្រវត្តិរូបជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់ និងឲ្យជាប់ជានិច្ច ហើយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច ។*

*៤) តាងនាមបក្ស ក្នុងការទាក់ទងបណ្តាបក្សម៉ាក្សលេនីនជាបងប្អូន ។”*

*បន្ទាប់មកលោក ស្មីត បានសួរថា តើសមាជិកគណៈមជ្ឈិមរបស់របបកម្ពុជាប្រជាធិបតេយ្យមានចំនួនប៉ុន្មាន ។ ឌុច បានអះអាងថា អង្គការមជ្ឈិមបក្សមានចំនួន៤ថ្នាក់ ៖*

*១) **ជំនួយការមជ្ឈិម** ដែលមានសិទ្ធិចូលទៅរៀនជាមួយ*

នឹងគេតែគ្មានសិទ្ធិបញ្ចេញមតិនិងគ្មានសិទ្ធិបោះឆ្នោតសម្រេចទេ ។

៣) **មជ្ឈិមត្រៀម** អ្នកដែលនៅក្នុងមជ្ឈិមត្រៀមមានសិទ្ធិរៀនជាមួយនឹងគេ និងមានសិទ្ធិបញ្ចេញមតិ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតសម្រេចទេ ។

៣) **មជ្ឈិមពេញសិទ្ធិ** អ្នកដែលស្ថិតនៅក្នុងមជ្ឈិមពេញសិទ្ធិ មានសិទ្ធិក្នុងការបោះឆ្នោត ដើម្បីសម្រេច ។

៤) **អចិន្ត្រៃយ៍មជ្ឈិម** មានសមាជិកចំនួន៧រូប គឺ ប៉ុល ពត ដែលជាលេខា, នួន ជា ជាអនុលេខាទី១, សោ ភឹម អនុលេខាទី២, អ៊ុង ជឿន ហៅ ម៉ុក អនុលេខាទី៣, អៀងសារីសមាជិកមជ្ឈិមពេញសិទ្ធិ, វ៉ន វេត ជាសមាជិកមជ្ឈិមត្រៀម និង សុន សេន សមាជិកមជ្ឈិមត្រៀម ។

ឌុច បំភ្លឺថា សមាជិកអង្គការមជ្ឈិកបក្សទាំងបួនថ្នាក់ដែលខ្លួនបានរៀបរាប់ខាងលើមានចំនួនសរុបទាំងអស់ប្រហែលមិនលើសពី១០០នាក់ ។ ឌុច បានបន្តថា សមាជិកអចិន្ត្រៃយ៍មជ្ឈិមទាំងអស់សុទ្ធតែរស់នៅភ្នំពេញ លើកលែងតែ ដួន ជឿន (តាម៉ុក) និង សោ ភឹម ដែលជាអនុលេខាមជ្ឈិមប៉ុណ្ណោះ ដែលបានទៅគ្រប់គ្រងនៅតាមភូមិភាគ ។ ឌុច បញ្ជាក់ថា អំណាចទាំងអស់គឺប្រមូលនៅក្នុងកណ្តាប់ដៃ ប៉ុល ពត ប៉ុន្តែ នួនជាក៏នៅក្នុងនោះដែរ ព្រោះពេលណាដែលប៉ុលពតសម្រេចលើបញ្ហាអ្វីមួយ គឺ នួន ជា ជាអ្នកតាមមើលការអនុវត្ត ។ បន្តមកទៀត លោក ស្មិត បានបន្តសួរ ឌុច ទាក់ទងនឹងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានឆ្លើយថា សេចក្តីសម្រេចរបស់បក្សដែលធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ពិតជាត្រូវបានយកមកអនុវត្ត បន្ទាប់មកបក្សបានចាប់ផ្តើមសម្លាប់ផ្ទៃក្នុងខ្លួនឯង គឺសម្លាប់ពួកកម្មាភិបាល និងទាហានរបស់ខ្លួន ។ ឌុច បានបញ្ជាក់ថា ចំនួនអ្នកស្លាប់នៅក្រោយសេចក្តីសម្រេចឆ្នាំ១៩៧៦ ពិតជាមានច្រើនជាងការសម្លាប់មុនធ្វើសេចក្តីសម្រេច ។

### ង) មន្ទីរ៨៧០

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងគណៈមន្ទីរមជ្ឈិម ឌុច បានអះអាង ថា ខៀវ សំផន គឺជាប្រធាននៅទីនោះ ប៉ុន្តែមិនបានដឹងលម្អិតថា ខៀវ សំផន ធ្វើអ្វីនោះទេ ដោយ ឌុច អះអាងថា ខ្លួននៅឆ្ងាយពី ខៀវ សំផន ណាស់ ដូច្នេះខ្លួនមិនបានដឹងឡើយ ។ មកដល់ចំណុចនេះ មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន បានជំទាស់នឹងការសួរសំណួររបស់សហព្រះរាជអាជ្ញាដែលសួរសាក្សីនូវសំណួរដដែលៗ និងមិនចាំបាច់គឺ ឌុច ឆ្លើយតែអ្វីដែលខ្លួនបានអានចេញពីឯកសារតែប៉ុណ្ណោះ បើដូច្នេះក្រុមមេធាវីការពារក៏អាចអានឯកសារនោះដោយខ្លួនឯងបានដែរ ។ បន្ទាប់មក មេធាវីអន្តរជាតិការពារក្តី អៀង សារី លោក ខាណារ៉ាស់ បានក្រោកឡើងជំទាស់នឹងការចោទសួររបស់សហព្រះរាជអាជ្ញា ដោយលោកបានអះអាងថា សហព្រះរាជអាជ្ញាបានសួរសាក្សីនូវសំណួរដែលសាក្សីមិនបានដឹងដោយខ្លួនឯង ប៉ុន្តែយោងលើឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានផ្តល់ឲ្យ សាក្សី ឌុច ធ្វើការសិក្សាអស់រយៈពេលជាយូរមកហើយ ។ ដូច្នេះចម្លើយរបស់សាក្សី គឺគ្រាន់តែយោងលើកំណត់ហេតុរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ។ អង្គជំនុំជម្រះបានបដិសេធការជំទាស់របស់ក្រុមមេធាវីការពារក្តី ។

ឌុច បានបន្តលើកឡើងទាក់ទងនឹងការចូលប្រជុំរបស់ ខៀវ សំផន នៅក្នុងសេចក្តីសម្រេច ចាប់ខ្លួន សឿ វ៉ាស៊ី ហៅ ឌឿន និងថា ខៀវ សំផន មិនបានដណ្តើមអំណាចរបស់ ឌឿន ដូចជាការ សរសេររបស់ ដេវីត ឆេនល័រ ទេ ពីព្រោះ ខៀវ សំផន មានកិត្តិយសរបស់គេ ។ ម្យ៉ាងវិញទៀត ខៀវ សំផន មានតួនាទីធំជាង ឌឿន គឺ ខៀវ សំផន មានទាំងតួនាទីខាងពាណិជ្ជកម្ម និងតួនាទីខាងអគ្គិសនីនៅចាក់អង្រែថែមទៀត ។ ឌុច បញ្ជាក់ថា ខ្លួនដឹងពីបញ្ហានេះគឺយោងទៅលើការឆ្លើយសារភាពរបស់ យ៉ា ដែលខ្លួនជឿជាក់ថាចម្លើយនោះគឺជាការពិត ។

ឌុច បានលើកឡើងពីលិខិតដើរផ្លូវ ដែលមានសុពលភាពម្តង៦ខែ ។ ពេលចេញទៅណាមកណា ត្រូវតែមានលិខិតនេះជាចាំបាច់ ។ ឌុច បានបន្តថា សុន សេន បានចុះហត្ថលេខានៅលើលិខិតដើរផ្លូវនោះ ដោយប្រើឈ្មោះថា ឃឹម ។ ឌុច បានកត់សម្គាល់ថា សុន សេន មានឈ្មោះច្រើនណាស់ នៅក្នុងផ្នែកកងទ័ពគេហៅ សុន សេន ថា បង៨៩ ចំណែកឯនៅស-២១គេហៅថា បង៦២ ហើយឈ្មោះទូទៅគេហៅថា បងខៀវ សម្រាប់សំបុត្រដើរផ្លូវដែល សុន សេន ចុះហត្ថលេខាគឺប្រើឈ្មោះ បងឃឹម ។ ចំពោះលិខិតដើរផ្លូវរបស់ ប៉ាង គឺមានឈ្មោះ ហែម ជាអ្នកចុះហត្ថលេខា ប៉ុន្តែខ្លួនមិន

ដឹងថាហេតុអ្វីបានជា ហែម ចុះហត្ថលេខានៅលើលិខិតនោះទេ ។ ឌុច បានបញ្ជាក់ថា ហែម គឺឈ្មោះ របស់ខៀវសំផន ។ បន្ទាប់មក សហព្រះរាជអាជ្ញារង លោក វីល្លៀម ស្មីត បានសួរឌុចថាតើប៉ង់ មាននាទីជាអ្វី? ហើយនរណាជាមេកើយផ្ទាល់របស់ ប៉ង់? ។ ឌុច ឆ្លើយថា ប៉ង់ គឺជាប្រធានមន្ទីរស-៧១ និងជានាំពាក្យផ្ទាល់របស់ លេខាបក្ស ប៉ុល ពត និងបញ្ជាក់ថា ប៉ង់ មិនដែលនាំពាក្យ ខៀវ សំផន មកប្រាប់ខ្លួនទេ គឺនាំយកតែពាក្យរបស់ ប៉ុល ពត មកប្រាប់ខ្លួន ប៉ុណ្ណោះ ។ ឌុច បន្តថា ខ្លួនធ្លាប់បានជូន ប៉ង់ ដើរទៅមន្ទីរក-៧ ដែល មានទីតាំងនៅជិតមាត់ទន្លេ ។ នៅមន្ទីរក-៧ ខ្លួនធ្លាប់បានទៅទទួល អ្នកទោសមកពីខាងភូមិភាគឧត្តរ ។ នៅទីនោះខ្លួនឃើញមានទូរស័ព្ទ កណ្តាលមួយដែលខ្លួនយល់ថាវាគឺជាកន្លែងទទួលសំបុត្រពីភូមិភាគ ហើយបញ្ជូនទៅថ្នាក់លើ ។ ប្រធានមន្ទីរក-៧ មានឈ្មោះថា គី ដែល សុន សេន បានណែនាំឲ្យខ្លួនបានស្គាល់ និងមានតំណែងជា ប្រធានមន្ទីរនិរសារ ប៉ុន្តែខ្លួនមិនដឹងថានៅទីនោះមានបុគ្គលិក ធ្វើការប៉ុន្មាននាក់នោះទេ ។

ឌុច បានបញ្ជាក់ថា ខ្លួនធ្លាប់ស្គាល់ សឿ វ៉ាស៊ី ហៅ ឌឿន តាំងតែពីឆ្នាំ១៩៦៧ ប៉ុន្តែក្រោយមកខ្លួនដឹងថា ឌឿន បានក្លាយ ជាប្រធានគណៈមន្ទីរមជ្ឈិម ។ ឌុច បានបន្តថា ដេវីត ឆេនល័រ បានចោទ ខៀវ សំផន ថា ជាមនុស្សថោកទាប ។ ឌុច យល់ថា ខៀវ សំផន មិនមែនជាមនុស្សថោកទាបដូចជាការលើកឡើងរបស់ ឆេនល័រ ទេ ។ ខៀវ សំផន គឺជាមនុស្សថ្លៃថ្នូរ ។ ចំពោះសេចក្តី សម្រេចដែលចេញពីមន្ទីរ៨៧០ ឌុច អះអាងថា មន្ទីរនេះពិតជា ធ្លាប់បានចេញសេចក្តីសម្រេចមែន ប៉ុន្តែមិនមែនក្រោមបង្គាប់ របស់ ខៀវ សំផន ទេ គឺស្ថិតក្រោមការបញ្ជារបស់ ប៉ុល ពត និង នួន ជា តាមរយៈ សុន សេន ។

ឌុច ឆ្លើយតបនឹងសំណួររបស់លោកសហព្រះរាជអាជ្ញារង វីល្លៀម ស្មីត ដោយបំភ្លឺថា អ្នកដែល ស្គាល់ ឌឿន និងខ្សែអនុធន របស់ ឌឿន អាចដឹងថាការចាត់តាំងឲ្យទៅនៅមន្ទីរមជ្ឈិម គឺដើម្បី បំបែក កម្លាំង កុយ ធួនកុំឲ្យនៅប្រមូលផ្តុំគ្នានៅខាងពាណិជ្ជកម្ម ។ ឋានៈរបស់ ឌឿន គឺជាលេខាធិកាដ្ឋានរបស់ ប៉ុល ពត ឯតំណែង របស់ ខៀវ សំផន តាមរយៈការទទួលបានដំណឹងក្រៅផ្លូវការថា ខៀវ សំផន កាន់កាប់ចែកចាយម៉ាស៊ីនទៅឲ្យមូលដ្ឋាន និងជាអ្នក នាំផ្លូវសម្តេច សីហនុ និង ប៉ែន នុត ទៅទស្សនកិច្ចនៅតាម ជនបទ ។ ក្រោយមកពេលដែល ឌឿន ទៅធ្វើការខាងពាណិជ្ជកម្មវិញ ។ ឌុច ជឿថា ជនជាប់ចោទ ខៀវ សំផន នៅតែមានមុខងារដដែល ព្រោះ គ្មាននរណាអាចធ្វើឲ្យប៉ះពាល់ដល់ ខៀវ សំផន បានទេ ។ ឌុចបាន បន្តទៀតថា ឌឿន ជាមនុស្សថ្មី យ៉ាងហោចណាស់ត្រឹមតែជា សមាជិកមជ្ឈិមត្រៀម មិនមានឥទ្ធិពលដល់ ខៀវ សំផន ទេ ហើយ ទោះបីជាតំណែងនៅក្នុងបក្សក៏ ខៀវ សំផន មានឋានៈធំជាងដែរ ។

## ច) ក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យ និងការចាប់ខ្លួនបុគ្គលិក របស់ក្រសួង

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការ បង្កើតក្រសួងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានបញ្ជាក់ ថាក្រសួងដែលត្រូវបានបង្កើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានដូចជា ក្រសួងពាណិជ្ជកម្មរដ្ឋ គ្រប់គ្រងដោយ កុយ ធួន, ក្រសួង ថាមពល គ្រប់គ្រងដោយ ឆាយ គឹមហ៊ា ហៅ ហុក, ក្រសួងសង្គមកិច្ច គ្រប់គ្រងដោយ អៀង ធីរិទ្ធ, ក្រសួងឃោសនាការ គ្រប់គ្រងដោយ ហ៊ូ នឹម, ក្រសួងអប់រំ គ្រប់គ្រងដោយ យុន យាត ។ នៅក្រោយ ពេលមានការចាប់ខ្លួន ហ៊ូ នឹម មក ស-២១ យុន យាត ដែលត្រូវ ជាប្រពន្ធរបស់ សុន សេន បានចូលមកគ្រប់គ្រងទាំងក្រសួង ឃោសនាការ និងអប់រំតែម្តង ។ រីឯក្រសួងឧស្សាហកម្មគឺគ្រប់គ្រង ដោយ ចេង អន ។ ឌុចបញ្ជាក់ថា ការរៀបរាប់នេះប្រហែលជានៅ ខ្វះខាតខ្លះ ។ បន្ទាប់មក ឌុច បានបន្ថែមថា មានក្រសួងការបរទេស មួយទៀតដែលជាក្រសួងមាននាទីធំណាស់ ដែលគ្រប់គ្រងដោយ អៀង សារី ។ ក្រៅពីនោះនៅមានគណៈ កម្មាការផ្សេងៗទៀត ។

បន្ទាប់មកលោកសហព្រះរាជអាជ្ញារង ស្មីត បានស្នើ ឌុច ឲ្យបញ្ជាក់ពីឈ្មោះរបស់មនុស្សមួយចំនួនដែលមាននៅក្នុងឯកសារ ដែលសហព្រះរាជអាជ្ញាបានបង្ហាញនៅលើអេក្រង់កុំព្យូទ័រ ។ លោក ស្មីត បានសួរថាតើនរណាជាសមមិត្តលេខា ។ ឌុច បញ្ជាក់ ថា សមមិត្តលេខាគឺ ប៉ុល ពត រីឯសមមិត្តអនុលេខា គឺ នួន ជា, សមមិត្ត វ៉ាន់គឺ អៀង សារី, សមមិត្ត ហែម គឺ ខៀវ សំផន, សមមិត្ត ធុច គឺ កុយ ធួន, សមមិត្ត ខៀវ គឺ សុន សេន, សមមិត្ត វន ទទួលបន្ទុកខាងឧស្សាហកម្ម អាយស្ម័យយាន គឺ វន វេត, សមមិត្ត ឌឿន ដែលជាប្រធាន ៨៧០ គឺមានឈ្មោះដើម សឿ វ៉ាស៊ី ។ ឌុច

បានបន្ថែមថា មិត្ត ឡឿន ចេញពី៨៧០ទៅពាណិជ្ជកម្មរដ្ឋ ។ សមមិត្ត ភា គឺអៀង ធីរិទ្ធ ដែលជាភរិយារបស់ អៀង សារី ។ សមមិត្ត អាត ដែលទទួលបន្ទុកខាងឃោសនាអប់រំទាំងក្នុង និងក្រៅ គឺ យុន យាត ដែលជា ភរិយារបស់ សុន សេន ។ សមមិត្ត ជ័យ ទទួលបន្ទុកខាងកសិកម្ម គឺ នួន សួន ។ សមមិត្ត យែម ទទួលបន្ទុកនៅការិយាល័យ៨៧០ គឺ សឹម ស៊ុន ។ សមមិត្ត ប៉ង់ ដែលទទួលបន្ទុកខាងមន្ទីររដ្ឋាភិបាល គឺ ឈឹម សំអោក ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការទំនាក់ទំនងរវាងមន្ទីរស-២១ និងក្រសួងផ្សេងៗទៀត ឌុច បំភ្លឺថាស-២១មិនមានទំនាក់ទំនងជាមួយនឹងក្រសួងណាផ្សេងក្រៅពី សុន សេន នួន ជា និង ប៉ង់ ទេ ។ ឌុច បានបញ្ជាក់ថា មានមនុស្សច្រើនដែលត្រូវបានបញ្ជូនមកពីក្រសួងផ្សេងៗ ឲ្យស-២១សួរចម្លើយ និងកម្ទេច ប៉ុន្តែខ្លួនមិនបានចាំច្បាស់ថាអ្នកទាំងនោះមកពីក្រសួងណានោះទេ ប៉ុន្តែខ្លួនគ្រាន់តែដឹងពីព្រឹត្តការណ៍ចាប់ខ្លួន វន វ៉េត ក្រោមការបញ្ជាផ្ទាល់របស់ តាម៉ុក និងព្រឹត្តការណ៍ មួយទៀតគឺខ្លួនទៅទទួលដោយផ្ទាល់ចំពោះការចាប់ខ្លួនប្រពន្ធរបស់ ចេង អន នៅពុទ្ធិកសិក្សាព្រះសុរាម្រិត ។ឌុចបន្តថាវនវ៉េតធ្លាប់ធ្វើជាមេរបស់ខ្លួននៅពេលដែលខ្លួនធ្វើការនៅមន្ទីរម-១៣ ហើយគេចាប់ខ្លួនវនវ៉េតនៅថ្ងៃទី៧ ខែវិច្ឆកា ឆ្នាំ១៩៧៨ ប៉ុន្តែខ្លួនមិនចាំច្បាស់ពីព្រឹត្តិការណ៍នៃការចាប់ខ្លួននោះទេ ដោយគ្រាន់តែបានឃើញគេបញ្ជូន វន វ៉េត និងចេង អន តាមឡានទម្ងន់៥០០គីឡូ មកមន្ទីរស-២១ ។

លោក ស្មិត បានរំឭកសម្ដីរបស់ ឌុច ទាក់ទងនឹងចំនួនអ្នកទោសដែលត្រូវបានចាប់ខ្លួនមកពីកងពលលេខ៨៨៧, ក្រសួងពាណិជ្ជកម្ម, ក្រសួងសង្គមកិច្ច, ទាហានរបស់ លន់ នល់, រណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួមរួបជាតិកម្ពុជា ។ ឌុច បានបញ្ជាក់ថា នៅក្នុងឯកសារចម្លើយសារភាព គឺមានខ្លឹមសារនៃចម្លើយសារភាព ហើយនៅផ្នែកខាងក្រោយបង្អស់នៃចម្លើយសារភាពតែងតែមានឈ្មោះមនុស្សដែលគេឆ្លើយដាក់ និងមានចំនួនច្បាស់លាស់ ។

### ៣) រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន និងយោធា

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការបែងចែកភូមិភាគ ឌុច បានអះអាងថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពិតជាមានការបែងចែកភូមិភាគ ដោយនៅក្នុងឆ្នាំ១៩៧៧ មានការបែងចែកភូមិភាគបន្ថែមមួយទៀត ។ នៅតាមភូមិភាគនីមួយៗមានគណៈអចិន្ត្រៃយ៍របស់ខ្លួនដូចជានៅ ភូមិភាគបូព៌ាមាន សោ ភឹម គណៈអចិន្ត្រៃយ៍ភូមិភាគ ។ នៅក្នុងគណៈអចិន្ត្រៃយ៍ភូមិភាគមានសមាជិកមិន លើសពី៥ នាក់នោះទេ ។ ឌុច អះអាងថា ភូមិភាគនីមួយៗត្រូវបែងចែកជាតំបន់ ហើយនៅក្នុងតំបន់នោះមានគណៈកម្មាធិការរបស់គេ គឺរបស់បក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងតំបន់នីមួយៗត្រូវបែងចែកទៅជាស្រុក ហើយនៅក្នុងស្រុកក៏មានគណៈកម្មាធិការរបស់បក្សចាត់ចែងនិងគ្រប់គ្រងនៅទីនោះ ។ ស្រុកទាំងនោះត្រូវបែងចែកទៅជាអង្គភាពតូចៗបន្ថែមទៀត គឺសហករណ៍ដែលគ្រប់គ្រងដោយគណៈកម្មាធិការ សាខាបក្សសហករណ៍ ។ នៅក្នុងនោះក៏មានកងចល័តដែលគេបង្កើតឡើងដើម្បីលើកទំនប់ និងជីក ប្រឡាយ គ្រប់គ្រងដោយសាខាបក្ស ។ លេខាគណៈកម្មាធិការសហករណ គឺជាបក្ខជន ។ ឌុច អះអាងថា ថ្នាក់ក្រោមត្រូវតែរាយការណ៍ទៅថ្នាក់លើដែលគ្រប់របបនៅទូទាំងបក្សត្រូវតែគោរព និងអនុវត្តន៍គោលការណ៍នេះ ។ ចំពោះសំណួរនេះត្រូវបានក្រុមមេធាវីការពារក្ដី នួន ជា ជំទាស់សាជាថ្មីដោយអះអាងថា សាក្សីមិនអាចដឹងថា តើមានអ្វីកើតឡើងនៅថ្នាក់ស្រុក ឬតំបន់នោះទេ ។ លោកសហព្រះរាជអាជ្ញារង ស្មិត បានឆ្លើយតបថា លោកមិនបានសួរថាតើមានអ្វីកើតឡើងនៅថ្នាក់ស្រុកឬភូមិភាគទេ ប៉ុន្តែលោកគ្រាន់តែសួរសាក្សីពីការរាយការណ៍នៅក្នុងថ្នាក់ទាំងនោះប៉ុណ្ណោះ ព្រោះសាក្សីរូបនេះមានចំណេះដឹងច្រើនពីបញ្ហានេះ និងធ្លាប់បានបង្រៀននៅក្នុងវគ្គរៀនសូត្រដែរ ។ ជាថ្មីម្ដងទៀត ការជំទាស់របស់ក្រុមមេធាវីការពារក្ដី នួន ជា ត្រូវបានបដិសេធ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្តសំណួររបស់ខ្លួន ។

លោក ស្មិត បានបន្តសួរ ឌុច ពីការរាយការណ៍របស់គណៈកម្មាធិការនៅតាមថ្នាក់នីមួយៗ ។ បន្ទាប់មកលោកបានសួរ ឌុច ពីការបែងចែករចនាសម្ព័ន្ធរបស់គណៈអចិន្ត្រៃយ៍ដែលមានបួន ។ ឌុច ថា គណៈអចិន្ត្រៃយ៍មានអំណាចខ្លាំងជាងគេ ។ ទាក់ទងនឹងសំណួរដែលថាតើមានគោលការណ៍ថ្នាក់លើមានការរាយការណ៍

មកថ្នាក់ក្រោមដែលឬទេ ។ឌុច បញ្ជាក់ថា ថ្នាក់លើរាយការណ៍មកថ្នាក់ក្រោម គឺមានរូបភាពរបស់វាដូចជាការណែនាំពីសភាពការណ៍លន់ទល់ ឈ្នះនៅឆ្នាំណា ហើយរលំនៅឆ្នាំណាជា ដើម ។

ទាក់ទងនឹងការគោលការណ៍សម្រេចកម្មេច ឌុច អះអាងថា ចាប់តាំងពីឆ្នាំ១៩៧១មក បើស្ថិតនៅក្នុងភូមិភាគណា គណៈអចិន្ត្រៃយ៍ភូមិភាគនោះគឺជាអ្នកសម្រេច ។ រីឯគណៈមន្ទីរមជ្ឈិមគឺសំដៅអ្នកដែលជួយការងារលេខា និងអនុលេខាផ្ទាល់ទៅតាមមុខសញ្ញានីមួយៗ ។ គណៈមន្ទីរមជ្ឈិម ឌុច អះអាងថា ខ្លួនមិនអាចពន្យល់ឲ្យបំ និងត្រឹមត្រូវទេ ព្រោះនៅឆ្ងាយពីខ្លួនពេក ប៉ុន្តែជាទ្រឹស្តីគឺមានតែលេខាគណៈមជ្ឈិមទេដែលអាចសម្រេចបាន ។ ទាក់ទងនឹងពាក្យថា តំបន់ឯករាជ្យ ឌុច បានឆ្លើយតបទៅសហព្រះរាជអាជ្ញាថា គឺឡើងទៅផ្ទាល់ទៅដល់ថ្នាក់កំពូលតែម្តងដោយមិនចាំបាច់ឆ្លងកាត់ថ្នាក់កណ្តាល ។ តំបន់ឯករាជ្យ រួមមានសៀមរាបក្រចេះ(តំបន់៥០៥) និងកំពង់សោម ។ស-២១ គឺជាវរៈសេនាធំឯករាជ្យមួយ និងស្ថិតនៅក្នុងរចនាសម្ព័ន្ធយោធាមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានអះអាងថា ស-២១ គឺមានឯករាជ្យទាក់ទងនឹងចម្លើយសារភាពរបស់អ្នកទោស ដោយមិនស្ថិតនៅក្រោមសេនាធិការយោធាឡើយ ។ ឌុច បញ្ជាក់ថា ទីតាំងសេនាធិការយោធា គឺនៅខាងជើងបុរីកីឡាប្រហែលជាពីរផ្លូវ ។ ក្រៅពីសុន សេន ដែលជាអគ្គសេនាធិការ គឺមាន ម៉ែន សាន ហៅ យ៉ា និងសៀត ឆែ ហៅ ទុំ ក្រោយមកអ្នកទាំងពីរនាក់នេះត្រូវបានចាប់ខ្លួនមក ស-២១ និងត្រូវបានសម្លាប់ចោលនៅទីនោះ ។

ទាក់ទងនឹងរចនាសម្ព័ន្ធកងទ័ព ឌុច បានអះអាងថា កងទ័ពត្រូវបានបែងចែកទៅជាឈ្នួបតំបន់ និងស្រុក ។ នៅមុនឆ្នាំ១៩៧៥ រចនាសម្ព័ន្ធកងទ័ព គឺស្ថិតនៅក្រោមការបញ្ជាផ្ទាល់ដោយលេខាភូមិភាគ ប៉ុន្តែស្ថិតនៅក្រោមការបញ្ជាផ្តាច់មុខរបស់លេខា និងអនុលេខាបក្ស គឺ ប៉ុល ពត និង នួន ជា ។ ក្រោយឆ្នាំ១៩៧៥ កងពលមួយចំនួនត្រូវបានគ្រប់គ្រងដោយភូមិភាគ ហើយមួយចំនួនត្រូវបានគ្រប់គ្រងដោយអគ្គសេនាធិការ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងចំនួនរបស់កងពល ឌុច បាន បញ្ជាក់ថាមិនបានចាំចំនួនជាក់លាក់នោះទេ ប៉ុន្តែខ្លួនអាចរាប់ចំនួនកងពលដែលខ្លួនធ្លាប់បានដឹងជូនសហព្រះ រាជអាជ្ញាបាន ។ កងពលដែលឌុច បានរៀបរាប់មានដូចជាកងពលលេខ១៧០ និងកងពលលេខ២៩០ មានទីតាំងស្ថិតនៅភូមិភាគបូព៌ា, កងពលលេខ៣១០ កងពលលេខ៤៥០ និងកងពលលេខ៩២០ មានទីតាំងស្ថិតនៅក្នុងភូមិភាគឧត្តរ, កងពលលេខ៨០១ និងកងពលលេខ១៦៤ មានទីតាំងស្ថិតនៅភូមិភាគនិរតី, កងពលលេខ៥០២នៅភូមិភាគនិរតីចាស់ និងកងពល៧០៣ ដែលជាកងទ័ពរបស់មជ្ឈិម ។

ទាក់ទងនឹងការប្រជុំជាមួយនឹងសេនាធិការយោធា ឌុច បានបញ្ជាក់ថាខ្លួនធ្លាប់បានចូលរួមប្រជុំជាមួយនឹងសេនាធិការយោធាដែលកំណត់ហេតុនៃការប្រជុំនោះក៏មាននៅសល់ដែរ ។ ឌុច និយាយថាក្នុងចំណោមអ្នកទោសជាងមួយម៉ឺនពីរពាន់នាក់ មានអ្នកទោសដែលស្ថិតនៅក្នុងជួរកងទ័ពជាងប្រាំពាន់នាក់ត្រូវបានចាប់ខ្លួនបញ្ជូនមកស-២១ ហើយសម្លាប់ចោល គឺដោយសារមូលហេតុចោទថាក្បត់បក្ស ។

ឌុច បានបញ្ជាក់ថា អគ្គសេនាធិការកងទ័ព គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត និង នួន ជា ដោយអះអាងថា លេខាបក្សគឺគ្រប់គ្រងផ្នែកយោធា និងសេដ្ឋកិច្ច ហើយអនុលេខាគឺគ្រប់គ្រងកិច្ចការរបស់បក្ស ។ឌុច បានលើកឡើងពីលក្ខន្តិកៈរបស់បក្សឆ្នាំ១៩៧១ ដែលចែងថាកងទ័ពគឺជាកូន និងជិតបំផុតរបស់បក្ស ។ ដូច្នេះកងទ័ពគឺគ្រប់គ្រងដោយបក្ស ។

### ២.២.៣) ប្រព័ន្ធទំនាក់ទំនងការងារ

ពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ លោកសហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានសួរដេញដោលសាក្សី ឌុច ដោយផ្តោតលើប្រព័ន្ធរាយការណ៍, ទំនាក់ទំនងរវាង ឌុច និងថ្នាក់លើ, ការចេញបញ្ជា, និងការធ្វើចំណារ ។

#### *ក) លក្ខខណ្ឌនៃប្រព័ន្ធរាយការណ៍*

យោងតាមសក្ខីកម្មរបស់ ឌុច ការរាយការណ៍របស់បក្សកុម្មុយនីស្ត គឺធ្វើឡើងពីថ្នាក់តូចទៅថ្នាក់ធំតាមលំដាប់ ។ គណៈកម្មាធិការបក្សថ្នាក់ មានគណៈកម្មាធិការបក្សថ្នាក់សាខា ថ្នាក់សហករណ៍ ថ្នាក់ស្រុក ថ្នាក់តំបន់ថ្នាក់ភូមិភាគ ។ចំណែកនៅក្នុងផ្នែកកងទ័ពមានគណៈកម្មាធិការថ្នាក់កងអនុសេនាធំ ថ្នាក់វរៈសេនាតូច វរៈសេនាធំ ថ្នាក់កងពល និងថ្នាក់អគ្គសេនាធិការ ។ នៅលើគណៈកម្មាធិការថ្នាក់ភូមិភាគមាន គណៈកម្មាធិការអចិន្ត្រៃយ៍

បក្ស ។ ចំណែកគណៈកម្មាធិការមជ្ឈិមគឺរួមទាំងគណៈកម្មាធិការអចិន្ត្រៃយ៍ដែរ បន្ទាប់មកមានគណៈកម្មាធិការមជ្ឈិមពេញសិទ្ធថ្នាក់មជ្ឈិមត្រៀម និងថ្នាក់ជំនួយការមជ្ឈិម ។ ចំពោះលក្ខខណ្ឌនៃប្រព័ន្ធរាយការណ៍ គឺថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើបន្ទាប់របស់ខ្លួនដែលរាយការណ៍អំពីសភាពការណ៍ និងកិច្ចការដែលខ្លួនបានធ្វើ ។ តាមចម្លើយរបស់ ឌុច សភាពការណ៍សំដៅទៅលក្ខណៈសម្បត្តិសម្ភារដែលកើតមានឡើងនៅក្នុងការកិច្ចរបស់យើង ។ ឧទាហរណ៍នៅមន្ទីរស-២១ ក្នុងមួយថ្ងៃគេបញ្ជូនមនុស្សមកពីណាប៉ុន្មាននាក់នេះ ហៅថាសភាពការណ៍ ។ ចំណែកកិច្ចការគឺជាការងារប្រចាំថ្ងៃ ។ ឧទាហរណ៍ក្នុងមួយថ្ងៃនេះទទួលបានឯកសារល្អប៉ុន្មានដែលត្រូវរាយការណ៍ជូនបក្ស នេះហៅថាកិច្ចការ ។ នៅក្នុងកងវរៈស-២១ គឺអនុវត្តការរាយការណ៍ពីថ្នាក់តូចទៅថ្នាក់លើដែរ ។ សាក្សី ឌុច ដែលជាអតីតប្រធានមន្ទីរស-២១រាយការណ៍ទៅ សុន សេន ផ្ទាល់ក្នុងរយៈពេលបីថ្ងៃម្តង ដែលពេលខ្លះបួនថ្ងៃម្តង ។ សុន សេន តាមដានការងារជាប់រៀងរាល់ថ្ងៃ គឺតែងតែទាក់ទងតាមរយៈទូរស័ព្ទមក ឌុច និងសន្ទនាគ្នាប្រហែលជាមួយម៉ោងក្នុងមួយថ្ងៃ ឬលើសពីនេះ ។ ដោយឡែកឯកសារណាសំខាន់ និង ចាំបាច់ គឺ សុន សេន បញ្ជូននិរសារឲ្យមកយកភ្លាមៗ ។ ក្រោយមកនៅពេល នួន ជា គ្រប់គ្រងមន្ទីរស-២១ បន្តពី សុន សេន ការរាយការណ៍ទៅ នួន ជា ធ្វើឡើងក្នុងរយៈពេលបីថ្ងៃដែរ ឬយ៉ាងយូរប្រាំថ្ងៃម្តង ។ ដោយសារ នួន ជា មិនប្រើទូរស័ព្ទដូចនេះតម្រូវឲ្យ ឌុច ត្រូវទៅជួបផ្ទាល់ ។ ឌុច បានរៀបរាប់ថា នៅមន្ទីរស-២១ឯកសារសំខាន់ឬអត់ គឺអាស្រ័យលើចម្លើយសារភាពរបស់អ្នកទោស ។ ការរាយការណ៍ធ្វើឡើងតាមរយៈព័ត៌មានពីរប្រភេទ គឺទី១ ព័ត៌មានផ្ទៃក្នុងអង្គភាពស-២១ទាំងមូល ។ ថ្នាក់ក្រោមរាយការណ៍រហូតជាខ្សែសង្វាក់មកប្រមូលផ្តុំគ្នាទៅមិត្ត ហ៊ឹរ ។ មិត្ត ហ៊ឹរ ប្រមូលផ្តុំគ្នារួចរាយការណ៍មកឲ្យឌុចផ្ទាល់ ។ រហូតដល់ពេលវេលាណាមួយសមស្រប ឌុច រាយការណ៍ទៅថ្នាក់លើ ។ ទី២ ព័ត៌មានជាចម្លើយសារភាព គឺត្រូវផ្តល់ឲ្យ ឌុច នៅពេលណាដែលបញ្ចប់ការសួរចម្លើយអ្នកទោសម្នាក់ៗ ។ ឌុច ត្រូវអាន ពិនិត្យ និងក្រោយមកត្រូវសង្ខេបជាសេចក្តីសង្ខេបខ្លីៗងាយស្រួលស្តាប់ដើម្បីប្រគល់ជូនទៅថ្នាក់លើ ។ ចំពោះការរាយការណ៍ ឬការងារទាក់ទងនឹងផ្នែកភស្តុភារ និងផ្សេងទៀត គឺត្រូវទាក់ទងមក ឌុច និងខាងគណៈកម្មាការសេនាធិការដែលមានជំនួយការនៅមន្ទីរស-២១ ។

### ១) ការទំនាក់ទំនងរវាង ឌុច និងថ្នាក់លើ

ចំពោះសំណួរពាក់ព័ន្ធនឹងទំនាក់ទំនងរវាង ឌុច និង សុន សេន នៅពេលដែល ឌុច មានតួនាទីជាប្រធានស-២១ ឌុច បានឆ្លើយថាខ្លួនធ្លាប់បានជួបប្រជុំជាមួយ សុន សេន ជាញឹកញាប់ដើម្បីរាយការណ៍ និងពេលខ្លះ សុន សេន ហៅ ឌុច ទៅប្រជុំ ហើយ សុន សេន ជាអ្នកកំណត់របៀបវារៈនៅក្នុងកិច្ចប្រជុំនោះ ។ បន្ទាប់មកលោកសហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានសួរបន្តថា តើនៅពេលណាដែល នួន ជា ចូលមកជំនួសតំណែងដោយផ្ទាល់នៅស-២១ និងថានៅពេលណាដែល ឌុច រាយការណ៍ដោយផ្ទាល់ទៅ នួន ជា ។ ឌុច ឆ្លើយថា នៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ នួន ជា បានបញ្ជាឲ្យគេហៅខ្លួនទៅជួបនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។ នៅពេលទៅដល់ នួន ជា បានប្រាប់ថាមិត្ត ខៀវ (សុន សេន) ចេញទៅសមរភូមិ ហើយខ្លួននឹងជំនួសតំណែងរបស់មិត្ត ខៀវ ។ ឌុច បញ្ជាក់ថាខ្លួនបានចាប់ផ្តើមរាយការណ៍ទៅ នួន ជា ចាប់តាំងពីពេលនោះមក ។ នៅពេលសួរដល់សំណួរនេះ លោកមេធាវី ម៉ៃឃើល ផេស្តមេន បានក្រោកឡើងជំទាស់នឹងការសួរសំណួររបស់សហព្រះរាជអាជ្ញា ដោយអះអាងថាសហព្រះរាជអាជ្ញាបានសួរលើសពីវិសាលភាពនៃសវនាការដែលអង្គជំនុំជម្រះបានកំណត់ ព្រោះសំណួររបស់សហព្រះរាជអាជ្ញាបានសួរហាក់បីដូចជាចូលទៅការទទួលខុសត្រូវរបស់កូនក្តីរបស់ខ្លួននៅក្រោយឆ្នាំ១៩៧៧ ឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ ដែលអាចបង្កព្យសនកម្មដល់កូនក្តីរបស់ខ្លួន និងស្នើថា សហព្រះរាជអាជ្ញាគួរតែសួរសំណួរណាដែលទាក់ទងនឹងអង្គហេតុជាក់ស្តែងដូចជាចលនាជម្លៀសប្រជាជននៅឆ្នាំ១៩៧៥ ទៅភូមិភាគឧត្តរ និងត្រូវមានការប្រុងប្រយ័ត្នចំពោះការពិភាក្សាពីរចនាសម្ព័ន្ធក្រោយដំណាក់បឋម ។ ម៉្យាងវិញទៀត ការសួរ ឌុច អំពីស-២១ គឺមិនមានជាប់ពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងទេ ហើយបើចង់សួរ ឌុច អំពីស-២១ សហព្រះរាជអាជ្ញាគួរតែរង់ចាំសួរនៅក្នុងសវនាការដោយឡែកទាក់ទងនឹងស-២១ តែម្តង ។

ឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា

លោកសហព្រះរាជអាជ្ញារង ស្មីត បានលើកឡើងថា ដោយយោង លើដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ និងដីកាដំណោះស្រាយ និងអះអាងថា លោកបានសួរសំណួរដោយផ្អែក លើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ម៉្យាង វិញទៀត ក្រុមមេធាវីការពារក្តី នួន ជា ប្រហែលជាមានការភាន់ ច្រឡំទាក់ទងនឹងអង្គហេតុនៃការជម្លៀស ដោយហេតុថាអង្គហេតុ ទាក់ទងនឹងការជន្លៀសមានរហូតទៅដល់បីដំណាក់កាល ដែលធ្វើ ឡើងនៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មិនមែនតែនៅក្នុងឆ្នាំ ១៩៧៥ដូចជាការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា នោះទេ ។ អង្គជំនុំជម្រះបានបដិសេធការជំទាស់របស់ក្រុមមេធាវី ការពារក្តី នួន ជា និងតម្រូវសហព្រះរាជអាជ្ញាត្រូវសួរសំណួរ ដោយប្រុងប្រយ័ត្ន ដើម្បីកុំឲ្យចេញពីអ្វីដែលអង្គជំនុំជម្រះបាន កំណត់ ។

បន្ទាប់មកលោក ស្មីត បានបន្តសួរ ឌុច ទៀតថាតើហេតុអ្វី បានជា ឌុច ចងចាំពីថ្ងៃដែល នួន ជា ចូលមកគ្រប់គ្រងខ្លួនច្បាស់ ម៉្លេះ ។ ឌុច ឆ្លើយថា ដោយសារតែ នួន ជា មានតួនាទីធំជាង សុន សេន ដូច្នេះខ្លួនរំភើបដែលបានធ្វើការជាមួយ នួន ជា ហើយបាន កត់ត្រាទុកនូវថ្ងៃខែដែលខ្លួនបានជួប នួន ជា ក្នុងកំណត់ត្រារបស់ ខ្លួន ។ ឌុច បានរំឭកអំពីការជួបគ្នាជាមួយ នួន ជា នៅពុទ្ធិសិក្សា ព្រះសុរាម្រិត គឺជួបតែពីរនាក់ ដោយពិភាក្សាពីបាតុភាពសេរីនៅ ក្នុងអង្គភាព និងសេរីដើរហើររបស់កម្មាភិបាល ។ ឌុចបន្ថែមថា ការជួបប្រជុំនេះ គឺជាទូទៅធ្វើឡើងក្នុងរយៈពេល៣ថ្ងៃម្តង ប៉ុន្តែ ក្រោយពេល នួន ជា ទៅប្រទេសចិន សមមិត្ត ប៉ង់ ដែលជាអ្នកនាំ ពាក្យផ្ទាល់របស់ ប៉ុលពត ជាអ្នកមកទាក់ទង ឌុច ។ ក្រោយពី នួន ជា ត្រឡប់ពីប្រទេសចិនវិញ ការជួបប្រជុំនេះត្រូវបានធ្វើឡើងប្រហែល ជាប្រាំថ្ងៃម្តង ។ ឌុច បានអះអាងថា នៅពេលមួយនោះ នួន ជា បានសួរ ឌុច ថា "តើមិត្តធ្វើអ្វីប៉ុន្មានថ្ងៃនេះ បានជាមិនឃើញមានអ្វី រាយការណ៍" ឌុច បញ្ជាក់ថា នៅពេលនោះខ្លួនពិតជាមិនមានអ្វីត្រូវ រាយការណ៍ទៅ នួន ជា ដោយសារតែខ្លួនមិនមានអារម្មណ៍ដើម្បី ធ្វើការងារ ព្រោះខ្លួនបានឃើញនៅក្នុងចម្លើយសារភាពមានការ ឆ្លើយដាក់ចំពោះកម្មាភិបាលកាន់តែខ្ពស់ទៅៗ ។ ឌុច បានលើក ឧទាហរណ៍ចំពោះចម្លើយសារភាពមួយដែលបានឆ្លើយដាក់ឈ្មោះ មិញ ដែលត្រូវជាកូនបង្កើតរបស់ អៀង សារី និងឈ្មោះ ពឿន ជា កូនប្រសាររបស់ អៀង សារី និងក្រោយមកទៀតមានការឆ្លើយ ដាក់ ខៀវ សំផន ថាជាអ្នកដឹកនាំខាងផ្លូវក្បត់ថែមទៀតផង ។ ឌុច បានបន្តថា ក្រោយពីបានឮការរាយការណ៍របស់ខ្លួនដូច្នេះ នួន ជា បានឆ្លើយតបមកវិញថា "មិត្ត! មួយស្រុកខ្មែរនៅសល់តែខ្ញុំនិងបង ប៉ុលមួយទេ មិត្តចង់ទៅធ្វើទូតទេ? " លោកសហព្រះរាជអាជ្ញារង បានស្នើឲ្យ ឌុច ពន្យល់ចំពោះពាក្យដែល នួន ជា និយាយថាចង់ បញ្ជូន ឌុច ឲ្យទៅធ្វើទូត ។ ឌុច បានឆ្លើយតបដោយលើកឧទាហរណ៍ ពីករណីរបស់ ណាត ដែលមុនដំបូងធ្លាប់ធ្វើការនៅខាងផ្នែកយោធា ប៉ុន្តែក្រោយមកគេដកយកទៅធ្វើខាងទូត ករណីរបស់ កែ គឹមហួត មុនដំបូងធ្វើការជាលេខាតំបន់មួយនៅខាងភូមិភាគពាយ័ព្យ ប៉ុន្តែក្រោយមកត្រូវបានគេដកយកមកធ្វើទូត ករណីរបស់ឈ្មោះ ឆាយ គឹមហ៊ រ ពីដើមធ្វើការនៅខាងថាមពល ក្រោយមកក៏ត្រូវបាន ដកយកមកធ្វើទូត ។ ដូច្នេះពាក្យថាធ្វើទូត គឺត្រៀមខ្លួនសម្រាប់ ឲ្យអ្នកដែលគេដកយកមកធ្វើទូតនោះ មានលទ្ធភាពចូលមកស-២១ ទោះយូរឬឆាប់ ដើម្បីកុំឲ្យអ្នកទាំងនោះទៅបំផ្លាញកម្លាំង ឬផែនការ របស់គេ ។ ឌុច បន្ថែមថា នៅពេលដែល នួន ជា និយាយដូច្នេះ ជាមួយខ្លួន នួន ជា ក៏ដកខ្លួនថយបន្តិចទៅវិញ ដោយនិយាយថា "ហ្អើយ! វាមិនទៅស្អីទេ ធ្វើទូតក៏វាសប្បាយដែរ" ។ លោកសហ ព្រះរាជអាជ្ញាបានបន្តសួរថា តើមានអ្វីកើតឡើងចំពោះអ្នកដែល គេចង់បញ្ជូនឲ្យទៅធ្វើទូតនោះ? ឌុច បានបញ្ជាក់ថា ណាត ភ័យខ្លួន ចាប់តាំងពីអង្គការដកខ្លួនចេញពីស-២១ម៉្លេះ ។ នៅស-២១ ណាត មានកម្លាំងកាន់កាប់មួយវរៈសេនាធំ នៅពេលដកចេញពី ស-២១ឲ្យទៅធ្វើការជាជំនួយការមជ្ឈិម ណាត អស់មានកម្លាំង ក្តាប់ ។ ដូច្នេះអ្នកណាដែលមិនមានកម្លាំងក្តាប់ គឺមានន័យថាបក្ស លែងជឿទុកចិត្តហើយ ។ ឌុច បញ្ជាក់ថា ក្រសួងការបរទេសនៃ របបកម្ពុជាប្រជាធិបតេយ្យ គឺជាអ្នកអនុវត្តគោលនយោបាយ ការទូតនៃបក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បន្តថា ទូត គឺជាមនុស្សដែល ក្រសួងការបរទេសចាត់តាំងឲ្យចេញទៅតំណាងរបបកម្ពុជាប្រជា ធិបតេយ្យ ប៉ុន្តែនៅពេលនោះគេយកមនុស្សខ្លះដែលគេមិនឲ្យក្តាប់ កម្លាំង គេមិនទុកចិត្ត ប៉ុន្តែមិនទាន់មានឯកសារគ្រប់គ្រាន់ដើម្បី ចាប់ខ្លួន គេបញ្ជូនអ្នកនោះឲ្យទៅធ្វើទូត ។ ហេតុនេះ ទូតដែលគេ

បញ្ចេញទៅក្រៅប្រទេស និងទូតដែលគេចាត់តាំងដើម្បីយកមកដាក់ទណ្ឌកម្មគឺខុសគ្នា ។ ឌុច និយាយថា អ្នកធ្វើទូត មានពីរប្រភេទ គឺអ្នកការទូតមែនទែន និងអ្នកដែលគេដកតំណែង ។ ឌុច បានលើកឧទាហរណ៍ពីអ្នកដែលបក្សបានបញ្ជូនឲ្យទៅធ្វើទូតពិតប្រាកដចំនួនពីរនាក់ដែលខ្លួនបានស្គាល់ដូចជាឈ្មោះ ពេជ ជាង ជាអ្នកការទូតនៅប្រទេសចិន និងឈ្មោះ សឹម ស៊ុន ជាអ្នកការទូតប្រចាំនៅកូរ៉េខាងជើង ។ បន្ទាប់មក ឌុច បានរៀបរាប់ឈ្មោះរបស់ អ្នកដែលគេចាប់មកស-២១ដែលគេថាបញ្ជូនទៅធ្វើទូត រួមមាន សុន ទី ហៅ ទាញ, កែ គឹមហួត ហៅ មន ហៅ សុទ្ធ, អ៊ិន លន ហៅ ណាត, ឆាយ គឹមហ៊័រ ហៅ ហុក និងមានអ្នកផ្សេងមួយចំនួនទៀតដែល ឌុច ចាំមិនច្បាស់លាស់ ។ ឌុច អះអាងថា មេធំផ្នែកការទូតគឺ អៀង សារី ដែលជាឧបនាយករដ្ឋមន្ត្រីទី១ ។

ត្រឡប់មកប្រធានបទទាក់ទងនឹងការប្រជុំជាមួយនឹង នួន ជា វិញ ឌុច បានបញ្ជាក់ថា គោលបំណងចម្បងនៃការប្រជុំជាមួយ នួន ជា គឺដើម្បីក្តាប់សភាពការណ៍អ្នកដែល នួន ជា ចាប់អារម្មណ៍ដើម្បីស្តាប់ចម្លើយនិងក្តាប់សភាពការណ៍នៅស-២១ ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការដឹងឮពីអត្ថិភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ ឌុច និយាយថា ខ្លួនបានឮឈ្មោះកម្ពុជាប្រជាធិបតេយ្យនៅក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺឮតាមរយៈវិទ្យុ និងការប្រជុំនានា ។ ចំពោះមាត្រានៃរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ឌុច អះអាងថា ខ្លួនមិនដែលបានរៀនទេ គឺគ្រាន់តែឮតាមរយៈវិទ្យុ និងការសម្តែងល្ខោនតែប៉ុណ្ណោះ ។ ឌុច អះអាងថា ខ្លួនមិនច្បាស់ទេថាតើអ្នកណាជាអ្នកសរសេររដ្ឋធម្មនុញ្ញនោះ ប៉ុន្តែបើស្មានមិនខុសទេ គឺបងធំទី១ ប៉ុល ពត ជាអ្នកផ្តួចផ្តើមគំនិតសរសេររដ្ឋធម្មនុញ្ញ ។ ភ្លាមៗនោះ លោកមេធាវី ម៉ៃឃើល ផេស្តមេន បានជំទាស់នឹងសំណួរដូច្នេះរបស់សហព្រះរាជអាជ្ញា ដោយអះអាងថា សំណួររបស់សហព្រះរាជអាជ្ញាបានចាត់ទុក ឌុច ដូចជាអ្នកជំនាញមួយរូបដែលសន្និដ្ឋានថានរណាគឺជាអ្នកសរសេររដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកមេធាវីបានបន្តថា ឌុច បាននិយាយរួចហើយថាខ្លួនគ្រាន់តែបានឮការនិយាយពីរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យតាមរយៈវិទ្យុប៉ុណ្ណោះ ។ ប៉ុន្តែការជំទាស់នេះត្រូវបានបដិសេធដោយអង្គជំនុំជម្រះ ។

### ក) ការបញ្ជាក់កម្ទេចអ្នកទោសនៅស-២១ មុនការចូលមកដល់នៃកងទ័ពវៀតណាម

ឌុច បានបន្តថា ប្រហែលនៅថ្ងៃទី១ ឬទី២ ខែមករា ឆ្នាំ១៩៧៩ នួន ជា បានបង្គាប់ឲ្យខ្លួនកម្ទេចអ្នកទោសទាំងអស់ដែលមានចំនួនប្រហែលលើសពី៥០០នាក់ ។ ចំណែករឿងឯកសារ បង នួនមិនបានណែនាំទេ ។ នៅពេលទទួលដំណឹងភ្លាម ឌុច បានហៅមិត្ត ហ៊ីរ មកប្រាប់ភ្លាម ។ បីថ្ងៃក្រោយមក មិត្តហ៊ីរ ផ្តល់ដំណឹងមកវិញថាភារកិច្ចបានអនុវត្តន៍ចប់សព្វគ្រប់ហើយ ។ សហព្រះរាជអាជ្ញាបានសួរដេញដោលទៅសាក្សីអំពីព្រឹត្តការណ៍នៃការចាកចេញពីមន្ទីរស-២១ថាតើបានកម្ទេចឯកសារនៅទីនោះចោលដែរទេ? ឌុច បានរៀបរាប់ថា នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្លួនបានចាកចេញពីមន្ទីរស-២១ នៅពេលរថក្រោះបានមកដល់ខាងមុខផ្ទះ ។ ឌុច រៀបរាប់ថា ខ្លួនមិនបាននាំយកអ្វីជាប់តាមខ្លួនទាល់តែសោះ សូម្បីតែស្បែកជើង គឺមានតែស្លាបប៉ាកាមួយ និងកាំភ្លើងខ្លីមួយដើមប៉ុណ្ណោះ ។ ឌុច ជឿថាមិនមាននរណាម្នាក់នៅក្នុងអង្គភាពរបស់ខ្លួនអាចយកអ្វីចេញបានទេ ហើយឯកសារទាំងអស់គឺនៅទីនោះដដែល ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការបង្គាប់ឲ្យបំផ្លាញឯកសារដោយ នួន ជា ឌុចបានរំឭកពីព្រឹត្តការណ៍កើតឡើងនៅអំឡុងឆ្នាំ១៩៨៣ ថាៈ

“បងនួនគាត់អញ្ជើញចុះទៅប្រចាំការនៅសមរភូមិសំឡូត ។ ថ្ងៃមួយគាត់ហៅខ្ញុំឲ្យទៅជួប ។ គាត់ថាថ្ងៃរៀបចេញហ្នឹង មិត្តអត់បានជួបធ្វើការជាមួយខ្ញុំ មិត្តជួបធ្វើការជាមួយអ៊ំហែម? ខ្ញុំឆ្លើយថា បាទ កាលហ្នឹងគេលែងហៅបងហើយ គេហៅអ៊ំ ។ អ៊ំ ហែមហ្នឹងសាធារណជនស្គាល់ហើយតុលាការក៏ស្គាល់ដែរគឺបងខៀវសំផន ។ រួចចុះឯកសារមិត្ត? ខ្ញុំថាឯកសារនៅសាម៉ាមប៉ាកអញ្ចឹងបង ។ នែ៎!ខាងខ្ញុំកម្ទេចខ្ទេចអស់ហើយណា.....មិត្តអន់ណាស់ប៉ុណ្ណឹងក៏មិនម្ចាស់ការ ។ ហ្នឹង! ភាសាគាត់ ដូច្នេះខ្ញុំនិយាយនេះអាចខុសមួយម៉ាត់ ឬពីរម៉ាត់ប៉ុណ្ណោះពីភាសាដើម ។ ហើយខ្ញុំសូមរំឭកទៅមុខបន្តិចទៀតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៦ ខ្ញុំទៅជួបមេខ្ញុំ សុន សេន ខ្ញុំរាយការណ៍រឿងទាំងអស់នេះ ។ បង សុន សេន គាត់ថា

ហ៊ឹស! ចាំតែអស់ចុះ ។ នេះនិយាយពីឯកសារខាងមជ្ឈិមនេះ សូមរាយការណ៍ពីឯកសារតាមដំណើរវិវត្តក្រោយឆ្នាំ១៩៧៩» ។

ឌុច បានជម្រាបជូនអង្គជំនុំជម្រះពីអត្តចរិករបស់ នួន ជា ថាមិនទទួលស្គាល់ពីចំណុចខ្សោយរបស់ខ្លួនទេ គឺច្រើនតែសង្គ្រប់អ្នកខាងក្រោម ។

## ឃ) ការធ្វើចំណារ

បន្ទាប់មកលោកសហព្រះរាជអាជ្ញារង ស្មិត បានបង្ហាញឯកសារចម្លើយសារភាពមួយដល់ ឌុច ដើម្បីធ្វើការបញ្ជាក់អំពីចំណារលើចម្លើយសារភាពនោះថាតើនរណាជាអ្នកធ្វើចំណារនោះ ។ ឌុច បាន បញ្ជាក់ថា ចំណារលើចម្លើយសារភាពដែលសហព្រះរាជអាជ្ញាបានបង្ហាញ គឺជាចំណាររបស់ នួន ជា ។ ឌុចបន្ថែមថាការដែលខ្លួនអះអាងថាអក្សរដែលចារនៅលើចម្លើយសារភាពជារបស់ នួនជា ដោយសារតែខ្លួនធ្លាប់បានឃើញអក្សររបស់ នួនជា ។ បន្ទាប់មកសហព្រះរាជអាជ្ញាបានសួរ ឌុច អំពីពាក្យថា "ដោះស្រាយរួចហើយ" ដែលមានសរសេរនៅលើចម្លើយសារភាពនោះមានន័យដូចម្តេច ។ ឌុច បំភ្លឺថា ពាក្យនេះនៅក្នុងសម័យដែលខ្លួនធ្វើការនៅមន្ទីរម-១៣ គឺមានន័យថា គេបានយកទៅកម្ទេចរួចហើយ ។ ប៉ុន្តែពាក្យដែលប្រើនៅក្នុងចម្លើយសារភាព គឺមានន័យថា បក្សបានសម្រេចបញ្ជូនគេឲ្យទៅចាប់ខ្លួនរួចហើយ ។

បន្ទាប់មកសហព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយទៀតដោយស្នើឲ្យ ឌុច ធ្វើការបញ្ជាក់អំពី ថាតើចំណារដែលមានលើចម្លើយសារភាពជារបស់នរណា ។ជាថ្មីម្តងទៀត ឌុច បានបញ្ជាក់ថា ចំណារលើចម្លើយសារភាពគឺជារបស់ "បង នួន ជា របស់ខ្ញុំ" ។ សហព្រះរាជអាជ្ញាបានសួរបញ្ជាក់ ឌុច ថា ហេតុអ្វីបានជា ឌុច អះអាងថា ចំណារនោះជារបស់ នួន ជា? ឌុច បញ្ជាក់ថា មូលហេតុដែលខ្លួនអះអាងដូច្នេះ គឺដោយសារនៅលើចម្លើយសារភាពនោះមានចំណារមួយឃ្លាដែលសរសេរថា "ជូនទៅសមមិត្តវ៉ាន់" (អៀង សារី) ដែលខ្លួនយល់ថា មានតែ នួន ជា ម្នាក់ប៉ុណ្ណោះដែលហ៊ានហៅ អៀង សារី ថា សមមិត្ត វ៉ាន់ និងថាប្រសិនបើ សុន សេន វិញ គឺសរសេរថា "ជូនចំពោះបងវ៉ាន់" ។ ភ្លាមៗនោះ មេធាវីអន្តរជាតិការពារក្តី អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស់ បានក្រោកឡើងជំទាស់នឹងការសួរសំណួររបស់សហព្រះរាជអាជ្ញា ដោយអះអាងថា សហព្រះរាជអាជ្ញាបានសួរសំណួរសាក្សីឲ្យធ្វើការសន្និដ្ឋានស្មានៗចំពោះអ្វីដែលខ្លួនមិនបានដឹង ព្រោះសាក្សីរូបនេះមិនដែលបានទាក់ទងជាមួយនឹងអ្នកធ្វើចំណារនេះទេ ។ ដូច្នេះការអះអាងរបស់សាក្សីគ្រាន់តែជាការស្មានរបស់សាក្សីដែលជាការមិនអាចទទួលយកបាន ។ បន្ទាប់ពីមេធាវីការពារ អៀង សារី ជំទាស់ចប់ភ្លាម ក្រុមមេធាវីការពារក្តី នួន ជា ក៏បានក្រោកឡើងធ្វើការជំទាស់នឹងការចោទសួរសំណួររបស់សហព្រះរាជអាជ្ញាដូចគ្នា ។ អង្គជំនុំជម្រះយល់ស្របជាមួយការជំទាស់របស់ក្រុមមេធាវីការពារក្តី ដោយមិនឲ្យសាក្សី ឌុច ឆ្លើយសំណួររបស់សហព្រះរាជអាជ្ញានិងស្នើឲ្យសហព្រះរាជអាជ្ញាបន្តទៅសំណួរផ្សេងទៀត ។

សហព្រះរាជអាជ្ញារង លោក ស្មិត បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងចំណារសរសេរដោយដៃនៅលើចម្លើយសារភាពដោយសួរ ឌុច ថា តើឌុចមានចាំឬទេថាចំណារលើចម្លើយសារភាពនោះជារបស់នរណា? ប៉ុន្តែសំណួរនេះនៅតែត្រូវបានជំទាស់ដោយលោកមេធាវី ខាណាវ៉ាស់ ដោយបញ្ជាក់ថា សហព្រះរាជអាជ្ញានៅតែបន្តសំណួរដែលឲ្យសាក្សីធ្វើការសន្និដ្ឋាន ព្រោះ ឌុច បានលើកឡើងហើយថា ខ្លួនមិនដែលបានឃើញចំណារនោះពីមុនទេ ។ លោកមេធាវីបានបន្ថែមថា បើសាក្សីចេញតាមទ្វារខាងមុខហើយ គឺសាក្សីមិនអាចចេញតាមផ្លូវក្រោយបានទេ និងថាបើសិនជាសហព្រះរាជអាជ្ញាសួរសាក្សី ហើយសាក្សីឆ្លើយថាខ្លួនធ្លាប់បានឃើញចំណារនោះ ទើបសហព្រះរាជអាជ្ញាអាចសួរសំណួរបន្តថាតើចំណារនោះជារបស់អ្នកណា ។ ក្រុមមេធាវីការពារក្តី នួន ជា បានបន្ថែមលើការជំទាស់របស់ក្រុមមេធាវី អៀង សារី ថា សហព្រះរាជអាជ្ញាកំពុងតែព្យាយាមសួរសំណួរនាំមុខទៅសាក្សី ។ លោកសហព្រះរាជអាជ្ញា ស្មិត បានឆ្លើយតបទៅមេធាវីវិញថា ការដែលខ្លួនសួរសំណួរនេះ គឺដោយសារសាក្សីធ្លាប់បានធ្វើការទាក់ទងនឹងការធ្វើចំណារនេះ ដូច្នេះសហព្រះរាជអាជ្ញាគ្រាន់តែចង់ឲ្យសាក្សីធ្វើការបញ្ជាក់ប៉ុណ្ណោះ ។ ដើម្បីដោះស្រាយការជំទាស់របស់ក្រុមមេធាវីការពារក្តី លោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រគល់វេទិកាជូនលោកចៅក្រម ហ្សង់ម៉ាក់ ឡាវើញ ដើម្បីធ្វើការកត់សម្គាល់ ។ លោកចៅក្រម ឡាវើញ បានសួរ ឌុច ថាតើ

ឌុច មានបានទទួលចំណារ ឬទទួលបញ្ជាពីដែលមាននៅលើចម្លើយសារភាពដែល ឌុច អះអាងថាជារបស់ នួន ជា ដែរឬទេ? ។ ឌុច ឆ្លើយតបនឹងសំណួររបស់លោកចៅក្រមថា ខ្លួនមិនដែលបានឃើញចំណារនោះពីមុនមកទេ ។ ចំណារនេះគឺឃើញនៅពេលដែលសហចៅក្រមស៊ើបអង្កេតយកឯកសារចម្លើយសារភាពនោះមកសួរខ្លួនដើម្បីធ្វើការបញ្ជាក់នៅក្នុងដំណាក់កាលស៊ើបសួរប៉ុណ្ណោះ ។ ឌុច បន្ថែមថា រាល់ចម្លើយសារភាពទាំងអស់ដែលបញ្ជូនចេញពីស-២១ជូនថ្នាក់លើ គឺមិនដែលបញ្ជូនត្រឡប់មកវិញទេ ។ ដូច្នេះខ្លួនមិនដែលបានទទួលចម្លើយសារភាពដែលមានចំណារនោះមក ស-២១វិញទេ ។

លោក ស្មីត បានបង្ហាញចម្លើយសារភាពមួយដែលមានឈ្មោះ សាន់ ប៉ូ ដើម្បីឲ្យ ឌុច ធ្វើការបញ្ជាក់អំពីចំណារដែលមានលើចម្លើយសារភាព ។ ឌុច បំភ្លឺថា ចំណារលើចម្លើយសារភាពរបស់ សាន់ ប៉ូ គឺជាចំណាររបស់ នួន ជា ។ សហព្រះរាជអាជ្ញាបានបន្តសួរ ឌុច ថាតើ ឌុច ធ្លាប់បានឃើញចំណាររបស់ នួន ជា នៅពេលដែលខ្លួនធ្វើការនៅស-២១ដែរឬទេ? ។ ឌុច បញ្ជាក់ជូនសហព្រះរាជអាជ្ញាវិញថា នួន ជា ធ្លាប់បានសរសេរសំបុត្រមកខ្លួនប៉ុន្មានដង ដូច្នេះខ្លួនស្គាល់អក្សររបស់ នួន ជា និងបញ្ជាក់បន្ថែមថា ខ្លួនមិនដែលឃើញចំណាររបស់ នួន ជា នៅក្នុងអំឡុងពេលដែលខ្លួនធ្វើការជាប្រធានស-២១ទេ ប៉ុន្តែបានឃើញនៅក្នុងដំណាក់កាលស៊ើបអង្កេត ដែលសហចៅក្រមស៊ើបបានយកមកបង្ហាញ និងស្នើឲ្យខ្លួន ធ្វើការបញ្ជាក់ ។

លោក ស្មីត បានបង្ហាញតារាងបញ្ជីឈ្មោះរបស់អ្នកដែលឆ្លើយដាក់និងត្រូវគេឆ្លើយដាក់ដែលធ្វើការនៅក្រសួងការបរទេសដែលមានចំនួន២៩នាក់ ។ ឌុច បញ្ជាក់ថា មនុស្សដែលមានឈ្មោះក្នុងបញ្ជីនោះមិនទាន់ត្រូវបានគេយកទៅកម្ទេចទេ ដោយសារតារាងបញ្ជីឈ្មោះនោះមិនទាន់បញ្ជូនទៅអចិន្ត្រៃយ៍ ។ ឌុច បន្ថែមថា ការដែលខ្លួនហ៊ានអះអាងថាបញ្ជីតារាងឈ្មោះអ្នកដែលឆ្លើយដាក់គេ និងត្រូវបានគេឆ្លើយដាក់មិនទាន់ត្រូវបានបញ្ជូនទៅខាងលើ គឺមានមូលហេតុពីរ ។ ទីមួយ គឺដោយសារមិនមានហត្ថលេខា របស់ ឌុច នៅលើបញ្ជីឈ្មោះនោះ បើបញ្ជូនទៅអចិន្ត្រៃយ៍ ឌុច នឹងសរសេរថាគោរពជូនបង ។ ទីពីរ គឺឯកសារនោះមានដាក់អក្សរ ធី អេស អិល ដែលបង្ហាញថាឯកសារនោះប្រមូលយកចេញពីទួលស្លែង មានន័យថា ឯកសារនោះមិនទាន់យកចេញទៅអចិន្ត្រៃយ៍នៅឡើយទេ ។ ឌុច បន្តថា ឈ្មោះដែលគេឆ្លើយដាក់នៅក្នុងឯកសារនេះភាគច្រើនត្រូវបានគេឆ្លើយដាក់១ដង មានតែឈ្មោះមនុស្ស២នាក់ប៉ុណ្ណោះដែលគេឆ្លើយដាក់២ដង ។ បើការឆ្លើយដាក់មានចំនួនតិចពេក ស-២១ នឹងមិនបញ្ជូនទៅគណៈអចិន្ត្រៃយ៍ទេ ។

### ២.២.៤) តួនាទីរបស់ជនជាប់ចោទ

លោកសហព្រះរាជអាជ្ញារង ស្មីត បានបន្តសួរដេញដោល ឌុច ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ រួមមាន ខៀវ សំផន, អៀង សារី និង នួន ជា ។

#### ក) ខៀវ សំផន

ឌុច បានបញ្ជាក់ថា ខ្លួនធ្លាប់បានឮឈ្មោះ ខៀវ សំផន តាំងពីឆ្នាំ១៩៥៨ គឺតាំងខ្លួននៅក្មេងៗនៅពេលដែលនាយកសាលានៅខេត្តកំពង់ធំហៅខ្លួនទៅប្រឆាំងនឹងកាសែត ឡឺ អុបសេវ៉ាទ័រ និងបានដឹងពីបញ្ហាផ្សេងទៀតរបស់ ខៀវ សំផន ។ នៅពេលបន្ទាប់មកទៀតនៅឆ្នាំ១៩៦៧ ខៀវ សំផន បានបាត់ខ្លួននិងបានដឹងថា ខៀវ សំផន មាននាទីជាឧបនាយករដ្ឋមន្ត្រី និងអគ្គសេនាធិការកងទ័ព ប៉ុន្តែ ឌុច អះអាងថា តំណែងនោះគ្រាន់តែជាតំណែងឧបកិច្ចប៉ុណ្ណោះដោយសារ ខៀវ សំផន មិនចេះបញ្ជាទ័ពទេ ។ ឌុច បន្តទៀតថាខ្លួនបានដឹងថា ខៀវ សំផន មាននាទីនោះតាមរយៈវិទ្យុផ្សាយសំឡេង ។ មានពេលមួយនោះ ឌុច ធ្លាប់បានដឹងថា នៅឆ្នាំ១៩៦១ ខៀវ សំផន ត្រូវបាន គូរុណា ដែលជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃវ៉ៃសម្រាតនៅជិតផ្ទះកុងស៊ីម្នាក់ឈ្មោះ លឹម គ្រី ដោយដំណឹងស្តីពីព្រឹត្តិការណ៍នោះល្បីសុសសាយ ។ ឌុច បន្តថា ខៀវ សំផន មាននាទីជាប្រធានមន្ទីរមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា គឺខ្លួនបានឮនៅមុនឆ្នាំ១៩៧៥ ។ ឌុច បានបន្តថា ខៀវ សំផន ធ្វើជាអគ្គបញ្ជាការកងទ័ព ប៉ុន្តែគឺគ្រាន់តែជាអគ្គបញ្ជាការមានតែឈ្មោះ និងមិនមានកងទ័ពបញ្ជាឡើយ ព្រោះកងទ័ពទាំងអស់ជារបស់ ប៉ុល ពត ហើយ ខៀវ សំផន ខ្លួនឯងក៏មិនចេះបញ្ជាទ័ពដែរ ។ ឌុច បានបញ្ជាក់ទៀតថាការដែល ប៉ុល ពត ប្រគល់ភារកិច្ចឲ្យ ខៀវ សំផន ដូច្នេះគឺដោយសារតែ ប៉ុល ពត ទុកចិត្ត ហើយសម្តេច សីហនុ ក៏ទុកចិត្ត ខៀវ សំផន ដែរ ។ មានពេលមួយនោះ សម្តេចសីហនុ ធ្លាប់បាន

ហៅ ខៀវ សំផន ថា ជាព្រះពុទ្ធថែមទៀតផង ។ ឌុច បានបញ្ជាក់ថា ដោយសារតែខ្លួនស្រឡាញ់ចូលចិត្ត ខៀវ សំផន ក្នុងនាមជាអនុធន ទើបខ្លួនស្គាល់ ខៀវ សំផន ហើយការតែងតាំងជាអគ្គបញ្ជាការកងទ័ព គឺដោយសារតែអន្តរជាតិយល់ថា ខៀវ សំផន គឺជាមនុស្សម្នាក់ត្រឹមត្រូវ ។ ឌុច បញ្ជាក់ថា នៅឆ្នាំ១៩៧០-៧៥ ខៀវសំផន មាននាទីជាប្រធានមជ្ឈិម និងរស់នៅជាប់ជាមួយ ប៉ុល ពត ។

### ខ) អៀង សារី

ឌុច ថា ខ្លួនបានឮឈ្មោះ អៀង សារី ដំបូងនៅឆ្នាំ១៩៦២ នៅពេលដែលខ្លួនបានរៀនចប់ឌីប្លូមហើយ និងបានទៅនិយាយលេងជាមួយនឹងគ្រូរបស់ខ្លួន ពេលនោះគ្រូបានប្រាប់ខ្លួនថា អៀង សារី គឺជាអ្នកនយោបាយម្នាក់គួរឲ្យគោរព ។ សហព្រះរាជអាជ្ញារង ស៊្មីត បានសួរបន្តសួរ ឌុច ទាក់ទងនឹងជនជាប់ចោទអៀងសារី នៅអំឡុងឆ្នាំ១៩៧០-៧៥ ។ ឌុច បានអះអាងថា នៅឆ្នាំ១៩៧១ ខ្លួនបានដឹងថា អៀង សារី ធ្លាប់ធ្វើការខាងវិទ្យុនៅប៉េកាំង ។

ឆ្លើយតបនឹងសំណួរសហព្រះរាជអាជ្ញាទាក់ទងនឹងការជួបគ្នាជាមួយនឹង អៀង សារី នៅអំឡុង ឆ្នាំ១៩៧៥-១៩៧៩ ឌុច បំភ្លឺថា មិនដែលបានជួបគ្នាផ្ទាល់មាត់ជាមួយនឹង អៀង សារី ទេ ប៉ុន្តែធ្លាប់បានឃើញ អៀង សារី ពីរដង ។ លើកទី១ នៅបុរីកីឡា និងលើកទី២ ពេលដែល អៀង សារី ធ្វើដំណើរតាមផ្លូវ ព្រះសីហនុ ទៅមាត់ទន្លេ ស្របពេលដែលខ្លួនជិះម៉ូតូមកពីមាត់ទន្លេ នៅថ្ងៃទី៦ មករា ១៩៧៩ ។ ឌុច បានបញ្ជាក់ថា នួន ជា ធ្លាប់បាននិយាយពី អៀង សារី នៅក្នុងករណីចាប់ខ្លួនរបស់ ចៅ សេង តែម្តងគត់គឺ នួន ជា និយាយថាបើនរណាមកពីក្រសួងការបរទេសមកសួររក ចៅ សេង ត្រូវប្រាប់គេថាមិត្តមិនបានដឹងពីបញ្ហានេះទេ ។ ករណីមួយទៀតនៅពេលដែលមានចម្លើយសារភាពដែលឆ្លើយដាក់កូនបង្កើត និងកូនប្រសាររបស់ អៀង សារី ហើយឌុចទៅសុំយោបល់ពី នួន ជា អំពីថាតើគួរស្តាប់ចម្លើយខ្មាំងទៀតដែរឬទេ ។

### គ) នួន ជា

នៅចន្លោះ១៩៧០-៧៥ នួន ជា គឺជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានបន្ថែមថា ខ្លួនបានដឹងថា អៀង សារី, នួន ជា និង ខៀវ សំផន រស់នៅមន្ទីរមជ្ឈិម ប៉ុន្តែខ្លួនមិនច្បាស់ថាមន្ទីរមជ្ឈិមនោះ នៅទីណាពិតប្រាកដទេ ។ ឌុច បញ្ជាក់បន្ថែមថា ការដែលរស់នៅរួមគ្នា គឺមិនមែនជាគោលនយោបាយរបស់បក្សនោះទេ ប៉ុន្តែគឺដើម្បីកុំឲ្យមានការប្រណែនគ្នា ។

### ២.២.៥) ការបញ្ជាក់លើឯកសារនានា

ទាក់ទងនឹងការសួរដេញដោលលើឯកសារនានា លោកសហព្រះរាជអាជ្ញារងអន្តរជាតិបានស្នើឲ្យ ឌុច បញ្ជាក់ឯកសារជាច្រើនរួមមានឯកសារទាក់ទងនឹងប្រវត្តិរូប, ឯកសារដែលជារូបថតនៅស-២១, បញ្ជីអ្នកទោស, ឯកសារចម្លើយសារភាព, ឯកសារទស្សនាវដ្តីទង់បដិវត្ត, ឯកសារកំណត់ហេតុសរសេរដោយដៃ, ឯកសារទាក់ទងនឹងសិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ, វគ្គសិក្សានយោបាយថ្ងៃទី៣០ កញ្ញា ១៩៧៨, សេចក្តីណែនាំទាក់ទងនឹងការប្រើពាក្យ“អង្គការ”, គោលនយោបាយរបស់បក្សចំពោះខ្មាំង, មន្ទីរបឹងត្របែក, សេចក្តីសម្រេចប្រហារជីវិតជនក្បត់ទាំង៧រូប, ចម្លើយសារភាពរបស់ ហ៊ូ នឹម ។

### ក) ឯកសារប្រវត្តិរូប

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងការធ្វើប្រវត្តិរូបផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗនៅមន្ទីរស២១ ។ ឌុច បានរៀបរាប់ថា នៅក្នុងប្រវត្តិរូបនីមួយៗមានឈ្មោះលើសពីមួយដោយសារនៅមុនឆ្នាំ១៩៧៥ បុគ្គលម្នាក់ៗប្រើឈ្មោះសម្ងាត់នៅពេលចូលបដិវត្ត ។ ប្រវត្តិរូបត្រូវបានធ្វើឡើងនៅក្នុងការបំពេញការងារដូចជានៅមន្ទីរស-២១ និងធ្វើរៀងរាល់មួយឆ្នាំម្តងបន្ទាប់ពីបញ្ចប់វគ្គសិក្សា ។ តាមសក្ខីកម្មរបស់ ឌុច ប្រវត្តិរូបគឺធ្វើឡើងជារួមនៅទូទាំងប្រទេស មិនមែនមានតែក្នុងមន្ទីរស-២១ទេ ។ ឌុច បញ្ជាក់បន្ថែមថា នៅក្នុងប្រវត្តិរូបមានទម្រង់សំណួរជាច្រើនសួរពីបុគ្គលដែលពាក់ព័ន្ធដូចជាមិត្តភក្តិ ឪពុកម្តាយ បងប្អូន ដោយសារបុគ្គលទាំងនោះមានឥទ្ធិពលនយោបាយមកលើខ្លួន ។ ការសួរពីវណ្ណៈ កម្រិតអប់រំ និងបញ្ហានយោបាយដើម្បីឲ្យបក្សយល់ពីនយោបាយរបស់បុគ្គលដែលធ្វើប្រវត្តិរូបនេះ ។ ប្រវត្តិរូបរបស់អ្នកទោសនៅមន្ទីរស-២១ មានលក្ខណៈខុសគ្នាពីប្រវត្តិរូបរបស់បុគ្គលិកដែលធ្វើការនៅមន្ទីរស-២១ ។

ឌុច និយាយថា ការកសាងប្រវត្តិរូបបដិវត្ត គឺដើម្បីដឹងថាបក្ខជនមានភាពរារែកបត់បែនយ៉ាងណាខ្លះមានការចុះចូលជាមួយ

ខ្លាំង ឬមានភាពអសកម្មដែរឬទេ ។ ក្នុងមួយឆ្នាំពេលរៀនសូត្រវគ្គម្តងៗ គឺមានគម្រោងធ្វើប្រវត្តិរូបតាមឯកសារ ដែលបានរៀនក្នុងមួយឆ្នាំថាតើកសាងបានល្អកម្រិតណាហើយ ។ ឌុច បានបន្តទៀតថាម្ចាស់ប្រវត្តិរូបអានប្រវត្តិរូបរបស់ខ្លួនជូនអង្គប្រជុំស្តាប់ រួចឲ្យគេជួយជាមតិយោបល់ ។ ការកសាងប្រវត្តិរូបបដិវត្តមិនមែនចេះតែធ្វើនោះទេ គឺត្រូវកសាងប្រចាំឆ្នាំនៅពេលរៀនសូត្រនយោបាយជាដាច់ខាត ។ ជីវទស្សនៈបដិវត្តន៍ក៏ត្រូវបានកសាងតាមរបៀបនេះដែរ គ្រាន់តែពិនិត្យពីគំនិតរបស់បុគ្គលលើជីវភាពរស់នៅថាតើត្រូវការអ្វីខ្លះ ហើយត្រូវយល់ខ្លួនឯងថាត្រូវមានជីវិតរបៀបយ៉ាងម៉េច ។ សមាជិកបក្សត្រូវវិភាគលើការរស់នៅដើម្បីធ្វើបដិវត្តបម្រើប្រជាជនឬដើម្បីបុណ្យសក្តិ ។

## ខ) ការថតរូបនៅស-២១

លោកស្មីតបានបង្ហាញឯកសារចំនួន២ដើម្បីឲ្យឌុចធ្វើការបញ្ជាក់ទាក់ទងនឹងប្រវត្តិរូបអ្នកទោសនៅស-២១ ។ ឌុច បានទទួលស្គាល់ថា ឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញ គឺពិតជាឯកសាររបស់មន្ទីរស-២១ ដោយសារនៅលើឯកសារនោះមានចំណាររបស់សមមិត្ត ហ៊ី ដែលគេធ្វើឡើងដើម្បី ដឹងព័ត៌មានដំបូងរបស់អ្នកដែលគេចាប់បញ្ជូនមកស-២១ ។ លោកសហព្រះរាជអាជ្ញារងស្មីតបានស្នើឲ្យ ឌុច អានប្រវត្តិរូបរបស់ឈ្មោះ ផល វ៉ាហៅ ណាត ។ បន្ទាប់មកលោកបានបង្ហាញរូបថតដល់ ឌុច និងសួរពីទម្រង់នៃរូបថតនោះ និងចោទសួរថាតើអ្នកដែលគេចាប់ខ្លួនបញ្ជូនមកស-២១ ត្រូវតែថតរូបទាំងអស់ឬយ៉ាងណា? ឌុចឆ្លើយថារាល់អ្នកទោសទាំងអស់ដែលចូលមកស-២១ត្រូវតែថតរូបលើកលែងតែអ្នកទោសពិសេសដែលគេមិនថតពីព្រោះដើម្បីរក្សាការណ៍សម្ងាត់ ។ ឌុច បន្ថែមទៀតថា ពេលវេលាដែលអ្នកទោសពិសេសត្រូវបានចាប់ចូលមកស-២១ នៅពេលណាមិនមានអ្នកណាបានដឹងទេ ហើយអ្នកទោសនោះត្រូវបានគេនាំយកទៅដាក់ក្នុងគុកពិសេស ដោយមានកងពិសេសយាម សូម្បីតែអ្នកថតរូប និងអ្នកកត់ត្រាថ្ងៃចូលមកស-២១ ក៏មិនអាចចូលទៅកន្លែងដាក់អ្នកទោសពិសេសនោះបានដែរ ។ ចំពោះការកំណត់ថាអ្នកណាជាអ្នកទោសពិសេស គឺជាតួនាទីរបស់ សុន សេន ហើយជាទូទៅអ្នកទោស ពិសេសច្រើនតែជាកម្មាភិបាលជាន់ខ្ពស់របស់បក្ស ។ ឌុច បានបញ្ជាក់ថា ការថតរូបអ្នកដែលត្រូវបានចាប់បញ្ជូនមកស-២១ គឺចាប់ផ្តើមតាំងពីពេលដែល ណាត នៅធ្វើជាប្រធានស-២១ និងថាការថតរូបនេះធ្វើឡើងដើម្បីការពារនៅពេលដែលអ្នកទោសលួចរត់ គេអាចស្វែងរកមុខអ្នកទោសតាមរយៈរូបថតទាំងនោះបានភ្លាមៗ ។

## គ) បញ្ជីអ្នកទោស

បន្ទាប់មក លោក ស្មីត បានបង្ហាញឯកសារទាក់ទងនឹងឈ្មោះរបស់អ្នកទោសដើម្បីឲ្យ ឌុច ពិនិត្យមើលនិងធ្វើការកត់សម្គាល់ ។ ក្រោយពីបានឃើញបញ្ជីឈ្មោះដែលលោកសហព្រះរាជអាជ្ញាបង្ហាញ ឌុច បានអះអាងថា ឯកសារនោះគឺពិតជាឯកសារបញ្ជីឈ្មោះអ្នកទោសដែលចាប់មកពីក្រសួងការបរទេស និងបញ្ជូនមកស-២១ ហើយថាឯកសារនោះគឺធ្វើឡើងដោយមន្ទីរស-២១ ។ ឌុច បានបញ្ជាក់បន្ថែមទៀតថា ការធ្វើបញ្ជីឈ្មោះអ្នកដែលត្រូវបានចាប់បញ្ជូនមកស-២១ គឺដើម្បីដឹងពីចំនួនអ្នកទោសនិងដើម្បីជៀសវាងកុំឲ្យធ្លាក់លើស្តិបន្ទោសថាខ្ជីខ្ជានឹងការងារ ។

លោក ស្មីត បានបន្តបង្ហាញឯកសារទាក់ទងនឹងពេទ្យអង្គការដើម្បីឲ្យ ឌុច ធ្វើការកត់សម្គាល់ ។ ឌុច ថាឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញ គឺមិនមែនជាឯកសារដែលធ្វើឡើងដោយស-២១ទេ ព្រោះពេទ្យអង្គការមិនមែនជាផ្នែកនៃស-២១ ។ ប៉ុន្តែភ្លាមៗនោះ ឌុច បានទទួលស្គាល់វិញថា ឯកសារ នោះពិតជាបានធ្វើឡើងនៅស-២១ ដោយសារនៅលើឯកសារនោះមានចុះពីថ្ងៃចាប់ខ្លួនអ្នកទោស តែខ្លួនមិនដែលបានឃើញឯកសារនោះពីមុនមកទេ ។

លោកសហព្រះរាជអាជ្ញារង ស្មីត បានសួរ ឌុច អំពីចំនួនអ្នកទោសដែលគេនាំយកមកស-២១ នៅមុនថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ ឌុច និយាយថា មុនថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ មានអ្នកទោសចំនួនពីប្រាំមួយរយទៅមួយពាន់នាក់ប៉ុណ្ណោះ ដែលត្រូវបានគេចាប់បញ្ជូនមកមន្ទីរនគរបាលកងពល៧០៣ (មុនពេលប្រែក្លាយមកជាមន្ទីរស-២១) ក្នុងនោះមានអ្នកនេសាទជាជនជាតិថៃចំនួនប្រហែល៣០០នាក់ ។

## ឃ) សារភាព ធ្វើទារុណកម្ម និងកម្ទេច

លោក ស្មីត បានសួរ ឌុច ដោយរំឭកអំពីសម្តីរបស់ ឌុច ដែល

ថាជាទូទៅចម្លើយសារភាពនៅស-២១ គឺធ្វើឡើងក្រោមការធ្វើទារុណកម្ម បន្ទាប់មកលោកបានស្នើឌុចឲ្យពន្យល់អំពីពាក្យថា "សារភាព" ថាតើពាក្យនេះមានន័យយ៉ាងដូចម្តេច? ឌុច បានអះអាងថា ពាក្យថា "សារភាព" គឺត្រូវបានគេប្រើជារួមដោយសំដៅលើពាក្យថា "ឆ្លើយ" ទោះបីចម្លើយនោះទទួលបានមកដោយការបង្ខំក៏ដោយ ។ ឌុច បានបន្តទៀតថា រាល់អ្នកទោសទាំងអស់សុទ្ធតែទទួលរងការធ្វើទារុណកម្ម លើកលែងតែកុយ ធួនម្នាក់គត់ដែលឌុច ខ្លួនឯងត្រូវបានថ្នាក់លើបញ្ជាឲ្យសួរដោយផ្ទាល់ និងមិនឲ្យធ្វើទារុណកម្ម ។ ឌុច បញ្ជាក់ថា មុនដំបូងខ្លួន ណែនាំឲ្យបុគ្គលិកនៅស-២១ ថតសំឡេងនៅពេលសួរចម្លើយអ្នកទោសហើយបញ្ជូនទៅថ្នាក់លើ ប៉ុន្តែសុន សេន បានណែនាំមិនឲ្យធ្វើដូច្នេះ ដោយប្រាប់ឌុច ថា នួន ជា ចិត្តចូលអានជាជាងស្តាប់ ។ ហេតុនេះខ្លួនក៏ប្តូរពីការសួរចម្លើយដោយថតសម្លេងមកជាការសួរចម្លើយដោយសរសេរផ្ទាល់ដៃវិញ ។ ឌុច បន្ថែម ថាបើក្នុងករណីអ្នកសួរចម្លើយមិនចេះសរសេរអក្សរ គេនឹងសួរដោយថតជាខ្សែអាត់ហើយប្រគល់ឲ្យបុគ្គលិកស-២១ផ្សេងទៀតចម្លងចេញពីខ្សែអាត់ថតសំឡេង ។ ឌុច អះអាងថា ខ្លួនធ្លាប់បានសួរចម្លើយ កុយ ធួន ដោយផ្ទាល់ចំនួន៤ដងតាមបញ្ជារបស់ សុន សេន ដែលជាថ្នាក់លើរបស់ខ្លួន ហើយព័ត៌មានដែលទទួលបានពីការសួរចម្លើយនោះមានកម្រាស់ច្រើនរយទំព័រ ។ បន្ទាប់មកចម្លើយសារភាពរបស់ កុយ ធួន ត្រូវបានបញ្ជូនទៅថ្នាក់លើដើម្បីពិនិត្យ ។ក្រោយពិនិត្យរួចរាល់ សុនសេន បានបញ្ជាក់ប្រាប់ ឌុច វិញថា ចម្លើយនោះមានព័ត៌មានពិតប្រាកដត្រឹមតែចម្លើយលើកទីបីប៉ុណ្ណោះ ក្រៅពីនេះគឺជាការឆ្លើយប្រឌិត ។ ឌុច បានបន្តថា នៅស-២១មិនមែនឲ្យតែអ្នកទោសចូលមកដល់ភ្លាម ធ្វើទារុណកម្មភ្លាមនោះទេ គឺមានវិធីច្រើនដើម្បីទាញយកចម្លើយពីអ្នកទោស ។ វិធីទាំងនោះមានដូចជា ស្លូត ក្តៅ អង្អៀម ។ ការសួរចម្លើយ គឺដើម្បីយកព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធដោយតម្រូវឲ្យអ្នកដែលត្រូវបានចាប់ខ្លួនរៀបរាប់ពីប្រវត្តិរូបរបស់ខ្លួនតាំងពីឆ្នាំណា និងបញ្ជូនចម្លើយទាំងអស់នោះទៅថ្នាក់លើដើម្បីពិចារណាថាតើព័ត៌មានទាំងអស់នោះពិត ឬអត់ ។

លោកសហព្រះរាជអាជ្ញារងបានបង្ហាញ ឌុច បន្ថែមទៀតអំពីឯកសារចម្លើយសារភាពរបស់ ឈ្មោះ ទីវ អុល និងស្នើឲ្យ ឌុច ធ្វើការបញ្ជាក់ពីឯកសារនោះ ។ ឌុច និយាយថា ឯកសារនោះពិតជាធ្វើឡើងដោយស-២១ ដោយសារមានចំណាររបស់ខ្លួនដែលសរសេរទៅបងទី២ និងចំណាររបស់ សុន សេន ។ ឌុច បានបញ្ជាក់ថាក្រោយពីសួរចម្លើយរួចរាល់ហើយអ្នកទោសទាំងអស់តែងតែត្រូវបានគេនាំយកទៅសម្លាប់ភ្លាមៗ លើកលែងតែ កុយ ធួន មួយ


កុយ ធួន ជាប់ឃុំឃាំងនៅមន្ទីរ ស-២១

គត់ដែលថ្នាក់លើបញ្ជាឲ្យទុកឲ្យបានយូរក្រោយពេលសួរចម្លើយ ។ ឌុច បានសង្កត់ធ្ងន់ថា អ្នកដែលមានសិទ្ធិបញ្ជាឲ្យយកនរណាម្នាក់ទៅកម្ទេចគឺសុនសេនប៉ុន្តែ ចាប់ពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៧ ក្រោយពេល សុន សេន ចេញទៅសមរភូមិ គឺ នួន ជា ដែលជាអ្នកមានសិទ្ធិបញ្ជាចំពោះបញ្ហានេះ ។

បន្ទាប់មកលោក ស្មឹត បានបង្ហាញឯកសារទាក់ទងនឹងបញ្ជីរាយឈ្មោះអ្នកទោសដែលបានផ្ទាកនៅខែមករា ឆ្នាំ១៩៧៧ ។

ឌុច បានពន្យល់ថា ពាក្យថា "ផ្ដាក" មានន័យថា ជាការសួរចម្លើយមិនទាន់ចប់សព្វគ្រប់ ហើយបញ្ឈប់ការសួរ ដោយយកអ្នកទោសដែលមិនទាន់សាកសួរចប់ទៅកម្ទេច ។ ឌុច បន្តថា បញ្ហានេះកើតឡើងបន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួនបញ្ជូនកមកស-២១ នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ១៩៧៦ ហើយឆ្លើយសារភាពនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៦ ។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ថ្នាក់លើបានសម្រេចសម្រិតសម្រាំងយកខ្សែរបស់ កុយ ធួន រាប់រយនាក់មកស-២១ ។ ដូច្នេះអ្នកដែលនៅសល់ថ្នាក់លើបានបញ្ជាឲ្យស-២១ បញ្ចេញ ។

## ង) ទស្សនាវដ្ដីទង់បដិវត្ត

លោកសហព្រះរាជអាជ្ញារងបានបន្តបង្ហាញឯកសារទាក់ទងនឹងទស្សនាវដ្ដីទង់បដិវត្ត ហើយចោទសួរ ឌុច ថាតើទង់បដិវត្តគេប្រើដើម្បីអ្វី និងថាខ្លឹមសារនៅក្នុងឯកសារនោះមានន័យដូចម្ដេច? ឌុច និយាយ ថាទង់បដិវត្តគឺជាឈ្មោះទស្សនាវដ្ដីផ្ទៃក្នុងបក្សដែលលេខាបក្សសរសេរដើម្បីអប់រំបក្ខជនរបស់ខ្លួនរៀងរាល់ខែ ។ បក្ខជនគ្រប់រូបត្រូវតែអានឯកសារទស្សនាវដ្ដីទង់បដិវត្តដើម្បីយកទៅអប់រំអ្នកដែលនៅក្រោមបង្គាប់របស់ខ្លួន ហើយថាការអប់រំរបស់បក្សគឺផ្ដោតលើបញ្ហាបី ។ ទី១គឺគោលនយោបាយរបស់បក្ស ទីពីរ គឺគោលជំហរសតិអារម្មណ៍របស់បក្ស និងទីបី គឺគោលជំហរអប់រំរបស់បក្ស ។ ឌុច បញ្ជាក់ថាខ្លួនបានទទួលទស្សនាវដ្ដីនេះជាទៀងទាត់ និងបានបង្រៀនកម្មាភិបាលរបស់ខ្លួនអំពីគោលនយោបាយរបស់បក្សតាមរយៈឯកសារទង់បដិវត្ត ។

ឌុច បានឆ្លើយតបអំពីពាក្យទំនាស់ថា នៅក្នុងទស្សនៈវិជ្ជាសម្ភារៈនិយម "បដិបក្រសមុបាត" ទំនាស់ មាន២គឺ ទី១ ទំនាស់ផ្ទៃក្នុង(មិនស្លាប់រស់ទេ)គឺរវាងភាគីពីរ ។ ភាគីទាំងពីរនេះពឹងអាស្រ័យចលនាគ្នាទៅវិញទៅមកដើម្បីឲ្យចលនាវាទៅមុខ ។ ឧទាហរណ៍ ទំនាស់រវាងកម្មាភិបាលជាមួយយុវជន ហើយការដោះស្រាយគឺតាមការស្ទីមតិតាមការរៀនសូត្រ និងទី២ ទំនាស់រវាងយើង និងខ្មាំងជាទំនាស់ស្លាប់រស់បាន ន័យថាបើមួយអាចរីកចម្រើនបានត្រូវតែអត់មានមួយទៀត ។

## ច) កំណត់ហេតុសរសេរដោយដៃ

បន្ទមកលោកសហព្រះរាជអាជ្ញារង ស្មីត បានបង្ហាញកំណត់ហេតុសរសេរផ្ទាល់ដៃរបស់ឈ្មោះ ម៉ម ណៃ ដើម្បីឲ្យ ឌុច ធ្វើការបញ្ជាក់ ។ ឌុច និយាយថា ម៉ម ណៃ គឺជាសាស្ត្រាចារ្យបរិញ្ញាអក្សរសាស្ត្រខ្មែរ និងមានតួនាទីជាជំនួយការរបស់ខ្លួន ។ ឌុច អះអាងថា ខ្លួនធ្លាប់បានបញ្ជា ម៉ម ណៃ ឲ្យសួរចម្លើយឈ្លើយសឹកវៀតណាមដើម្បីថតជាខ្សែអាត់សំឡេងយកទៅចាក់ផ្សាយតាមវិទ្យុចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ មកម្ល៉េះ ។

ឆ្លើយតបនឹងសំណួរពាក់ព័ន្ធនឹងមហាសន្និបាតដែលប្រារព្ធធ្វើនៅស-២១ ឌុច ឆ្លើយថា ស-២១ ធ្លាប់បានប្រារព្ធធ្វើមហាសន្និបាតចំនួន២ដងដែលមានវត្តមានរបស់ សុន សេន ចូលរួមផ្ទាល់ បន្ទាប់ពីពេលនោះមកមិនដែលមានធ្វើមហាសន្និបាតទៀតឡើយ

លោក ស្មីត បានបន្តបង្ហាញអំពីឯកសារចម្លើយសារភាពរបស់ឈ្មោះ ចាប មិុត ដែលនៅលើចម្លើយសារភាពនោះមានចំណារផ្ទាល់របស់ ឌុច ដែលសរសេរទៅសមមិត្ត ប៉ុន ។ ឌុច បានអះអាងថា ចំណារដែលមាននៅលើចម្លើយសារភាពរបស់ ចាប មិុត ពិតជាចំណារផ្ទាល់របស់ខ្លួន ។ ឌុច បន្តទៀតថា នៅលើចម្លើយសារភាពនោះមានឃ្លាមួយដែលខ្លួនបានសរសេរទៅសមមិត្ត ប៉ុន ឲ្យដកឈ្មោះមនុស្សមួយចំនួនចេញពីបញ្ជីឈ្មោះដែលគេឆ្លើយដាក់តាមគោលការណ៍ណែនាំរបស់បងទី២ ដែល ឌុច អះអាងថា បងទី២គឺ នួន ជា ។

ពាក់ព័ន្ធនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើឲ្យ ឌុច ធ្វើការបញ្ជាក់អំពីសំបុត្រដែល ឌុច សរសេរផ្ញើជូនឈ្មោះ ប៉ុន ទាក់ទងនឹងការសួរចម្លើយអ្នកទោសម្នាក់ឈ្មោះ យ៉ា ។ ឌុច អះអាងថា សំបុត្រ នោះគឺគ្រាន់តែធ្វើឡើងដើម្បីបំភ័យ យ៉ា ឲ្យឆ្លើយសារភាពតែប៉ុណ្ណោះ ព្រោះអត្ថន័យនៅក្នុងសំបុត្របានសរសេរថា បើ យ៉ា នៅតែមិនសារភាព អង្គការបញ្ជាឲ្យយកទៅកម្ទេចចោលតែម្ដង ។ ប៉ុន្តែ ឌុច បន្ថែមថា អង្គការមិនបានធ្វើសំបុត្រនោះទេ គឺខ្លួនជាអ្នកធ្វើជាមួយនឹងសមមិត្តឈ្មោះ ប៉ុន ហើយមិនមានថ្នាក់លើណា បានដឹងពីបញ្ហានេះទេ ។ ឌុច បន្តថា ការធ្វើដូច្នេះគឺដើម្បីបំភ័យ យ៉ា ឲ្យឆ្លើយសារភាពដោយខ្លួនឯង ដោយជៀសវាងការធ្វើទារុណកម្ម ។

## ឆ) សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ

លោក ស្មីត បានបន្តសួរអំពីសិទ្ធិសម្រេចកម្ទេចក្នុងជួរ និង

ក្រៅជួរដោយស្នើឲ្យ ឌុច អានសេចក្ដីសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្ដកម្ពុជា ។ បន្ទាប់ពី ឌុច អានឯកសារនោះចប់ភ្លាម មេធាវីអន្ដរជាតិការពារក្ដីជនជាប់ចោទ ខៀវ សំផន គឺមេធាវី អង់តា ហ្គីសេ បានក្រោកឡើងជំទាស់ដោយអះអាងថា សហព្រះរាជអាជ្ញាបានព្យាយាមបង្ហាញសាក្សីនូវឯកសារដែលសាក្សីធ្លាប់បានអះអាងថា ខ្លួនមិនដែលស្គាល់ ។ បន្ទាប់មកមេធាវីជាតិការពារក្ដី ខៀវ សំផនគឺ លោក គង់ សំអុន បានបន្ថែមលើសហភាគារបស់ខ្លួនដោយអះអាងថា សហព្រះរាជអាជ្ញាបានស្នើឲ្យសាក្សីធ្វើការសន្និដ្ឋានចំពោះអ្វីដែលខ្លួនមិនបានដឹង ។ មេធាវីការពារក្ដី នួន ជា គឺលោក ជេស្ដមេន បានក្រោកឈរ និងគាំទ្រចំពោះការលើកឡើងរបស់ក្រុមមេធាវី ខៀវ សំផន ។ ឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដី លោក ស្មិត បានលើកឡើងថា ឯកសារដែលក្រុមមេធាវីការពារក្ដីធ្វើការជំទាស់នោះគឺត្រូវបានអង្គជំនុំជម្រះសម្រេចរួចហើយ ។ម៉្យាងវិញទៀត ការធ្វើដូចនេះគឺធ្វើឲ្យអង្គជំនុំជម្រះចំណាយពេលវេលាកាន់តែច្រើន ។ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអ្នកនាង លីម៉ា និងលោក ពេជ អង្គ បានគាំទ្រចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា និងថាឯកសារដែលមានយោងនៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយគឺពិតជាអាចទទួលយកបាន ។ ក្រោយពីបានពិភាក្សាគ្នារួចរាល់អង្គជំនុំជម្រះបានបដិសេធការជំទាស់របស់ក្រុមមេធាវីការពារក្ដីទាំងពីរក្រុម ។ ដូច្នេះសហព្រះរាជអាជ្ញាអាចបន្ដប្រើប្រាស់ឯកសារនេះដើម្បីសួរដេញដោល ទៀតបាន ។

លោក ស្មិត បានបន្ដសួរ ឌុច ថាតើ ឌុច ទើបនឹងឃើញ និងអានសេចក្ដីសម្រេចរបស់គណៈមជ្ឈិមបក្សនៅដំណាក់សុីបអង្កេតឬ? ឌុច បានឆ្លើយថា ខ្លួនទើបនឹងឃើញ និងបានអានឯកសារស្ដីពីសេចក្ដីសម្រេចរបស់គណៈមជ្ឈិមនៅក្នុងតំណាក់កាលរបស់ចៅក្រមសុីបអង្កេតពិតប្រាកដមែន ។

សហព្រះរាជអាជ្ញាបានបន្ដសួរដេញដោល ឌុច ពាក់ព័ន្ធនឹងសិទ្ធិសម្រេចកម្ទេច គឺក្នុងជួរ និងក្រៅ ជួរ ។ ឌុច បញ្ជាក់ថា ការកម្ទេចក្រៅជួរ គឺសំដៅលើប្រជាជនសុទ្ធសាធ ហើយនៅមូលដ្ឋានគឺអនុញ្ញាតឲ្យលេខាភូមិភាគមានសិទ្ធិសម្រេច ។

## ជ) វគ្គសិក្សានយោបាយថ្ងៃទី៣០ កញ្ញា ១៩៧៨

បន្ទាប់មកលោក ស្មិត បានសួរ ឌុច ពីការចូលរួមក្នុងវគ្គសិក្សារបស់បក្ស ។ ឌុច ឆ្លើយថា នៅមុនថ្ងៃទី៣០ កញ្ញា ឆ្នាំ១៩៧៨ ខ្លួនធ្លាប់បានចូលរួមវគ្គសិក្សានយោបាយជាមួយនឹង ប៉ុល ពត មិនមែន សុន សេន ទេ ។ នៅក្នុងវគ្គសិក្សានោះ ប៉ុល ពត បានបង្រៀនថា កុំឲ្យហៅប្រជាជន១៧មេសា តទៅទៀត ព្រោះថ្ងៃនោះ [១៧មេសា] គឺជាថ្ងៃជោគជ័យរបស់បក្ស ហើយបានណែនាំដល់មន្ទីរស-២១ មិនឲ្យសួរចម្លើយខ្លាំងបន្ដទៀតទេ ។ ឌុច បន្ដថា ក្រោយមកប្រហែលរយៈពេល៣ថ្ងៃ នួន ជា បានជួបខ្លួន ហើយប្រាប់ថា *“ឥឡូវនេះមិត្ត ឌុច បេះមាគ៌ាសម្បើមខ្លាំងណាស់ហ្ន៎!”* ។ បន្ទាប់ពីបានឮសម្ដីរបស់ នួន ជា ដូច្នេះ ឌុច ក៏បានផ្ដើមសួរចម្លើយអ្នកទោសឡើងវិញ ។ ឌុច បានសន្និដ្ឋានថា វគ្គសិក្សានោះគ្រាន់តែធ្វើឡើងដើម្បីកុំឲ្យអ្នកចូលរួមមានការព្រួយបារម្ភពីការចាប់ខ្លួនប៉ុណ្ណោះ ព្រោះការចាប់ខ្លួនសួរចម្លើយនៅពេលនោះនៅតែបន្ដ ។ បន្ទាប់ពីបានចូលរួមវគ្គសិក្សានយោបាយ ខ្លួននៅតែដាក់ផែនការ និងបន្ដភារកិច្ចសួរចម្លើយបន្ដទៀត ដោយមិនមានការបញ្ជាពីនរណាឡើយ ព្រោះខ្លួនបានជួបនិយាយជាមួយ នួន ជា រួចហើយ ។ ក្រោយមកទៀត ឌុច មិនបានចាំថាថ្ងៃណាឲ្យច្បាស់លាស់នោះទេ ប៉ុន្ដែប្រហែលជានៅថ្ងៃទី៣ ខែមករា ១៩៧៩ នួន ជា បានប្រាប់ខ្លួនថា *“មិត្ត ឌុច ត្រូវតែបញ្ចេញអ្នកទោសទាំងអស់ទៅ”* ។ បន្ទាប់ពីបាននិយាយជាមួយ នួន ជា រួចហើយ ឌុច ក៏បានមកប្រាប់មិត្ត ហ៊ឹ ឲ្យចាត់ការលើបញ្ហានេះ ។ ឌុច បន្ដថា នៅពេលដែលរថក្រោះវៀតណាមចូលមកដល់ផ្លូវមុនីវង្ស មិត្តណាត បានយកចំពុះទង់ចាក់សម្លាប់អ្នកទោសបួននាក់ដែលនៅសល់ក្នុងស-២១ចោលតែម្ដង ។

## ឈ) សេចក្ដីណែនាំទាក់ទងនឹងការប្រើពាក្យ“អង្គការ”

លោក ស្មិត បានបង្ហាញឯកសារស្ដីពីសេចក្ដីណែនាំទាក់ទងនឹងការប្រើប្រាស់ពាក្យ “អង្គការ” និង “បក្ស” ដើម្បីឲ្យ ឌុច បញ្ជាក់ ។ ឌុច អះអាងថា ឯកសារនោះគឺធ្វើឡើងដើម្បីណែនាំឲ្យមានការប្រើប្រាស់ពាក្យទាំងនោះដោយមិនមានការខុសឆ្គង ដោយ ឌុច បានឧទាហរណ៍អំពីស-២១ ដែល ណាត ធ្លាប់បានឲ្យគេហៅខ្លួនថាជាអង្គការ ដែល ឌុច យល់ថាគឺជាការខុសឆ្គងមួយ ព្រោះអង្គការគឺសំដៅតែចំពោះ ប៉ុល ពត ម្នាក់ប៉ុណ្ណោះ ។

### ៣) គោលនយោបាយរបស់បក្សចំពោះខ្មាំង

ពាក់ព័ន្ធនឹងគោលនយោបាយជាក់លាក់របស់បក្សចំពោះខ្មាំង ឌុច បានបញ្ជាក់ថា ឲ្យតែបក្សចាត់ទុកថាជាខ្មាំង គឺត្រូវតែកម្ទេច ។ ប្រភេទមនុស្សដែលបក្សចាត់ទុកថាជាខ្មាំង រួមមាន ពួកសេអ៊ីអា, ពួកកាហ្សេបេ, និងពួកយួនឈ្លានពានលេបទឹកដី និងប្រល័យពូជសាសន៍ ។

### ៤) មន្ទីរបឹងត្របែក

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការចុះទៅចាប់ខ្លួនមនុស្សដោយបុគ្គលិក ស-២១ ឌុច អះអាងថា ភាគច្រើនគឺជាម្ចាស់អង្គភាពជាអ្នកចាប់បញ្ជូនអ្នកទោសមកស-២១ មានតិចតួចប៉ុណ្ណោះដែលបុគ្គលិកស-២១ចេញទៅចាប់ដោយផ្ទាល់ ។ ចំពោះសំណួរពាក់ព័ន្ធនឹងពាក្យថា "បឹងត្របែក" ឌុច បានបញ្ជាក់ជូនសហព្រះរាជអាជ្ញាថា "បឹងត្របែក" សំដៅលើកន្លែងដែលគេដុកពួករណសិរ្សដើម្បីតាមដានចាំមើល និងចាប់កំហុស និងអប់រំកសាងខ្លួនសារជាថ្មី ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ មិន មីន ហៅ ព្រុំ ។ អ្នករណសិរ្ស គឺជាសមាជិករបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឬរណសិរ្សរួបរួមជាតិកម្ពុជា ។ អ្នកទាំងអស់នោះគេមិនចាត់ទុកជាសត្រូវ ហើយក៏មិនចាត់ទុកជាមិត្តដែរ គឺរង់ចាំមើលសកម្មភាពអ្នកទាំងនោះ ។ ឌុចបន្តថា អ្នកដែលគេឃុំនៅបឹងត្របែកគឺមិនត្រូវបានបញ្ជូនមកស-២១ទេ ។

### ៥) សេចក្តីសម្រេចប្រហារជីវិតជនក្បត់ទាំង៧រូប

បន្ទាប់មកសហព្រះរាជអាជ្ញាបានបន្តសួរ ឌុច ទាក់ទងនឹងការសម្រេចសម្លាប់ជនក្បត់ទាំង៧រូប ថាតើ ឌុច បានដឹងពីសេចក្តីសម្រេចនោះតាមវិធីណា? ឌុច បានអះអាងថា ខ្លួនបានស្តាប់ឮតាមវិទ្យុ ។ បន្ទាប់មកលោក ស្មិត បានបង្ហាញឯកសារទាក់ទងនឹងប្រតិចារិករបស់ហ៊្វីបប៊ីស ដែលចុះផ្សាយនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ដើម្បីឲ្យ ឌុច ធ្វើការបញ្ជាក់ ។ ឌុចបំភ្លឺថា ខ្លួនមិនដែលបានឃើញឯកសារនោះទេ ប៉ុន្តែធ្លាប់ឮខ្លឹមសារនៃឯកសារនេះតាមវិទ្យុ ។ បន្ទាប់មកសហព្រះរាជអាជ្ញាបានសួរ ឌុច អំពីថាតើនរណាជាអ្នកបង្កើត និងដាក់ចេញសេចក្តីប្រកាសសម្លាប់ជនក្បត់ទាំង៧នាក់នោះ? ឌុច បានអះអាងថា រាល់សេចក្តីសម្រេចទាំងអស់គឺតែងតែចេញមកពី ប៉ុល ពត មិនមែន ខៀវ សំផន ជាអ្នកសម្រេចនោះទេ ។ ឌុច បញ្ជាក់ប្រាប់សហព្រះរាជអាជ្ញាថា គោលនយោបាយក្នុងការប្រហារជីវិតជនក្បត់ទាំងប្រាំពីររូបពិតជាត្រូវបានយកទៅអនុវត្តន៍ ដោយសាររណសិរ្សរួបរួមជាតិកម្ពុជាបានធានានៅចំពោះមុខឆាកអន្តរជាតិរួចហើយ ។ ឌុច បន្តទៀតថា ពេលដែលប្រកាស អ្នកទាំងនោះមិនត្រូវបានយកមកសម្លាប់ភ្លាមនោះទេ គឺយកមកប្រឈមមុខនឹងតុលាការប៉ុណ្ណោះ ។ ឌុច បំភ្លឺថា ខ្លួនមិនបានដឹងច្បាស់ចំពោះឈ្មោះអ្នកទាំងប្រាំពីរនាក់នោះទេ ព្រោះខ្លួនអាចភ្លេច ។ តាមសំណើរបស់សហព្រះរាជអាជ្ញា ឌុច បានរាប់ឈ្មោះអ្នកទាំងនោះ ប៉ុន្តែឌុចមិនបានចាំអ្នកទី៧ឡើយ ៖

ទី១) លន់ នល់

ទី២) សិរិមតៈ

ទី៣) ចេង ហេង

ទី៤) អ៊ិន តាំ

ទី៥) ឡុង បូរ៉េត

ទី៦) សូស្តែន ហ្វេណង់ដេស និង

ទី៧) លន់ នុន

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលសួរថាតើក្រោយមក ឌុច មានដឹងអំពីជោគវាសនារបស់អ្នកទាំងប្រាំពីរនាក់នោះដែរឬទេ? ឌុច បញ្ជាក់ថា ក្រោយថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ លន់ នល់ បានចាកចេញទៅរស់នៅសហរដ្ឋអាមេរិក ចាប់តាំងពីថ្ងៃទី១ ខែមេសា ១៩៧៥ រីឯ សិរិមតៈ និង ឡុង បូរ៉េត ឌុច បញ្ជាក់ថាខ្លួនមិនបានដឹងនោះទេ ប៉ុន្តែក្រោយមកឮដំណឹងថា ត្រូវបានចាប់ខ្លួននៅមុខស្ថានទូតបារាំង ។ រីឯ



ហ៊ូ នឹម

*លន់ នន់គឺបានបាត់ខ្លួននៅពេលជម្លៀស ។*

## ៧) ចម្លើយសារភាពរបស់ ហ៊ូ នឹម

*បន្ទាប់មកលោកសហព្រះរាជអាជ្ញាបានបង្ហាញចម្លើយសារភាពរបស់ ហ៊ូ នឹម ដែលមានកម្រាស់ជាងមួយពាន់ទំព័រឲ្យ ឌុច ធ្វើការបញ្ជាក់ និងស្នើឲ្យ ឌុច អានឃ្លាមួយដែល ហ៊ូ នឹម បានសរសេរនៅក្រោយពេលចាប់ខ្លួនមកមន្ទីរស-២១ បានមួយថ្ងៃ ។ ឃ្លាដែល ឌុច បានអានពីសំណេររបស់ ហ៊ូ នឹម គឺនៅក្នុងទំព័រ៩២៣ ដល់ ៩២៤ និងមានអត្ថន័យថាៈ*

*« គោរពបក្សកុម្មុយនីស្តកម្ពុជាលើសពីជីវិតខ្ញុំ គោរពបង ប៉ុល, បងនួន, បងវ៉ាន់, បងវន, សមមិត្តខៀវ, សមមិត្ត ហែម ជាទីគោរពស្នេហា » ។*

*បន្ទាប់លោកសហព្រះរាជអាជ្ញារង ស្មឹត បានស្នើឲ្យ ឌុច ធ្វើការបញ្ជាក់អំពីឈ្មោះអ្នកដែល ហ៊ូ នឹម បានសរសេរទៅ ។ ឌុច បំភ្លឺថា បង ប៉ុល គឺ ប៉ុល ពត, បង នួន គឺ នួន ជា, បង វ៉ាន់ គឺ អៀង សារី, បង វន គឺ វន វេត, សមមិត្ត ខៀវ គឺ សុន សេន រីឯសមមិត្ត ហែម គឺខៀវ សំផន ។*



## ៣) ការផ្តល់សក្ខីកម្មរបស់ ឌុច ចំពោះការចោទសួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

*បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានស្តាប់ការផ្តល់សក្ខីកម្មរបស់ ឌុច ដែលចោទសួរដោយតំណាងសហព្រះរាជអាជ្ញាអង្គជំនុំជម្រះបានបន្តបើកសវនាការស្តាប់ការផ្តល់សក្ខីកម្មរបស់ ឌុច ដែលចោទសួរដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយផ្តោតសំខាន់លើអង្គហេតុទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

### ៣.១) ការចោទសួរដោយមេធាវី ហុង គីមសួន ចំពោះ ឌុច



ហុង គីមសួន

*មុននឹងចូលដល់សំណួររបស់ខ្លួន លោកមេធាវី ហុង គីម សួន បានថ្លែងនូវអំណរគុណចំពោះ ឌុច ដែលបានសហការណ៍ជាមួយតុលាការក្នុងការឆ្លើយសំណួរ ក៏ដូចជាការព្រមទទួលស្គាល់អង្គហេតុជាច្រើន និងការសម្តែងនូវវិប្បដិសារីចំពោះប្រជាជនដែលបានរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ហុង គីម សួន បន្ថែមថា នេះសបញ្ជាក់ឲ្យឃើញថា ពិតជាមានអំពើឧក្រិដ្ឋកើតឡើងនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប្រាកដមែន ។ បន្ទាប់ពីនោះមក លោក ហុង គីម សួន បានសួរ ឌុច ដោយផ្តោតសំខាន់លើអង្គហេតុដែលកើត*

នៅក្រសួងការបរទេស ។

ពាក់ព័ន្ធនឹងក្រសួងការបរទេស ឌុច បានផ្តល់សក្ខីកម្មថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជនជាប់ចោទ អៀង សារី មានតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស ។ អំឡុងពេលនោះ មន្ត្រីទូតនិងភ្នាក់ងាររបស់ក្រសួងការបរទេសទាំងអស់ត្រូវបានបញ្ជូនមកស្រុកខ្មែរវិញ ហើយមានមួយចំនួនត្រូវបានចាប់បញ្ជូនទៅមន្ទីរសន្តិសុខស-២១ ដូចជា មាយ ទូច, ហេង សុខឃាង...។ ក្នុងនោះក៏មានបញ្ញាជនមួយចំនួនទៀតដូចជា ចៅ សេង និង ភ៉ាន់ពីនី ។ ឌុច បញ្ជាក់ថា ចៅ សេង គឺជាជនចម្រើនម្នាក់ដែលប្រឆាំងនឹងរបប លន់ នល់ ។ ក្នុងខែសីហា ឆ្នាំ១៩៧៧ សុន សេន ប្រាប់ខ្លួន ថានឹងនាំ ចៅ សេង មកមន្ទីរ ស-២១ ។ ក្រោយមក នួន ជា បានបញ្ជាឲ្យសម្លាប់ ចៅ សេង ។ ដោយសារតែ ចៅ សេង ជាមនុស្សល្បីម្នាក់ ដូចនេះមុនពេលសម្លាប់ ចៅ សេង គឺត្រូវប្តូរឈ្មោះមកជា ចៅ ដុន វិញដើម្បីជាការបិទបាំងភ្នែកអន្តរជាតិ ។ ឌុច បន្ថែមថា *"រាល់ការសម្រេចចាប់បុគ្គលណាម្នាក់គឺចេញមកពីមជ្ឈិម ប៉ុន្តែជាទូទៅគឺជាការសម្រេចរបស់ ប៉ុល ពត ហើយជួនកាលជាការសម្រេចរបស់នួន ជា"* ។

**កំណត់សម្គាល់** ៖ បន្ទាប់បានសួរសំណួរមួយចំនួន លោក ហុង គីមសួន បានបង្ហាញឯកសារមួយចំនួនទៀតដូចជា ឯកសារកំណត់ហេតុលើកទី២៤ ដែល ឌុច បានផ្តល់សក្ខីកម្មជូនចៅក្រមស៊ើបអង្កេតស្តីពីការបញ្ជូនលិខិតនានារបស់ អៀង សារី ទៅមន្ទីរ ស-២១ ។ តែលោកមេធាវីមិនបានសួរសំណួរណាមួយពាក់ព័ន្ធនឹងឯកសារនេះឡើយ ។ ឯកសារមួយទៀត គឺជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមស្តីពី "បញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលក្នុងឯកសារនេះមាននិយាយពីសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ ។ ឯកសារនេះក៏លោកមេធាវីមិនបានសួរបញ្ជាក់លើខ្លឹមសារដែលមាននៅក្នុងឯកសារនេះដែរ ពោលគឺលោកគ្រាន់តែសួរ ឌុច ថា ធ្លាប់បានស្គាល់ឯកសារនេះដែរឬទេ ។ ដោយឃើញការអនុវត្តបែបនេះ លោកមេធាវី ម៉ៃឃើល ខារណាវ៉ាស់ បានលើកឡើងថា លោកមេធាវី ហុង គីមសួន មិនអាចបង្ហាញឯកសារឲ្យ ឌុច ពិនិត្យ និងមិនបានសួរសំណួរណាមួយពាក់ព័ន្ធនឹងឯកសារនោះសោះ ដែលការធ្វើបែបនេះធ្វើឲ្យមេធាវីការពារក្តីពិបាកយល់ថាលោកមេធាវី ហុង គីមសួន មានគោលបំណងអ្វីនោះទេ ហើយខ្លួនក៏មានការលំបាកក្នុងការឆ្លើយតបដែរ ។ បន្ថែមលើ




នេះ លោកប្រធានអង្គជំនុំជម្រះបញ្ជាក់ថា ប្រសិនបើ លោក ហុង គីមសួន គ្រាន់តែមានបំណងសួរបញ្ជាក់ ឌុច ថាបានស្គាល់ឯកសារទាំងនោះដែរឬទេអញ្ចឹងមែននោះ គឺមិនចាំបាច់ឡើយ ព្រោះសំណួរប្រភេទនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាសួររួចហើយ ។

## ៣.២) ការចោទសួរដោយមេធាវី លីម៉ា ង្វៀន ចំពោះ ឌុច



ក្នុងការសួរដេញដោល ឌុច មេធាវី លីម៉ា ផ្ញៀន បានបង្ហាញឯកសារមួយចំនួន រួមទាំងចម្លើយសារភាពរបស់អ្នកទោសដើម្បីឲ្យ ឌុច ធ្វើការបកស្រាយ ឬធ្វើការកត់សម្គាល់ ខ្លីៗ ។

នៅពេលចាប់ផ្តើមដំបូងមេធាវី លីម៉ា បានសួរដោយផ្តោតសំខាន់លើកងពល៥០២ ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់នាយសេនាធិការកងទ័ពនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាការឆ្លើយតប ឌុច ផ្តល់សក្ខីកម្មថា កងពល៥០២ គឺជាកងទ័ពអាកាសដែលមាន ស៊ូ ម៉េត ជាប្រធានកងពល ។ ភ្លាមៗនោះលោក ខណោ វ៉ាស់ លើកឡើងថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីកំពុងសួរសំណួរដែលមិនជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២ ពោលគឺសំណួរទាំងនេះជាប់ពាក់ព័ន្ធនឹងបុគ្គលមួយចំនួននៅក្នុងសំណុំរឿង០០៣ និង០០៤ តែប៉ុណ្ណោះ ។ ជាការឆ្លើយតប មេធាវី លីម៉ា បានលើកឡើងថា សំណួរទាំងនេះគឺជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនិងប្រព័ន្ធទំនាក់ទំនងការងារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងតាមរយៈខ្សែបណ្តោយ និងខ្សែទទឹង ។ បន្ទាប់ពីមានការផ្តល់សំអាងហេតុដូចនេះ លោកប្រធានអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីសួរបន្តអំពីបញ្ហាទាំងនេះដោយបានរំឭកដល់មេធាវីថា គប្បីមានការប្រុងប្រយ័ត្នក្នុងការបញ្ចេញឈ្មោះបុគ្គលណាម្នាក់ ព្រោះបុគ្គលនោះអាចក្លាយជាកម្មវត្ថុនាំមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនៅក្នុងសំណុំរឿង០០២ដែលត្រូវទទួលបានសិទ្ធិការពារអត្តសញ្ញាណផ្ទាល់ខ្លួនតាមអនុសញ្ញាស្តីពីការការពារសាក្សីនៅក្នុងរឿងព្រហ្មទណ្ឌ ។

បន្ទាប់មកមេធាវីបានដាក់បង្ហាញឯកសារមួយចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ ដែលឯកសារនេះត្រូវបាន ស៊ូ ម៉េត សរសេរបញ្ជូនមកមន្ទីរស-២១ ។ ឯកសារនេះនិយាយពីការចាប់បញ្ជូនមនុស្សមកមន្ទីរស-២១ តាមសេចក្តីសម្រេចរបស់ថ្នាក់លើ ។ បុគ្គលទាំងនោះរួមមានឈ្មោះ ផន, សៀ, ផល, ម៉ុន... ដែលត្រូវបានចាប់ដោយសារតែយោងតាមចម្លើយសារភាពរបស់ឈ្មោះ សោម នៅមន្ទីរម-៦៣ ។ ឯកសារនេះក៏មាននិយាយពីការស្នើសុំចាត់វិធានការបន្ថែមទៀត ចំពោះឈ្មោះបុគ្គលមួយចំនួនទៀតដែលមិនទាន់បានចាប់ខ្លួនបន្ថែមទៀត ។

ឆ្លងទៅឯកសារមួយផ្សេងទៀត មេធាវី លីម៉ា បានដកស្រង់ខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ដែលចែងថា "កម្ពុជាប្រជាធិបតេយ្យប្រកាន់ខ្ជាប់នូវនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធ មិនអនុញ្ញាតឲ្យបរទេសណាមកតាំងមូលដ្ឋានសឹកនៅក្នុងប្រទេសកម្ពុជាដាច់ខាត ។ តស៊ូដាច់ខាតនឹងការជ្រៀតជ្រែកគ្រប់បែបយ៉ាងពីខាងក្រៅមកក្នុងកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា ។ តស៊ូដាច់ខាតនឹងអំពើវិទ្ធង្សនា ការឈ្លានពានគ្រប់បែបយ៉ាងពីខាងក្រៅមកលើប្រទេសកម្ពុជា ទោះបីជាវិទ្ធង្សនា ឬឈ្លានពានខាងយោធាក្តី ខាងនយោបាយក្តី ខាងវប្បធម៌ក្តី ខាងសេដ្ឋកិច្ចក្តី ខាងសង្គមក្តី ខាងការទូតក្តី ឬក៏តាមរូបភាពយកនាមថាមនុស្សក្តី" ។ បន្ទាប់មកមេធាវីបានសួរ ឌុច ថា បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តចំពោះចំណុចទាំងនេះដែរឬទេ? ឌុចបញ្ជាក់ថា តាមការអនុវត្តនិងការមើលឃើញជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្តកម្ពុជាពិតជាបានអនុវត្តចំណុចទាំងនេះយ៉ាងខ្ជាប់ខ្ជួន និងដាច់ខាតបំផុត ។ ក្នុងការការពារអធិបតេយ្យរបស់ជាតិ កងពល១៦៤ មានតួនាទីនិងភារកិច្ចការពារដែនសមុទ្ររបស់កម្ពុជា ។ ប្រធានកងពលនេះ គឺឈ្មោះ មាស មុត ដែលពេលនោះ មាស មុត ទើបតែក្លាយជាសមាជិករបស់គណៈមជ្ឈិម ។ តាមរយៈកងពលនេះ ប្រជាជនថៃជាច្រើនត្រូវបានចាប់មកមន្ទីរស-២១ ដោយសារបានលួចចូលនេសាទក្នុងដែនសមុទ្រកម្ពុជា ។ ឌុចបញ្ជាក់ថា ការចាប់អ្នកនេសាទជនជាតិថៃនេះ គឺចេញមកពីបញ្ជារបស់ សុន សេន ។

ចុងក្រោយ មេធាវីបានសួរដោយផ្តោតសំខាន់អំពីការចាប់និងសម្លាប់អ្នកទោសបរទេស៤រូប ដែលត្រូវបានគេចោទថាជាចារបុរស ។ ឌុច បានបញ្ជាក់ថា បុរសទាំង៤រូបនេះបានចូលមកប្រទេសកម្ពុជាដោយគ្មានការអនុញ្ញាតពីក្រសួងការបរទេស ដូចនេះបក្សបានចាត់ទុកថាជាចារបុរសដែលមានបទពិសោធខាងធ្វើចារកម្ម ។ អ្នកទោសទាំង៤នាក់នេះត្រូវបានសួរយកចម្លើយដោយយកចិត្តទុកដាក់បំផុត ហើយបន្ទាប់ពីទទួលបានចម្លើយ នួន ជា បានបញ្ជាឲ្យខ្លួននាំយកអ្នកទោសទាំង៤រូបនេះទៅសម្លាប់ចោល ។

ពាក់ព័ន្ធនឹងចារកម្មនេះ មេធាវីបានដាក់បង្ហាញឯកសារទស្សនាវដ្តីទង់បដិវត្តមួយដែលមានចំណងជើងថា "តើអ្វីជាទំនាស់រវាងបដិវត្តយើងនិងការប្រឆាំងបដិវត្តតើជាទំនាស់អ្វី?" ។ នៅក្នុងឯកសារនេះមាននិយាយលម្អិតពីការកំណត់សត្រូវស្លាប់រស់

របស់បក្សកុម្មុយនីស្តកម្ពុជា រួមមាន យួន, សេអ៊ីអា និង កាហ្សេបេ ដែលត្រូវតែកម្ទេចចោល ។ ឌុច បានបញ្ជាក់ថា ពាក្យសេអ៊ីអា ដែលគេប្រើនៅពេលនោះ គឺសំដៅដល់ប្រជាជនខ្មែរដែលរស់នៅក្នុងទឹកដីរបស់ខ្លួន តែធ្វើការងារក្រោមការចាត់តាំងពីភ្នាក់ងាររបស់សហរដ្ឋអាមេរិក ហើយជាទូទៅគេហៅថា ភ្នាក់ងារសេអ៊ីអា ។ ចំណែកពួកយួន គឺបក្សកុម្មុយនីស្តកម្ពុជាសំដៅដល់យួនដែលរស់នៅក្នុងទឹកដីខ្មែរ ឬខ្មែរដែលមាននិន្នាការយួន ។ និយាយឲ្យខ្លីគឺសំដៅដល់កម្មាភិបាលខ្មែរក្រហមដែលជាអតីតកម្លាំងរបស់បក្សប្រជាជនបដិវត្តកម្ពុជា ។ ឌុច បញ្ជាក់យ៉ាងច្បាស់ថា យួន, សេអ៊ីអា និងកាហ្សេបេ ត្រូវបានចាត់ទុកថាជាសត្រូវស្លាប់រស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលសត្រូវទាំងនេះត្រូវតែសម្លាប់ចោល ។

**កំណត់សម្គាល់** ៖ មុនពេលចាប់ផ្តើមសួរ ឌុច មេធាវី លីម៉ាឡៀន ស្នើសុំអង្គជំនុំជម្រះបញ្ជាក់ឲ្យបានច្បាស់ថា ខ្លួននៅសល់ពេលប៉ុន្មានទៀត ព្រោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេល១ថ្ងៃពេញ តែពេលនេះត្រូវបានផ្តល់ជូនព្រះរាជអាជ្ញាអស់មួយម៉ោងទៅហើយ ដូចនេះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគប្បីទទួលបានពេល១ម៉ោងនេះវិញដែរឬទេ ។ លោក ខាណាវ៉ាស់ ធ្វើការជំទាស់ចំពោះការស្នើសុំនេះ ដោយលោកផ្តល់ហេតុផលថា កាលពីមុនមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសុំពេលតែ១ថ្ងៃប៉ុណ្ណោះ ហើយបានចែកពេលនេះ១ម៉ោងជូនតំណាងសហព្រះរាជអាជ្ញា តែឥឡូវបែរជាមកសុំពេលបន្ថែម១ម៉ោងវិញ ដែលការធ្វើបែបនេះគឺមិនត្រឹមត្រូវ ។ អង្គជំនុំជម្រះសម្រេចទទួលយកការជំទាស់របស់លោក ខាណាវ៉ាស់ ហើយតម្រូវឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រើប្រាស់ពេលវេលារបស់ខ្លួនដែលនៅសល់តែប៉ុណ្ណោះ ។ ប៉ុន្តែនៅក្នុងអំឡុងពេលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរ ឌុច គឺមានបញ្ហាផ្សេងៗជាច្រើនចេញពីដំណើរការនីតិវិធីដែលធ្វើឲ្យខាតបង់ពេលវេលាជាច្រើនរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយឃើញសភាពបែបនេះ លោកស្រីមេធាវី ស៊ីមូណូហ្សុត ស្នើសុំជាថ្មីទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្លួនមានពេលវេលា១ម៉ោងបន្ថែមទៀតដើម្បីជាការប៉ះប៉ូវ ។ សំណើនេះត្រូវបានលោក ខាណាវ៉ាស់ គាំទ្រ ដោយលោកបានផ្តល់សំអាងដូចគ្នានឹងលោកស្រីមេធាវីដែរ ។ ដោយមានការស្នើសុំ និងផ្តល់សំអាង ហេតុដូចនេះ ប្រធានអង្គជំនុំជម្រះសម្រេចផ្តល់ពេលវេលា១ម៉ោងបន្ថែមទៀតជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

បន្ទាប់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបបញ្ចប់សំណួររបស់ខ្លួនដោយសារអស់ពេល អង្គជំនុំជម្រះបានបន្តសួរ ឌុច នូវសំណួរមួយចំនួនពាក់ព័ន្ធនឹងការកំណត់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា និងសិទ្ធិក្នុងការសម្រេចកម្ទេចខ្មាំង ។ នៅពេលចាប់ផ្តើមដំបូង លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ សួរបញ្ជាក់នូវអ្វីដែល ឌុច បានឆ្លើយជូនតំណាងសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការបែងចែកខ្មាំង ។ ជាថ្មីម្តងទៀត ឌុច បញ្ជាក់ថា មាគ៌ានយោបាយជាយុទ្ធសាស្ត្រក្នុងការបែងចែកខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុម័តក្នុងមហាសន្និបាតបក្សលើកទីមួយក្នុងឆ្នាំ១៩៦០ ។ ក្នុងឆ្នាំ១៩៦៧ ខ្លួនបានរៀនសូត្រពីទ្រឹស្តីក្នុងការកំណត់ខ្មាំង បន្ទាប់មកក្នុងឆ្នាំ១៩៧១ ចាប់ផ្តើមមានការណែនាំឲ្យអនុវត្តជាក់ស្តែង ។ ពេលគឺបុគ្គលទាំងឡាយណាដែលរត់ចូលតំបន់រំដោះត្រូវបានចាត់ទុកថាជាគិញ ឬខ្មាំងរបស់បក្សដែលត្រូវសម្លាប់ចោលបន្ទាប់ពីសួរចម្លើយរួច ។ ក្រោយមកនៅក្នុងអំឡុងឆ្នាំ១៩៧៣ ប្រជាជនរស់នៅក្នុងតំបន់ដែលបក្សទើបតែរំដោះបាន ក៏ត្រូវបានចាត់ទុកថាជាខ្មាំងដែលត្រូវមានការត្រួតពិនិត្យយ៉ាងតឹងរឹង ពេលទាំងអ្នកដែលរត់ចូលនិងរត់ចេញពីតំបន់រំដោះនឹងត្រូវបានចាត់ទុកថាជាខ្មាំងដែលត្រូវសម្លាប់ចោល ។

បន្ទាប់មក លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ ដកស្រង់ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលត្រូវបានអនុម័តក្នុងសមាជជាតិនៅថ្ងៃទី២៤-២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ក្រោមអធិបតីភាពរបស់ ខៀវ សំផន ។ សេចក្តីថ្លែងការណ៍នោះបានលើកឡើងថា “...ជនរួមជាតិគ្រប់ស្រទាប់វណ្ណៈទាំងអស់ដែលរស់នៅទីក្រុងភ្នំពេញ ហើយនឹងស្ថិតនៅក្នុងទីរួមស្រុកដែលស្ថិតនៅក្រោមការក្តោបក្តាប់របស់ខ្មាំង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ មេទាហាន មន្ត្រីនគរបាលទាំងអស់ដែលត្រៀមខ្លួនក្នុងការចាកចេញពីជួរខ្មាំង ហើយនឹងត្រៀមខ្លួនចូលរណសិរ្សរួបរួមជាតិនេះ មិនចាំបាច់ព្រួយអំពីជីវភាពរស់នៅ និងការងារនោះទេ យើងនឹងធានាទាំងស្រុងចំពោះចំណុចទាំងអស់នេះ” ។ លោកចៅក្រមបានសួរបញ្ជាក់ថា តើបក្សកុម្មុយនីស្តកម្ពុជា

ពិតជាមានគោលនយោបាយធានាបែបនេះដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ ឌុច បញ្ជាក់ថា "ខ្ញុំសូមនិយាយមួយម៉ាត់ថាគ្មានទេ" ។



ហ្សង់ម៉ាក ឡាវ៉េញ

សំណួរចុងក្រោយគឺលោកចៅក្រម ឡាវ៉េញ ផ្តោតលើតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ដែលជាមនុស្សជិតស្និទ្ធរបស់ ប៉ុល ពត ។ ឌុច បញ្ជាក់ថា ខៀវ សំផន គឺជាមនុស្សម្នាក់ដែលនៅជាប់ជាមួយ ប៉ុល ពត ។ ខៀវ សំផន ជាអ្នកទទួលបន្ទុកក្នុងការគ្រប់គ្រងរាល់ឯកសារទាំងអស់របស់ ប៉ុល ពត ពោលរាល់ឯកសារសេចក្តីសម្រេចសំខាន់ៗដែល ប៉ុល ពត បានធ្វើគឺរក្សាទុកជាមួយ ខៀវ សំផន ។ ឬនិយាយម្យ៉ាងទៀតថា រាល់ឯកសារដែលរក្សាទុកនៅថ្នាក់មជ្ឈិមគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ខៀវ សំផន ។ ពាក់ព័ន្ធ ខៀវ សំផន ប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានសួរ ឌុច ថា "ប្រសិនបើគ្រប់មនុស្សកម្មាភិបាលបុគ្គលិកនៃមន្ទីរជុំវិញមជ្ឈិមដែលមានបញ្ហា ហើយត្រូវបានចាប់ខ្លួនបញ្ជូនមកឃុំឃាំងសួរចម្លើយ ហើយនឹងកម្ទេចនៅស-២១ ដែលលោកសាក្សីបង្ហាញគ្រួសៗមុននេះ ថាតើអ្នកណាមានសិទ្ធិសម្រេចឲ្យកម្ទេចដូច្នេះ?" ។ ឆ្លើយតបនឹងសំណួរនេះ ឌុច ផ្តល់សក្ខីកម្មថា "ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច ។ មានន័យថាគឺត្រូវ ខៀវ សំផន ជាអ្នកសម្រេច" ។

### ៤) ការផ្តល់សក្ខីកម្មរបស់ ឌុច ចំពោះការចោទសួររបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ

បន្ទាប់ពីបញ្ចប់ការសួរសំណួររបស់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងការសួរសំណួរបន្ថែមដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉េញ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីក្រុមសួរដេញដោល ឌុច អំពីការយល់ដឹងនៃរបបកម្ពុជាប្រជាធិបតេយ្យ រចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ ចោទ ។

### ៤.១) ការចោទសួរដោយមេធាវីការពារក្តីរបស់ នួន ជា ចំពោះ ឌុច

ដូចបានបញ្ជាក់រួចមកហើយថា អង្គហេតុដែលនឹងត្រូវយកមកពិភាក្សានៅក្នុងសវនាការវគ្គទី២ គឺពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាយ៉ាងណាក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា រួមមានលោកមេធាវី ម៉ៃឃើល ផេស្គមេន លោកមេធាវី ហ្សាស្តើ ប៉ៅ និងលោកមេធាវី សុន អរុណ បានចោទសួរ ឌុច លើបញ្ហាទាំងនេះតិចតួចបំផុត ។ អ្វីដែលក្រុមមេធាវីទាំងនេះសួរផ្តោតសំខាន់នោះគឺ ភាពអាចទុកចិត្តបានចំពោះ ឌុច ក្នុងការផ្តល់សក្ខីកម្ម ។

ភាពអាចទុកចិត្តបានចំពោះ ឌុច ក្នុងការផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ គឺជាបញ្ហាសំខាន់បំផុត ។ ដូចបានដឹងស្រាប់ហើយថា ឌុច បានឆ្លើយនឹងសំណួរជាច្រើនរបស់តំណាងសហព្រះរាជអាជ្ញានិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលចម្លើយទាំងនេះស្ទើរតែទាំងស្រុងគឺដាក់បន្ទុកលើជនជាប់ចោទ ។ ដូចនេះប្រសិនបើរកឃើញថា ឌុច បានផ្តល់សក្ខីកម្មដោយមិនអាចជឿជាក់បានទេនោះ អាចនាំឲ្យអង្គជំនុំជម្រះពិចារណាលើតម្លៃ ឬទម្ងន់នៃភស្តុតាងដែល ឌុច បានផ្តល់សក្ខីកម្មទាំងអស់ ។

#### ៤.១.១) ការចោទសួរដោយមេធាវី ម៉ៃឃើល ផេស្គមេន

សំណួរជាច្រើនដែលលោកមេធាវី ម៉ៃឃើល ផេស្គមេន លើកមកចោទសួរ ឌុច គឺក្នុងគោលបំណងបង្ហាញពីភាពមិនស្មោះត្រង់របស់ ឌុច ក្នុងការផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ ជាក់ស្តែងលោកមេធាវីបានលើកឡើងថា ឌុច ផ្តល់សក្ខីកម្មដោយមិនស្មោះត្រង់ជូនអង្គជំនុំជម្រះ ។ ជាទូទៅគឺលោក ផេស្គមេន សួរចង់ដឹងពីសកម្មភាពរបស់ ឌុច ទាំងនៅមុននិងក្នុងកំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ដែលចម្លើយទាំងនេះគឺភាគច្រើនអាចធ្វើឲ្យសាក្សី

ឆ្លើយដាក់បន្ទុកលើខ្លួនឯង ។ ប៉ុន្តែទោះបីជាយ៉ាងណាសំណួរទាំងនេះត្រូវបាន ឌុច ប្រើប្រាស់សិទ្ធិមិនឆ្លើយតប ។ បន្ថែមលើនេះតំណាងសហព្រះរាជអាជ្ញានិងអង្គជំនុំជម្រះបានធ្វើអន្តរាគមន៍មិនឲ្យ ឌុច ឆ្លើយតប ។


ម៉ៃឃើល ផេស្តមេន

ក្រៅពីសំណួរដែលអាចធ្វើឲ្យសាក្សីឆ្លើយដាក់បន្ទុកលើខ្លួនឯងលោក ផេស្តមេន បានសួរ ឌុច ជាច្រើនពាក់ព័ន្ធនឹងការធ្វើចំណាររបស់មេដឹកនាំខ្មែរក្រហមលើឯកសារចម្លើយសារភាពរបស់អ្នកទោស ឬចំណារបញ្ហាផ្សេងៗដែលធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមលើនេះមួយចំណុចទៀត លោក ផេស្តមេន បានសួរផ្តោតលើការវាយរំដោះយកទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ដែលការរំដោះនេះត្រូវបានដឹកនាំទ័ពដោយបុគ្គលមួយចំនួនមានឋានៈជាមេបញ្ជាការកងទ័ព អនុលេខាកងពល ហើយបច្ចុប្បន្នអ្នកទាំងនោះមានមួយចំនួននៅមានជីវិតនៅឡើយ ។

### ក) ភាពស្មោះត្រង់ និងសិទ្ធិមិនឆ្លើយសំណួររបស់ ឌុច

សំណួរដែលលោកមេធាវី ម៉ៃឃើល ផេស្តមេន យកមកចោទសួរដើម្បីបញ្ជាក់ពីភាពមិនស្មោះត្រង់របស់ ឌុច ក្នុងការផ្តល់សក្ខីកម្ម និងការរក្សាសិទ្ធិមិនឆ្លើយតបរបស់ ឌុច ចំពោះសំណួរទាំងនេះ គឺជាចំណុចដែលមានការជជែកយ៉ាងច្រើនសម្រាប់ភាគីក្នុងរឿងក្តី ។

សំណួរចាប់ផ្តើមដំបូង គឺលោក ផេស្តមេន ចោទសួរថាតើ ឌុច មានភាពស្មោះត្រង់ក្នុងការផ្តល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេត ចៅក្រមជំនុំជម្រះនៅក្នុងសំណុំរឿង០០១ រួមទាំងព្រះរាជអាជ្ញា និងចៅក្រមនៃតុលាការយោធារបស់កម្ពុជា និងការផ្តល់បទសម្ភាសន៍ជាមួយ គ្រីស្តូប ប៉េហ្ស, នីកដុនឡុប និងលោក នេតថៃយើដែរឬទេ? ឆ្លើយតបនឹងសំណួរទាំងនេះ ឌុច បញ្ជាក់ថាអ្វីដែលខ្លួនធ្លាប់បាននិយាយប្រាប់អ្នកទាំងនោះគឺសុទ្ធតែការពិតទាំងអស់ តែបដិសេធមិនព្រមទទួលស្គាល់បទសម្ភាសន៍ដែលខ្លួនបានធ្វើជាមួយលោក នីកដុនឡុប និងលោក នេតថៃយើ ឡើយ ។ ឌុច បញ្ជាក់ថា *"សូមជម្រាបលោកប្រធាន ពីរនាក់នេះយកពាក្យខ្ញុំមួយម៉ាត់ពីរម៉ាត់ទៅបំភ្លៃច្រើនណាស់ ។ អ្នកកាសែតពីររូបនេះអត់យកជាការបានទេ ។ ខ្ញុំបដិសេធការអត្ថាធិប្បាយរបស់អាពីរនាក់នេះ"* ហើយស្នើសុំមេធាវីឲ្យដកស្រង់យកតែសម្តីណាដែលខ្លួនបានផ្តល់ជូនអ្នកដែលមានសមត្ថកិច្ចតាមច្បាប់តែប៉ុណ្ណោះ ។

បន្ទាប់ពី ឌុច បង្ហាញជំហរបែបនេះ លោក ផេស្តមេន បានចោទសួរបន្តថាតើធ្លាប់ធ្វើទារុណកម្ម ឬសម្លាប់មនុស្សនៅមន្ទីរម-១៣ដែរឬទេ? សំណួរនេះត្រូវបាន ឌុច បដិសេធមិនឆ្លើយតបដោយអះអាងថា គឺជាសំណួរដែលអាចធ្វើឲ្យខ្លួនឆ្លើយដាក់បន្ទុកលើខ្លួនឯង ។ ឆ្លើយតបនឹងការបដិសេធនេះ លោក ផេស្តមេន លើកឡើងថា ឌុច មានកាតព្វកិច្ចត្រូវតែឆ្លើយតបនឹងសំណួររបស់ខ្លួន ព្រោះ ឌុច ត្រូវបានតុលាការកំពូលកាត់ទោសឲ្យមានពិរុទ្ធភាពរួចហើយ ។ ដូច្នេះ ឌុច មិនអាចប្រើប្រាស់សិទ្ធិមិនឆ្លើយសំណួរបានឡើយ ហើយស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជា ឌុច ឲ្យឆ្លើយនឹងសំណួររបស់ខ្លួន ។ ជាការឆ្លើយតប ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បញ្ជាក់ជូនលោក ផេស្តមេន ក៏ដូចជាភាគីផ្សេងៗ ទៀតថា ឌុច មកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ហើយសាក្សីមានសិទ្ធិមិនឆ្លើយនឹងសំណួរទាំងឡាយណាដែលអាចនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដែលសិទ្ធិទាំងនេះត្រូវបានអង្គជំនុំជម្រះបញ្ជាក់ប្រាប់សាក្សីក៏ដូចជាភាគីផ្សេងៗ ទៀតរួចមកហើយមុនពេល ឌុច មកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ ភ្លាមៗនោះ មេធាវីរបស់ជនជាប់ចោទ អៀង សារី គឺ លោក ម៉ៃឃើល ខាណាវ៉ាស់ បានលើកឡើងថាតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដា គឺក្នុងករណីដែលជនជាប់ចោទនោះត្រូវបានតុលាការកំពូលសម្រេចឲ្យមានពិរុទ្ធភាពរួច

ហើយ ជនជាប់ចោទរូបនោះនឹងត្រូវបង្ខំឲ្យឆ្លើយបាន ប្រសិនបើមិនព្រមឆ្លើយសំណួរនោះ អង្គជំនុំជម្រះមានសិទ្ធិដាក់ទណ្ឌកម្មបាន ។ លោក ខាណាវ៉ាស់ បានលើករឿងក្តីមួយដែលមានជនជាប់ចោទឈ្មោះ យូហ៊្កីក ត្រូវបានតុលាការឲ្យមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីបន្ទាប់ពីជនជាប់ចោទរូបនេះត្រូវបានតុលាការសម្រេចឲ្យមានពិរុទ្ធភាពជាស្ថាពរ ។ ជនជាប់ចោទរូបនេះបានប្រើប្រាស់សិទ្ធិមិនឆ្លើយនឹងសំណួរដូចគ្នានេះ ក៏ប៉ុន្តែត្រូវបានអង្គជំនុំជម្រះដាក់ទណ្ឌកម្មដោយចោទថា ការធ្វើបែបនេះគឺជាការប្រមាថដល់តុលាការ ។ ឆ្លើយតបនឹងការលើកឡើងនេះ សហព្រះរាជអាជ្ញារងអន្តរជាតិ គឺលោក វីល្លៀម ស្មីត បញ្ជាក់ថា ឌុច ត្រូវបានអង្គជំនុំជម្រះសម្រេចឲ្យមានពិរុទ្ធភាពចំពោះតែអំពើឧក្រិដ្ឋដែលកើតឡើងនៅមន្ទីរសន្តិសុខស-២១ គឺមិនបានសម្រេចពីអំពើឧក្រិដ្ឋដែលកើតនៅមន្ទីរម-១៣ឡើយ ។ ចំណែកសំណួររបស់លោក ដេស្តមេន គឺពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋនៅមន្ទីរម-១៣ ដូចនេះ ឌុច មានសិទ្ធិមិនឆ្លើយនឹងសំណួរទាំងនេះ ដើម្បីជៀសវាងការចោទប្រកាន់របស់សហព្រះរាជអាជ្ញានៅពេលអនាគត ។ ក្រោយពីបានស្តាប់ការលើកឡើងរបស់ភាគី លោកចៅក្រម និល ណុន បានបញ្ជាក់ជាថ្មីម្តងទៀតថា សាក្សីមានសិទ្ធិមិនឆ្លើយតបសំណួរលើអង្គហេតុទាំងឡាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង លើកលែងតែអង្គហេតុដែលកើតនៅមន្ទីស-២១ ដែល ឌុច មានកាតព្វកិច្ចត្រូវតែឆ្លើយ ព្រោះអង្គហេតុទាំងនេះត្រូវបានតុលាការវិនិច្ឆ័យរួចហើយ ហើយអង្គជំនុំជម្រះមិនអាចចោទប្រកាន់ជាថ្មីទៀតឡើយ ដោយយោងតាមគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ។ ដោយឡែក អង្គហេតុដែលកើតនៅមន្ទីរម-១៣ អង្គជំនុំជម្រះមិនទាន់បានវិនិច្ឆ័យទោសលើ ឌុច នៅឡើយ ។ ដូច្នេះ ឌុច មានសិទ្ធិមិនឆ្លើយតបនឹងសំណួរទាក់ទងនឹងអង្គហេតុទាំងឡាយដែលកើតនៅមន្ទីរម-១៣ ប្រសិនបើការឆ្លើយតបនឹងសំណួរទាំងនោះអាចបណ្តាលឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។

**កំណត់សម្គាល់**: ទោះបីជាប្រធានអង្គជំនុំជម្រះបញ្ជាក់យ៉ាងច្បាស់ដូច្នេះក្តី លោក ដេស្តមេន នៅតែបន្តសួរពីទង្វើដែលអាចចោទប្រកាន់ ឌុច នៅមន្ទីរម-១៣ ដោយលោក ដេស្តមេន បានអះអាងថា ខ្លួនមានសិទ្ធិសួរបញ្ហាទាំងនេះ ទោះបីសាក្សីប្រើប្រាស់សិទ្ធិមិនឆ្លើយតបនឹងសំណួរក៏ដោយ ។ ទោះបីជាយ៉ាងណាសំណួរទាំងនេះត្រូវបាន ឌុច បដិសេធមិនឆ្លើយតបជាញឹកញាប់ ហើយត្រូវបានអង្គជំនុំជម្រះ សម្រេចមិនឲ្យ ឌុច ឆ្លើយ ។

បន្ទាប់ពីបញ្ហាពាក់ព័ន្ធសិទ្ធិមិនឆ្លើយតបនឹងសំណួររបស់សាក្សីត្រូវបានដោះស្រាយចប់សព្វគ្រប់ បញ្ហាថ្មីមួយទៀតបានកើតចេញពីសំណួរស្រដៀងៗគ្នានេះដែរ គឺថាតើមេធាវីការពារក្តីមានសិទ្ធិសួរពីភាពអាចទុកចិត្តបានចំពោះសាក្សីដែរឬទេ?

សំណួរមួយក្នុងចំណោមសំណួរជាច្រើនដែលលោក ដេស្តមេន បានចោទសួរនេះគឺថា«តើលោកសប្បាយចិត្តចំពោះការធ្វើទារុណកម្មអ្នកទោសដែរឬទេ?» ។ ភ្លាមនោះ លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត ធ្វើការជំទាស់ចំពោះសំណួរនេះ ដោយលោកបានលើកឡើងថា ឌុច បានបញ្ជាក់រួចមកហើយថាខ្លួនមិនបានចូលរួមធ្វើទារុណកម្មលើអ្នកទោសឡើយ ។ លោក ដេស្តមេន នៅតែបន្តសួរដើម្បីបង្វែរចម្លើយរបស់ ឌុច ដែលបានឆ្លើយរួចមកហើយ ។ ដូច្នេះប្រសិនបើមេធាវីនៅតែមានបំណងសួរសំណួរទាំងនេះ គឺត្រូវបញ្ជាក់ពីគោលបំណងរបស់ខ្លួនជូនអង្គជំនុំជម្រះ ក៏ដូចជាភាគីផ្សេងៗទៀតឲ្យបានដឹង ។ ឆ្លើយតបនឹងសំណូមពរនេះ លោក ដេស្តមេន បញ្ជាក់ថា សំណួរដែលខ្លួនបានចោទសួរនេះ គឺដើម្បីបញ្ជាក់ពីភាពអាចទុកចិត្តបានចំពោះសាក្សីក្នុងការផ្តល់សក្ខីកម្ម ។ ទោះបីជាលោក ដេស្តមេន បញ្ជាក់ដូច្នេះក្តី អង្គជំនុំជម្រះសម្រេចទទួលយកការជំទាស់របស់លោក វីល្លៀម ស្មីត ហើយបង្គាប់ ឌុច មិនឲ្យឆ្លើយបតនឹងសំណួរនេះឡើយ ។

បន្ទាប់ពីអង្គជំនុំជម្រះសម្រេចបែបនេះ លោក ដេស្តមេន បានប្តូរសំណួររបស់ខ្លួន ដោយចោទសួរសំណួរផ្សេងៗទៀត ។ សំណួរទាំងនេះគឺនៅតែមានគោលបំណងបញ្ជាក់ពីភាពស្មោះត្រង់របស់ ឌុច ក្នុងការផ្តល់សក្ខីកម្មដដែល ។ ជាក់ស្តែងលោក ដេស្តមេន បានចោទសួរ ឌុច ថា«តើលោកចាំឬទេ ថាលោកបានសួរចម្លើយនិងធ្វើទារុណកម្មលើអ្នកទោសស្រីម្នាក់នៅមន្ទីរស-២១ ដោយប្រើវិធីឆក់ខ្សែភ្លើង?» ។ ឌុច បញ្ជាក់ថាខ្លួនមិនបានធ្វើដូច្នេះទេ ព្រោះអ្នកទោសនោះមិនស្ថិតនៅមន្ទីរស-២១ ហើយខ្លួនក៏មិនដែលបានធ្វើទារុណកម្មលើអ្នកទោសដែរ ។ បន្ទាប់ពី ឌុច ឆ្លើយបែបនេះ លោក ដេស្តមេន ស្នើសុំដកស្រង់ចម្លើយរបស់ ប្រាក់ ខន ដែល

បានដឹង ឬអាចបញ្ជាក់ថា ឌុច បានធ្វើបែបនេះ ។ តែសំណើនេះត្រូវបានអង្គជំនុំជម្រះសម្រេចបដិសេធ ដោយផ្ដល់សម្អាងហេតុថា ភាគីមិនអាចដកស្រង់ខ្លឹមសារនៃចម្លើយរបស់សាក្សីណាម្នាក់មកសួរសាក្សីម្នាក់ទៀតឡើយ ។ បន្ទាប់ពីអង្គជំនុំជម្រះបដិសេធនូវសំណើរបស់ខ្លួន លោក ផេស្គមេន លើកឡើងថា ខ្លួនមានសិទ្ធិសួរបញ្ជាក់ភាពស្មោះត្រង់របស់ ឌុច ក្នុងការផ្ដល់សក្ខីកម្ម ប្រសិនបើអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យខ្លួនយកឯកសារនេះមកសួរតទល់ជាមួយ ឌុច នោះទេ គឺខ្លួនមិនអាចបង្ហាញឲ្យឃើញថា ឌុច មានភាពមិនស្មោះត្រង់ក្នុងការផ្ដល់សក្ខីកម្មឡើយ ។ លោក ខាណារ៉ាស់ បន្ថែមថា "...ឌុច បាននិយាយហើយថាគាត់មិនបានធ្វើទារុណកម្ម ក៏ប៉ុន្តែមានសាក្សីផ្សេងទៀតនិយាយថា ឌុច បានធ្វើទារុណកម្ម ដូច្នេះមិនមានអ្វីដែលត្រូវរារាំងភាគីមិនឲ្យសួរសាក្សីផ្សេងទៀតដើម្បីបញ្ជាក់ថា ចម្លើយរបស់ ឌុច ត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះទេ..." ។ ទោះបីជាយ៉ាងណាក្ដី អង្គជំនុំជម្រះនៅតែរក្សាសេចក្ដីសម្រេចរបស់ខ្លួនដោយផ្ដល់សម្អាងហេតុដូចមុនដដែល ។

ពាក់ព័ន្ធនឹងការស្នើសុំបង្ហាញឯកសារផ្សេងៗដើម្បីបញ្ជាក់ពីភាពស្មោះត្រង់របស់ ឌុច ក្នុងការផ្ដល់សក្ខីកម្ម លោក ផេស្គមេន បានលើកយកឯកសារមួយចំនួនមកដាក់នៅចំពោះមុខ ឌុច ដោយលោកមេធាវីអះអាងថា ឯកសារទាំងនេះអាចបញ្ជាក់ពីភាពមិនស្មោះត្រង់របស់ ឌុច ក្នុងការផ្ដល់សក្ខីកម្មបាន ។ ឯកសារទាំងនោះរួមមាន ចម្លើយរបស់ អ៊ួច ស៊ន ដែលជាអ្នកទោសនៅមន្ទីរម-១៣ និងឯកសារជាបទសម្ភាសន៍ដែល ឌុច ផ្ដល់ឲ្យលោក គ្រីស្ទូប ប៉េហ្សូ ។

ទាក់ទងនឹងចម្លើយរបស់ អ៊ួច ស៊ន ដែលអង្គជំនុំជម្រះបដិសេធមិនឲ្យលោក ផេស្គមេន យកមកចោទសួរ ឌុច គឺដោយសារឯកសារនេះមិនមាននៅក្នុងសំណុំរឿង០០២ ពោលគឺឯកសារនេះមានតែនៅក្នុងសំណុំរឿង០០១ប៉ុណ្ណោះ ។ អង្គជំនុំជម្រះបញ្ជាក់បន្ថែមថា មេធាវីការពារក្ដីមានសិទ្ធិពេញលេញក្នុងការសួរពីភាពអាចទុកចិត្តបានលើសាក្សី ល្គឹកណាសំណួរទាំងនេះត្រូវផ្អែកលើឯកសារដែលមាននៅក្នុងសំណុំរឿង ។

ចំពោះឯកសារបទសម្ភាសន៍ដែលធ្វើឡើងរវាង ឌុច និងលោក គ្រីស្ទូប ប៉េហ្សូ ត្រូវបានលោក ផេស្គមេន ស្នើសុំដាក់ចំពោះមុខ ឌុច បន្ទាប់ពីលោកមេធាវីបានសួរពាក់ព័ន្ធនឹងការសួរចម្លើយនិងការធ្វើទារុណកម្មលើ កុយ ធួន និង សៀត ឆែ ហៅ ទុំ ។ មូលហេតុដែលលោក ផេស្គមេន ស្នើសុំដាក់ឯកសារនេះ គឺដោយសារ ឌុច ធ្លាប់បញ្ជាក់ជូនលោក ផេស្គផេន ថា ខ្លួនមិនដែលបានសួរចម្លើយអ្នកទោសណាក្រៅពី កុយ ធួន ឡើយ ។

សំណួរចុងក្រោយពាក់ព័ន្ធនឹងភាពស្មោះត្រង់ក្នុងការផ្ដល់សក្ខីកម្មនេះ លោក ផេស្គមេន ស្នើឲ្យ ឌុច បង្ហាញពីមតិយោបល់ក៏ដូចជាការកត់សម្គាល់លើមតិយោបល់របស់ចៅក្រម នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០១ដែលបានលើកឡើងថា ឌុច មិនមានភាពស្មោះត្រង់ ។ ភ្លាមនោះលោក វីល្លៀម ស្មីត ជំទាស់ ដោយលោកបានអះអាងថា សាក្សីគ្មានសិទ្ធិធ្វើការកត់សម្គាល់លើការយល់ឃើញរបស់ចៅក្រមឡើយ ។ អង្គជំនុំជម្រះសម្រេចទទួលយកការជំទាស់ និងការលើកឡើងរបស់ លោក វីល្លៀម ស្មីត ។ លោកស្រីចៅក្រម ខាត់ព្រ៉ាយត៍ បញ្ជាក់បន្ថែមថា មេធាវីមិនអាចសួរសំណួរឲ្យសាក្សីធ្វើការកត់សម្គាល់លើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះឡើយ ។

***កំណត់សម្គាល់*** ៖ បន្ទាប់ពីលោកមេធាវី ម៉ៃឃើល ផេស្គមេន ចោទសំណួរជាច្រើនពាក់ព័ន្ធនឹងភាពស្មោះត្រង់ក្នុងការផ្ដល់សក្ខីកម្ម លោកបានលើកឡើងថា ឌុច ជាមនុស្សកុហក ម្យ៉ាងវិញទៀតពេល ឌុច ឆ្លើយនៅក្នុងសំណុំរឿង០០១ ឌុច បាននិយាយថា ខ្លួនមិនមែនជាអ្នកទទួលខុសត្រូវលើឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ហើយទម្លាក់មកលើ នួន ជា ។ ភ្លាមៗនោះ លោកប្រធានអង្គជំនុំជម្រះបានព្រមានដល់លោក ផេស្គមេន ដោយផ្ដល់សម្អាងថា ការណ៍ដែលមេធាវីលើកឡើងបែបនេះគឺជាការប្រមាថដល់សាក្សី ។ បន្ទាប់ពីមានការព្រមានដូច្នេះ លោក ខាណារ៉ាស់ ផ្ដល់ជាការកត់សម្គាល់ជូនអង្គជំនុំជម្រះថា *"សហព្រះរាជអាជ្ញាខ្លួនគាត់នៅក្នុងសេចក្ដីថ្លែងបើករបស់គាត់ គាត់បានហៅជនជាប់ចោទថាជាឃាតករ ហើយគ្មានប្រតិកម្មពីអង្គជំនុំជម្រះទេ ខ្ញុំគិតថានោះជាការលើកឡើងមិនសមរម្យ"* ។

### ១) ការពិនិត្យចំណារលើចម្លើយសារភាព

បន្ទាប់ពីមានការចោទសួរជាច្រើនពាក់ព័ន្ធនឹងភាពស្មោះត្រង់ក្នុងការផ្ដល់សក្ខីកម្ម លោក ផេស្គមេន បានបង្ហាញឯកសារមួយចំនួនទៀតដើម្បីឲ្យ ឌុច ពិនិត្យចំណារដែលមាននៅលើចម្លើយ

សារភាពរបស់អ្នកទោស ។ ក្នុងការពិនិត្យនេះ មេធាវីស្នើឲ្យ ឌុច អានខ្លឹមសារចំណារខ្លីៗ កាលបរិច្ឆេទ និងពិនិត្យមើលអក្សរនៃចំណារទាំងនោះ ថាតើនរណាជាអ្នកចារ ហើយចារឲ្យនរណា ។

ពាក់ព័ន្ធនឹងការពិនិត្យចំណារនេះ លោក ដេស្ដមេន បានបង្ហាញឯកសារចម្លើយសារភាពមួយចំនួន ដើម្បីឲ្យ ឌុច ពិនិត្យថាតើចំណារដែលធ្វើគឺដោយ នួន ជា ឬ ប៉ុល ពត? ឌុច បញ្ជាក់ថាចំណារលើឯកសារទាំងនោះគឺធ្វើឡើងដោយ នួន ជា ។ មេធាវីបានលើកឡើងថា ចំណារទាំងនោះ ឌុច ធ្លាប់បានប្រាប់ចៅក្រមស៊ើបអង្កេតថា គឺជាចំណារដែលធ្វើឡើងដោយ សុន សេន ។ ជាការឆ្លើយតប ឌុច បានលើកឡើងថា ពេលដែលខ្លួនពិនិត្យមើលចំណារទាំងនោះនៅដំណាក់កាលចៅក្រមស៊ើបអង្កេត គឺស្ថិតក្នុងភាពស្រពិចស្រពិលតែប៉ុណ្ណោះ ។ តែពេលនេះខ្លួនមានភាពជឿជាក់ថាជាចំណាររបស់ នួន ជា ព្រោះទី១ អ្នកដែលមានសិទ្ធិចារលើចម្លើយសារភាពនៅមន្ទីរស-២១គឺមានតែ សុន សេន, នួន ជា និង ប៉ុល ពត តែប៉ុណ្ណោះ ហើយមិនអាចនរណាម្នាក់បំពានបានឡើយ ។ ឌុច អាចស្គាល់អក្សររបស់ សុន សេន ។ ទី២ ចំណារខ្លះ គឺ សុន សេន បានចារយ៉ាងច្បាស់ថាជូន នួន ជា ដូច្នេះមិនអាចប្រកែកបានឡើយ ។ ទី៣ អក្សររបស់ នួន ជា គឺសរសេរខ្លីៗងាយយល់ និងចាំដែលមិនងាយឲ្យខ្លួនមានការភាន់ច្រឡំឡើយ ។

លោក ដេស្ដមេនបង្ហាញឯកសារមួយទៀតដែលជាកំណត់ដៃអមចម្លើយសារភាពរបស់ សែ ជាលេខាភូមិភាគឆ្មើមកគណៈ ៨៧០ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ។ កំណត់ហេតុនេះផ្ញើជូន ប៉ុល ពត (គណៈ៨៧០) ។ នៅលើកំណត់ហេតុនេះមានចំណារត្រឡប់មកវិញ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៨ ។ ចំណារត្រឡប់នេះ ឌុច អះអាងថាជាចំណាររបស់ នួន ជា ព្រោះជាអក្សរជារបស់ នួន ជា ហើយចំណារនេះធ្វើក្រោយថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៧ ដែលក្នុងអំឡុងពេលនោះមានតែ នួន ជា ម្នាក់គត់ដែលទទួលការងារនេះ ។ គួររំឭកថា កំណត់ហេតុដដែលនេះ ឌុច ធ្លាប់បានផ្ដល់សក្ខីកម្មជូនចៅក្រមស៊ើបអង្កេតថា «ខ្ញុំមិនដឹងថានរណាជាអ្នកសរសេរចំណារនេះឡើយ តែប្រហែលជាចំណាររបស់ នួន ជា» ។ តែ ឌុច បានបំភ្លឺថានៅក្នុងដំណាក់កាលនោះខ្លួនគ្រាន់តែផ្ដល់សក្ខីកម្មដោយការថ្លឹងថ្លែងតែប៉ុណ្ណោះ ។

សំណួរចុងក្រោយដែលលោក ដេស្ដមេន សួរ ឌុច ពាក់ព័ន្ធនឹងការពិនិត្យចំណារនេះគឺ «តើលោកអះអាងថាជាចំណារ ឬអក្សររបស់ នួន ជា ដោយសារតែលោកពិនិត្យមើលកាលបរិច្ឆេទ ឬដោយសារតែចំណារនេះមិនមែនជាចំណាររបស់ សុន សេន ឬរបស់ខ្លួនលោកផ្ទាល់?» សំណួរនេះត្រូវបានលោកស្រីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស៊ីមូណូហ្វត ធ្វើការជំទាស់ ដោយលោកស្រីលើកឡើងថា លោក ដេស្ដមេន មិនអាចសួរសំណួរនេះឡើយ ព្រោះវាជាសំណួរដែលអាចធ្វើឲ្យ ឌុច ធ្វើការសន្និដ្ឋានដោយខ្លួនឯង ។ អង្គជំនុំជម្រះសម្រេចបដិសេធចំពោះការលើកឡើងរបស់លោកស្រីមេធាវី ហើយបានបង្គាប់ឲ្យ ឌុច ឆ្លើយតបនឹងសំណួររបស់លោក ដេស្ដមេន ។ ឌុច បានលើកឡើងថា ខ្លួនមានភាពច្របូកច្របល់ក្នុងការធ្វើសេចក្ដីសន្និដ្ឋាននេះ ហើយខ្លួនមិនអាចឆ្លើយបានដូច្នេះមានតែអង្គជំនុំជម្រះប៉ុណ្ណោះដែលមានសិទ្ធិក្នុងការសម្រេចថាចំណារមួយណាដែលធ្វើដោយ នួន ជា ។

### ក) ការរំដោះទីក្រុងភ្នំពេញ

ពាក់ព័ន្ធនឹងការរំដោះទីក្រុងភ្នំពេញ លោក ដេស្ដមេន សួរ ឌុច ដោយផ្ដោតសំខាន់លើឈ្មោះបុគ្គលមួយចំនួន ដែលដឹកនាំកងទ័ពវាយដណ្ដើមយកទីក្រុងភ្នំពេញ ។ សំណួរចាប់ផ្ដើមដំបូង គឺមេធាវីសួរ ឌុច ថាតើស្គាល់លោក ហេង សំរិន ដែរឬទេ? ហើយកាលពីមុននិងបច្ចុប្បន្នគាត់ធ្វើអ្វី? ឌុច បានឆ្លើយថា លោក ហេង សំរិន បច្ចុប្បន្នគឺជាប្រធានសភានៃប្រទេសកម្ពុជា ។ នៅពេលវាយដណ្ដើមយកទីក្រុងភ្នំពេញ លោក ហេង សំរិន មានតួនាទីជាអនុលេខាកងពលលេខ៣នៃភូមិភាគបូព៌ា ដែលពេលនោះមានឈ្មោះ ពៅ ហាក់ ជាលេខាកងពល ។ ប្អូនរបស់លោក ហេង សំរិន គឺឈ្មោះ គាល់ ដែលមានតួនាទីជាលេខាកងទ័ពជើងទឹកប្រចាំការនៅអ្នកលឿងគឺកងពល២៩០ ។ ឌុច បញ្ជាក់បន្ថែមថា មានមេបញ្ជាការជាច្រើនទៀតដែលបានដឹកនាំកងទ័ពវាយចូលកាន់កាប់ទីក្រុងភ្នំពេញ រួមមាន មាស មុត, ស៊ូ ម៉េត, ឃឹម ពីន, ឌី និង សំ ប៊ិត ជាដើម ។ ក្រុងភ្នំពេញត្រូវបានកាន់កាប់ដោយកងពលផ្សេងៗគ្នា ពោលគឺកងពលណាវាយបានតំបន់ណានៃទីក្រុងភ្នំពេញ កងពលនោះជាអ្នកគ្រប់គ្រង ហើយការឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយដែលមានការគ្រប់គ្រងបែបនេះ គឺមានការត្រួតពិនិត្យយ៉ាងតឹងតែង ។

***កំណត់សម្គាល់*** ៖ ពាក់ព័ន្ធនឹងការកាន់កាប់ទីក្រុងភ្នំពេញ លោក ដេស្តម្តេន ស្នើសុំដាក់ឯកសារបទសម្ភាសន៍មួយដែលធ្វើឡើងដោយ លោក ហេង សំរិន និងសាស្ត្រាចារ្យ ប៉ែន យៀវនិង ដោយលោកមេធាវីមានបំណងដកស្រង់ខ្លឹមសារ ដែលមាននៅក្នុងបទសម្ភាសន៍នេះមកសួរឌុច ។ លោក វីល្លៀម ស្មីត បានជំទាស់ចំពោះគោលបំណងនេះដោយលោកបានលើកឡើងថា ទោះបីជាឯកសារនេះមាននៅក្នុងសំណុំរឿង០០២ហើយក៏ដោយ អង្គជំនុំជម្រះមិនទាន់ទទួលយកឯកសារនេះនៅឡើយ ។ ដូច្នេះមេធាវីអាចសួរបានតែសំណួរទូទៅពាក់ព័ន្ធនឹងឯកសារនេះប៉ុណ្ណោះ ។ ចំណែកឯសំណួរជាក់លាក់ ឬការដកស្រង់ខ្លឹមសារដែលមាននៅក្នុងឯកសារនេះមកសួរគឺមេធាវីមិនអាចធ្វើបានឡើយ ។ ប្រធានអង្គជំនុំជម្រះទទួលយកការជំទាស់នេះ ដោយលោកបានផ្តល់សម្អាងហេតុដូចលោក វីល្លៀម ស្មីត ដែរ ។

### ៤.១.២) ការចោទសួរដោយមេធាវី ហ្សាស្តឺ ប៉ាវ



ហ្សាស្តឺ ប៉ាវ

ក្នុងការសួរដេញដោល ឌុច លោកមេធាវី ហ្សាស្តឺ ប៉ាវ បានសួរផ្តោតជាសំខាន់ថាតើអ្វីដែល ឌុច បានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ គឺពិតជា ឌុច បានដឹងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬគ្រាន់តែបានដឹងតាមរយៈការអានសៀវភៅ ឬឯកសារ ឬមើលខ្សែភាពយន្តមួយចំនួនដែលត្រូវបាននិពន្ធក្រោយរបបនេះតែប៉ុណ្ណោះឬយ៉ាងណា? សំណួរមួយចំនួនទៀតដែលលោក ហ្សាស្តឺ ប៉ាវ បានចោទសួរនោះគឺថា តើ ឌុច ធ្លាប់អានសៀវភៅ ឬមើលខ្សែភាពយន្តដែរឬទេ? តើ ឌុច ធ្លាប់បានធ្វើការជាប់លាប់ ឬជិតស្និតជាមួយមេដឹកនាំខ្មែរក្រហមដែរឬទេ? មានសំណួរជាច្រើនទៀតដែលសួរឡើងក្នុងគោលបំណងបង្ហាញថាអ្វីដែល ឌុច បានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ គឺគ្រាន់តែជាចំណេះដឹងដែលបានមកតាមរយៈការអានសៀវភៅ មើលឯកសារ ឬខ្សែភាពយន្តតែប៉ុណ្ណោះ ។ ជាក់ស្តែងសំណួរចុងក្រោយដែលលោកមេធាវីចោទសួរ ឌុច នោះគឺថា *"ឌុច! អ្វីដែលលោកបានឆ្លើយជូនអង្គជំនុំជម្រះ គឺគ្រាន់តែជាព័ត៌មានដែលលោកទទួលបានពីការមើលឯកសារផ្សេងៗដែលចៅក្រមស៊ើបអង្កេតបង្ហាញ និងសួរលោកតែប៉ុណ្ណោះ, តើត្រូវដែរឬទេ?"* ។

ឆ្លើយតបនឹងសំណួរទាំងនេះ ឌុច បានលើកឡើងថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនមិនដែលបានចូលរួមប្រជុំជាមួយគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាឡើយ ហើយក៏មិនដែលបានអានកំណត់ហេតុនៃកិច្ចប្រជុំទាំងនេះដែរ ។ ឌុច បន្ថែមថា ខ្លួនបានអានសៀវភៅមួយចំនួនដូចជា *"សំឡេងចេញពីមន្ទីរស-២១, ពេជឃាតបាត់ខ្លួន, ក្លោងទ្វាធំ កម្ពុជាឆ្នាំសូន្យ និងបានមើលខ្សែភាពយន្តចំនួនពីរ ដែលនិពន្ធដោយលោក រិទ្ធី ប៉ាន់"* ។ ទោះបីជាយ៉ាងណាក្តី ខ្លួនបានដឹងពីការងាររបស់បក្សកុម្មុយនីស្តកម្ពុជាតាំងពីមុនមកម៉្លេះ ព្រោះខ្លួនមានតួនាទីជាប្រធានមន្ទីរស-២១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីគណៈមជ្ឈិម និងតាមរយៈ សុន សេន ដែលជាថ្នាក់លើរបស់ខ្លួនប្រាប់ឲ្យអនុវត្ត ។ ជាពិសេស ខ្លួនបានដឹងពីរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងច្បាស់នៅក្នុងអំឡុងពេលនោះ ។

លោក ហ្សាស្តឺ ប៉ាវ បានដាក់បង្ហាញឯកសារមួយចំនួនទៀត ដូចជាសៀវភៅដែលសរសេរដោយ លោក ដេវីដ ឆេនល័រ ដែលនិយាយពីសេចក្តីសម្រេចក្នុងការកម្ទេចក្រៅជួរ និងក្នុងជួរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ លោកមេធាវីបានចោទសួរថា "ឌុច តើលោកចាំដែរឬទេថាសៀវភៅរបស់លោក ដេវីដ ឆេនឌ័ល័រ បានលើកឡើងអំពីសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦? ហើយនិយាយអំពីអ្វី?" ។ ឌុច បានលើកឡើងថា សៀវភៅនេះពិតជាបាននិយាយពីសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦

មែន ហើយសេចក្ដីសម្រេចនេះនិយាយពីអ្នកដែលមានសិទ្ធិសម្រេចកម្ទេច ។

នៅចុងបញ្ចប់លោកមេធាវី ហ្សាស្តេ ប៉ោ បានធ្វើការកត់សម្គាល់មួយយ៉ាងវែង ដោយលោកបានលើកឡើងថា «យើងដឹងថាហេតុការណ៍វាកើតឡើងយូរមកហើយ ខ្ញុំសូមលើកឡើងថាសក្ខីកម្មរបស់លោកបានបញ្ជាក់ចំណុចបានច្បាស់ ហើយខ្ញុំសូមលើកឡើងថា លោកមិនបានដឹងថាមានអ្វីកើតឡើងនៅក្នុងគណៈអចិន្ត្រៃយ៍ដោយផ្ទាល់នោះទេ ហើយលោកក៏មិនបានដឹងដោយផ្ទាល់អំពីអ្វីដែលកើតឡើងនៅក្នុងគណៈមជ្ឈិមដែរ ហើយលោកក៏មិនបានដឹងដោយផ្ទាល់នៅពេលដែលមានការបញ្ជូនសំណើទៅខាងលើ ហើយលោកក៏មិនដឹងពីតួនាទីរបស់ នួន ជា នៅក្នុងគណៈអចិន្ត្រៃយ៍ដែរ ។ អ្វីដែលលោកបានធ្វើការរៀបរាប់នេះ គឺដោយផ្អែកទៅលើសេចក្ដីសន្និដ្ឋាននិងអ្វីដែលលោកបានអានតែប៉ុណ្ណោះ» ។

### ៤.១.៣) ការចោទសួរដោយមេធាវី សុន អរុណ



សុន អរុណ

បន្ទាប់ពីលោក ហ្សាស្តេ ប៉ាវ បញ្ចប់សំណួររបស់ខ្លួន លោកមេធាវី សុន អរុណ បានបន្តសួរ ឌុច ដោយការដាក់បង្ហាញឯកសារមួយចំនួនដើម្បីសួរបញ្ជាក់ ។ ចាប់ផ្ដើមដំបូង លោក សុន អរុណ បានបង្ហាញឯកសារមួយដែលក្នុងនោះមានកំណត់តួនាទីរបស់មេដឹកនាំខ្មែរក្រហម ។ លោកមេធាវីបានលើកឡើងថា ឯកសារនេះមិនបានកំណត់ថា នួន ជា ទទួលភារកិច្ចជាអ្នកទទួលបន្ទុកខាងសន្តិសុខជាតិឡើយ ។ ជាការឆ្លើយតប ឌុច បានបញ្ជាក់ថា នៅក្នុងលក្ខន្តិកៈបក្សបានកំណត់យ៉ាងច្បាស់ថា រាល់កិច្ចការគ្រប់វិស័យ ត្រូវដឹកនាំដោយបក្ស ដែលក្នុងនោះមានតែ ប៉ុល ពត និង នួន ជា ប៉ុណ្ណោះដែលជាអ្នកដឹកនាំ ពោលគឺ ប៉ុល ពត ជាអ្នកសម្រេច ចំណែក នួន ជា គឺជាអ្នកធានាការអនុវត្ត ។ បន្ទាប់មកលោក សុន អរុណ បង្ហាញឯកសារមួយទៀត ដែលជាឯកសារកំណត់ហេតុប្រជុំរបស់គណៈចិន្ត្រៃយ៍ ។ នៅក្នុងឯកសារនេះ លោកមេធាវីអះអាងថា នួន ជា ទទួលភារកិច្ចខាងសង្គមកិច្ច ។ ឌុច បញ្ជាក់ថា ការណ៍ដែល នួន ជា អះអាងថាខ្លួនគ្រាន់តែទទួលបន្ទុកខាងអប់រំ គឺជាការកុហក ព្រោះការងារដែល នួន ជា ទទួលខុសត្រូវគឺការបញ្ចូលបក្សជនក្នុងបក្ស ហើយគ្រប់គ្រងលើប្រវត្តិរូបកម្មាភិបាលទាំងអស់ ដែលតម្រូវឲ្យធ្វើជីវទស្សន៍ និងការដាក់ពិន័យចំពោះកម្មាភិបាលខ្មែរក្រហមណាដែលធ្វើខុស ។ ឌុច បន្ថែមថា ប៉ុល ពត និង នួន ជា គឺជាអ្នកដឹកនាំគណៈមជ្ឈិម និងគណៈចិន្ត្រៃយ៍ ដែលជាស្ថាប័នមានអំណាចបំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយក្នុងករណីដែល ប៉ុល ពត មិននៅ គឺ នួន ជា ជាអ្នកទទួលការងារ ឬសម្រេចជំនួស ។ នៅពេលដែល ឌុច បញ្ជាក់បែបនេះ លោក សុន អរុណ ចោទសួរថា តើមានឯកសារណាដែលបញ្ជាក់ថា លេខា និង អនុលេខា បក្សជាអ្នកមានសិទ្ធិអំណាចជាងគេ? ឌុច លើកឡើងថា តាមលក្ខន្តិកៈបក្ស គឺថ្នាក់ក្រោមត្រូវតែគោរពថ្នាក់លើ ។ ដូចនេះ រាល់កិច្ចការសំខាន់ៗគឺត្រូវរាយការណ៍ទៅថ្នាក់លើដើម្បីទទួលបានការសម្រេច ។ ជាក់ស្ដែងទោះបីជាមានសេចក្ដីសម្រេចស្ដីពីសិទ្ធិក្នុងការកម្ទេចក្នុងជួរ និងក្រៅជួរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ក៏ដោយ តាមការអនុវត្តជាក់ស្ដែង ការចាប់ឬសម្លាប់កម្មាភិបាលខ្មែរក្រហម គឺតែងតែសុំការអនុញ្ញាតពី ប៉ុល ពត ។ ឌុច បញ្ជាក់បន្ថែមថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តួនាទី និងឋានៈរបស់កម្មាភិបាលខ្មែរក្រហម ជាទូទៅគឺមិនមានលិខិតតែងតាំងច្បាស់លាស់នោះទេ គឺអាស្រ័យលើការសម្រេចរបស់ ប៉ុល ពត ចាត់តាំងឲ្យបំពេញការងារតែប៉ុណ្ណោះ ។

ក្រៅពីនេះ មានសំណួរតិចតួច ដែលលោកមេធាវី សុន អរុណ សួរផ្ដោតលើការជម្លៀស ប្រជាជន អំពីទស្សនាវដ្ដីទង់បដិវត្ត និងការហៅ នួន ជា ថាជាបងទី២ ជាដើម ។

***កំណត់សម្គាល់ ៖***

*តាមការគ្រោងទុក មេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺលោក ម៉ៃឃើល ផេស្តមេន បានស្នើសុំពេលវេលាចំនួនពីរថ្ងៃពេញដើម្បីចោទសួរសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច អំពីអង្គហេតុដែលត្រូវយកមកជំនុំជម្រះនៅក្នុងដំណាក់កាលទីពីរនេះ ។ ប៉ុន្តែនៅពេលប្រើប្រាស់ពេលវេលាជាក់ស្តែង ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានចំណាយពេលវេលារហូតដល់ទៅជាង២ថ្ងៃ ហើយចុងក្រោយលោក មេធាវី សុន អរុណ ស្នើសុំពេលវេលាមួយម៉ោងបន្ថែមទៀតដើម្បីបញ្ចប់សំណួររបស់ខ្លួន ។ សំណើនេះមិនទាន់ត្រូវបានអង្គជំនុំជម្រះសម្រេចនៅឡើយ ព្រោះខ្លួនមានពេលវេលាតែពីរថ្ងៃទៀតប៉ុណ្ណោះសម្រាប់ផ្តល់ឲ្យមេធាវីរបស់អៀង សារី និង ខៀវ សំផន ចោទសួរ ឌុច ។ អង្គជំនុំជម្រះបញ្ជាក់ថាប្រសិនបើមេធាវីរបស់ជនជាប់ចោទទាំងពីរនេះប្រើពេលវេលារបស់ខ្លួនមិនអស់ នោះពេលវេលាដែលនៅសល់នឹងត្រូវផ្តល់ជូនក្រុមមេធាវីការពារក្តីរបស់ នួន ជា ។*

## ៤.២) ការចោទសួរដោយមេធាវីការពារក្តីរបស់ អៀង សារី ចំពោះ ឌុច


ម៉ៃឃើល ខាណាវ៉ាស

*នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ប្រធានអង្គជំនុំជម្រះបានបន្តសវនាការស្តាប់សក្ខីកម្មរបស់ ឌុច ដោយផ្តល់ឱកាសជូនក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ជាអ្នកសួរដេញដោល ។ លោក ខាណាវ៉ាស មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី បានចាប់ផ្តើមសំណួរទាក់ទងនឹងរយៈពេលដែល ឌុច នៅបំពេញការងារនៅមន្ទីរសន្តិសុខស-២១ ។ ឆ្លើយតបនឹងសំណួររបស់លោកមេធាវី ឌុច បានឆ្លើយតបដោយឯកភាពថា ខ្លួនពិតជាត្រូវបានកម្រិតសកម្មភាពនៅត្រឹមតែតួនាទីរបស់ខ្លួន ទាំងការដើរហើរការយល់ដឹង គឺនៅត្រឹមកម្រិតមធ្យមប៉ុណ្ណោះ ។ ឌុច បានបន្តថានាពេលនោះខ្លួនព្យាយាម បំពេញការងារតាមតែបញ្ជា និងខិតខំធ្វើយ៉ាងណាឲ្យស្របតាមមាគ៌ាបក្ស និងការណែនាំជាបន្តបន្ទាប់របស់ថ្នាក់លើដែលមាន សុន សេន និងក្រោយមកគឺ នួន ជា ។ ឌុច និយាយថា កម្រិតភ័យខ្លាចរបស់ខ្លួននៅពេលនោះពិតជាមានកម្រិតខ្ពស់ ហើយភាពភ័យខ្លាចដែលខ្ពស់បំផុតនោះគឺនៅពេលដែលបក្សសម្រេចចាប់ខ្លួន វ៉ើត យូ ហៅ ហុង គណៈកម្មាធិការពាណិជ្ជកម្មនៅមន្ទីរស-២១ និងភាពភ័យខ្លាច នៅពេលដែល នួន ជា បានបញ្ជាឲ្យកម្ទេចអ្នកទោសទាំងអស់នៅមន្ទីរស-២១ នាថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ ។ ព្រឹត្តការណ៍ទាំងនេះបានធ្វើឲ្យខ្លួនមានការតក់ស្លុតយ៉ាងខ្លាំងរហូតធ្វើអ្វីមិនកើត សូម្បីតែចេញពីផ្ទះក៏មិនហ៊ានដែរ ។*

*ទាក់ទងនឹងចម្លើយសារភាព ឌុច អះអាងថា ចម្លើយសារភាពគឺមិនអាចសន្មតទុកថាជារឿងកុហកទាំងស្រុង ហើយក៏មិនអាចសន្និដ្ឋានបានថាជាការពិតទាំងស្រុងដែរ ។ ជាគោលការណ៍មនុស្សដែលបក្សចាប់ និងបញ្ជូនមកមន្ទីរស-២១គឺបក្សកំណត់ថាជាខ្មាំង ដូច្នេះមន្ទីរស-២១ត្រូវពុះពារធ្វើយ៉ាងណាឲ្យមនុស្សនោះទទួលស្គាល់ថាខ្លួនឯងបានប្រព្រឹត្តខុស ធ្លាក់ទៅក្នុងពិរុទ្ធភាពជាខ្មាំងដែលបក្សសង្ស័យ ហើយសម្រេចចាប់ខ្លួន ។ នេះជាបញ្ហាទូទៅដែលមាននៅមន្ទីរស-២១ ជាពិសេសគ្រប់មន្ទីរនគរបាលគិតជារួម ។ ខ្មាំងដែលបក្សកំណត់ជាផ្លូវការ និងជាសាធារណៈដែលត្រូវនាំមកសួរចម្លើយមានបីប្រភេទ គឺទី១) ភ្នាក់ងារសេអ៊ីអា ទី២) ភ្នាក់ងារកាហ្សេបេ និងទី៣) ភ្នាក់ងារយួនវាទីលេបទឹកដីប្រល័យពូជសាសន៍ ។ ឌុច បំភ្លឺថា ការណ៍ដែលឲ្យអ្នកទោសនៅមន្ទីរស-២១សរសេរចម្លើយសារភាពម្តងហើយម្តងទៀតនោះ គឺដើម្បីឲ្យពួកគេឆ្លើយឲ្យច្បាស់ មិនមែនដើរុញឲ្យពួកគេឆ្លើយកុហកទេ ។ ដោយឡែកចម្លើយសារភាពរបស់ កុយ ធួន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម គឺថ្នាក់លើបញ្ជាឲ្យសរសេរ ម្តងហើយម្តងទៀតចំនួនបួនលើក ។*

ឌុច បានអះអាងថា ខ្លួនមិនធ្លាប់បានចូលរួមប្រជុំការងារជាមួយ ប៉ុល ពត ទេ ។ ខណៈដែលលោកមេធាវីអន្តរជាតិ ខណៈរ៉ាស ទាមទារឲ្យលោកសាក្សីឆ្លើយនឹងសំណួរនាំមុខរបស់ខ្លួនដែលតម្រូវឲ្យឆ្លើយថា បាទឬក៏ទេនោះ លោកស្រីសហចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ្រ៉ាយត៍ បានរំឭកលោកមេធាវីឲ្យរៀបចំសំណួរឡើងវិញឲ្យបានត្រឹមត្រូវ ព្រោះមេធាវីមិនអាចកម្រិតសាក្សីឲ្យឆ្លើយត្រឹមតែអ្វីដែលខ្លួនចង់បានទេ ដោយសារកន្លងមកលោកស្រីសង្កេតឃើញថា មេធាវីបានសួរសំណួរដែលមានច្រើនថ្នាក់ ដូច្នេះ លោកស្រីសូមឲ្យលោកមេធាវីសួរសំណួរងាយយល់និងមិនគួរសួរសំណួរនាំមុខទេ ។

### ៤.២.១) កំណត់ហេតុរបស់សាក្សី

ឌុច បានលើកឡើងថា មានកំណត់ហេតុកិច្ចប្រជុំខ្លះមិនបានកត់ត្រាត្រឹមត្រូវទេ គឺមានការកែតម្រូវ ។ ឧទាហរណ៍ កំណត់ហេតុនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ។ ឌុច បានដឹងតែមួយគត់ពីការពិភាក្សាដាក់លាក់នៃកិច្ចប្រជុំតាមរយៈមេរបស់ខ្លួនគឺ សុន សេន ទាក់ទងនឹងករណីប្រជុំអចិន្ត្រៃយ៍ចាប់ ខ្លួន សួស នៅ ហៅ ឈូក ។ កំណត់ហេតុភាគច្រើនលើសលុប គឺកត់ត្រាបានត្រឹមត្រូវ ។ ឌុច លើកឧទាហរណ៍ថា កំណត់ហេតុសំខាន់បំផុតមួយគឺ កំណត់ហេតុថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលខ្លួនជឿថា ជាសម្ដីរបស់ ប៉ុល ពត តែម្ដង ។ ឯកំណត់ហេតុផ្សេងទៀត គឺមានតែនៅកន្លែងខ្លះៗប៉ុណ្ណោះ ។

លោកមេធាវីបានដដឹកសួរ ឌុច អំពីទំនាក់ទំនងរវាង ប៉ុល ពត ឬ នួន ជា ជាមួយ អៀង សារី សុន សេន ឬជាមួយ វន វ៉េត ជាដើម ប៉ុន្តែ ឌុច បានឆ្លើយតបថា ជាគោលការណ៍ខ្លួនដឹងថាមានទំនាក់ទំនងជាមួយគ្នារវាងមេធំ និងមេតាមផ្នែក ហើយជាក់ស្ដែងយ៉ាងណាខ្លួនមិនដឹងទេ ។ ឌុច បានលើកឡើងថា ខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំនោះទេ តែជាក់ស្ដែងមានម្ដងនោះ ខ្លួនបានសួរ ប៉ង់ ពីសេចក្ដីលម្អិតមួយចំនួន ហើយខ្លួនមិនមានភាពភ័យខ្លាចចំពោះ ប៉ង់ ដែលនឹងអាចរាយការណ៍ពីការសួរនាំរបស់លោកពីរឿងប្រជុំអចិន្ត្រៃយ៍មជ្ឈិមអំពីករណីចាប់ខ្លួន ជូ ជេត ហៅ ស៊ី ប្រាប់ទៅ ប៉ុល ពត ទេ ព្រោះខ្លួនសួរតែក្នុងសមត្ថកិច្ចដែលខ្លួនគួរតែដឹងប៉ុណ្ណោះ ។ ឌុច បានជម្រាបជូនអង្គជំនុំជម្រះថា ប៉ង់ ជាមនុស្សដែល នួន ជា បានខ្ទេសនាមឲ្យចុះឡើងមកមន្ទីរស-២១ និងមានសិទ្ធិក្ដាប់រហូតទៅដល់ចម្លើយសារភាពរបស់អ្នកទោស ហើយក៏ជាអ្នកមានសិទ្ធនាំសេចក្ដីសម្រេចពីថ្នាក់លើមកទៀតផង ។ ឌុច ជឿថា ប៉ង់ នៅទីនោះរៀបចំតុកៅអីសម្រាប់ប្រជុំ ដូច្នេះ ប៉ង់ អាចយល់ពីកិច្ចការ និងអាចប្រាប់ខ្លួនបានពីតម្លាភាពការងារ ដែលលោកគួរតែដឹង មិនមែនឲ្យដឹងដល់ការសម្ងាត់របស់ជាតិនោះទេ ។ ឌុច បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនមិនមានភាពភ័យខ្លាចថា ប៉ង់ អាចប្រាប់ ប៉ុល ពត ពីការសួរនាំរបស់ខ្លួននោះទេ ដោយសារខ្លួនយល់ថា ប៉ង់ ប្រាប់ឲ្យដឹងតែបញ្ហាណាដែលនៅក្នុងសមត្ថកិច្ចរបស់ខ្លួនប៉ុណ្ណោះ មិនមែនសួរឲ្យដឹងពីកិច្ចការសម្ងាត់ ហើយទៅបំផ្លាញកិច្ចការមជ្ឈិមនោះទេ ។ ឌុច បញ្ជាក់ថា *«ការចង់ដឹងដើម្បីយល់ឲ្យបានជ្រះស្រឡះ ភ្លឺស្វាង វាខុសពីចង់ដឹងដើម្បីបំផ្លាញមជ្ឈិម ដោយសារស្ថានភាពនៃការចង់ដឹងគឺផ្សេងគ្នា»* ។

លោកមេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ អៀង សារី បានលើកយកឯកសារមួយចំនួនមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ដែល ឌុច ធ្លាប់បានអាន រួមមាន ឯកសារពេជ្ឈឃាតបាត់ខ្លួន និងឯកសាររបស់លោក ដេវីដ ឆេនដ្ល័រ ដែលនិយាយពីសម្លេងពីមន្ទីរស-២១ ជាប្រវត្តិពន្ធនាគារសម្ងាត់របស់ ប៉ុល ពត ដើម្បីមកសួរដេញដោល ។ ចំពោះការដេញដោលលើឯកសារដែលមានចំណងជើងថា *សម្លេងពីមន្ទីរស-២១* ឌុច បានឆ្លើយតបថាមូលហេតុដែលខ្លួនអានសៀវភៅនេះតែពាក់កណ្ដាលហើយឈប់ទៅវិញ ដោយសារតែខ្លួនយល់ឃើញថាសៀវភៅនេះមិនមានសារសំខាន់ ។ ម្យ៉ាងទៀតនៅក្នុងឯកសារនេះ លោក ដេវីដ ឆេនដ្ល័រ ហាក់ដូចជាឲ្យតម្លៃថា ប៉ុល ពត គឺជាសិស្សរបស់ ម៉ៅ សេទុង ជាពិសេសឯកសារសិក្សាពីការដោះស្រាយត្រឹមត្រូវនៃទំនាស់ផ្ទៃក្នុងប្រជាជន ។

### ៤.២.២) ការចាប់ខ្លួន វន វ៉េត

លោកមេធាវីបានលើកយកចម្លើយដែល ឌុច បានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត កាលពីឆ្នាំ២០០៨មកសួរដេញដោល ។ ឌុច បានបញ្ជាក់ថា នៅពេលដែលបក្សសម្រេចចាប់ខ្លួន វន វ៉េត គឺជាការពិតខ្លួនបានឆ្លើយដាក់ វន វ៉េត ដើម្បីកុំឲ្យ ប៉ុល ពត មានឱកាសចោទមកលើខ្លួនបានងាយពេក ។


វន វេត

លោកមេធាវីបានបន្តសំណួររបស់ខ្លួន ដោយការសួរដេញដោល ឌុច ពីភាពខុសគ្នារវាងទ្រឹស្តី និងការអនុវត្ត ។ ឌុច បានលើកជាឧទាហរណ៍មួយថា តាមទ្រឹស្តីលេខាភាគមានសិទ្ធិសម្រេចកម្ទេចនៅក្នុងក្របខណ្ឌភាគរបស់ខ្លួន ដែលខ្លួនធ្លាប់បានគោរពតាំងពីឆ្នាំ ១៩៧១ មកម៉្លេះ ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង វាមិនច្បាស់លាស់ជាអញ្ចឹងទេ ឧទាហរណ៍គឺលក្ខខណ្ឌរបស់ កង ចាប ។ លោកមេធាវី បានព្យាយាមសួរឲ្យឌុចបញ្ជាក់ពីទម្លាប់ការងារអនុវត្តជាក់ស្តែងនៅក្រសួងការបរទេស ថាតើមានឯកសារណាមួយកំណត់ពីគោលការណ៍អនុវត្តជាក់លាក់ឬទេ ។ ឌុច បានឆ្លើយថា ឯកសារមាន ប៉ុន្តែតាមរូបភាពផ្សេងៗ ។ ឌុច បានផ្តល់ជាឧទាហរណ៍ជាក់ស្តែងថា ការណ៍ដែលសម្រេចចាប់ខ្លួនឈ្មោះ ចៅ សេង កាលនោះ អៀង សារី មិនដឹងទេ ។ សុន សេន ទាក់ទងទូរស័ព្ទមកខ្លួន ហើយប្រែឈ្មោះ ចៅ សេង ទៅជា ចិន សួន ព្រមទាំងបង្គាប់ថាមិនឲ្យប្រាប់នរណាឡើយ ។ ឯកសារភស្តុតាងនៅក្នុងបញ្ជីមនុស្សដែលចូលមកនោះគ្មានឈ្មោះ ចៅ សេង ទេ គឺមានតែឈ្មោះ ចិន សួន ប៉ុណ្ណោះ ។ ឌុច លើកឡើងទៀតថា បើយើងមានសុទ្ធិដ្ឋិនិយមទាំងអស់គ្នាក្នុងការស្វែងរកការពិត យើងអត់និយាយដើម្បីសង្កត់គ្នា សូមយើងទាំងអស់គ្នាទៅមើលឯកសារ ហេង ពេជ ហៅ ឆន ។ ឯកសារនេះ សុន សេន រាយការណ៍ជូន ប៉ុល ពត អំពីបុគ្គលម្នាក់ដែលខ្លួនសុំមិនបញ្ចេញឈ្មោះ ។ ខណៈពេល ឌុច កំពុងរៀបរាប់ លោកមេធាវីអន្តរជាតិ ខាណារ៉ាស បានឆ្លើយកាត់ដោយលើកឡើងថាខ្លួនមិនចង់ដឹងពីបញ្ហានេះទេ ។ ខ្លួនចង់ដឹងតែអំពីឯកសារជាក់លាក់ណាមួយដែលផ្ញើចេញពី សុន សេន ប៉ុល ពត ឬក៏ នួន ជា ទៅ អៀង សារី ដើម្បីជូនដំណឹង និងសូមអនុញ្ញាតចាប់បុគ្គលិកពីក្រសួងការបរទេសថាតើមានដែរឬទេ ។ ភ្លាមនោះ ក្រោយពីលោកមេធាវីបានបញ្ចប់ការលើកឡើងរបស់ខ្លួន លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បានក្រោកឈរដើម្បីជំទាស់សកម្មភាពរបស់លោកមេធាវីដែលបានកាត់ចម្លើយរបស់សាក្សី ។ មុននឹងស្តាប់ការជំទាស់របស់សហព្រះរាជអាជ្ញា លោកប្រធានអង្គជំនុំជម្រះបានរំឭកដល់សាក្សីមិនឲ្យឆ្លើយតបសំណួរភ្លាមៗទេ នៅពេលដែលមានភាគីជំទាស់ដូច្នេះ ហើយសាក្សីត្រូវរង់ចាំស្តាប់អង្គជំនុំជម្រះជាមុនសិន ។ លោកប្រធានបានផ្តល់ភាពច្បាស់លាស់ថាសាក្សីត្រូវស្តាប់តាមបញ្ជារបស់អង្គជំនុំជម្រះ មិនត្រូវស្តាប់តាមភាគីណាមួយទេ ។ បន្ទាប់មកលោកសហព្រះរាជអាជ្ញាបានជំទាស់ចំពោះមេធាវីដែលបានកាត់សម្តីសាក្សី ដោយអះអាងថាសាក្សីកំពុងតែឆ្លើយតបសំណួររបស់មេធាវី ក៏ប៉ុន្តែមេធាវីបែរជាមិនទុកពេលឲ្យសាក្សីឆ្លើយតបទៅវិញ ។ លោកមេធាវី ខាណារ៉ាស បានឆ្លើយតបនឹងសហព្រះរាជអាជ្ញាវិញថា សាក្សីមិនបានឆ្លើយតបនឹងសំណួររបស់ខ្លួនដែលសួរអំពីការអនុវត្តជាក់ស្តែងនិងគោលការណ៍ ។ បន្ទាប់មកលោកមេធាវីក៏បន្តសំណួររបស់ខ្លួនចំពោះ ឌុច បន្តទៀត ។

លោកមេធាវីបានបន្តបង្ហាញនូវឯកសាររបស់សហចៅក្រមស៊ើបអង្កេតដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាងសាក្សី ឌុច និងជនជាប់ចោទ អៀង សារី ។ ឌុច បានទទួលស្គាល់ឯកសារនោះ ដែលថាខ្លួនមិនមានទំនាក់ទំនងជាមួយ អៀង សារី ទេ ទោះបីជាពាក្យសម្តីឬជាលាយលក្ខណ៍អក្សរក្តី ។

តាមចម្លើយរបស់លោក ឌុច ពាក្យថា“អង្គការ” គឺសំដៅលើ ប៉ុល ពត ។ ចំណែក សុន សេន វិញនៅពីក្រោយខ្នង ឌុច ក៏ហៅថាជាអង្គការដែរ ប៉ុន្តែនៅចំពោះមុខ ឌុច មិនហៅ សុន សេន ដូច្នេះទេគឺហៅថា បង ព្រោះ សុន សេន មិនដែលចាត់ទុកថាខ្លួនជាអង្គការទេ ។ សុន សេន បានប្រាប់ឌុចថា សុន សេន ចុះមកធ្វើការនៅមន្ទីរ ស-២១ គឺក្នុងឋានៈជាតំណាងរបស់អង្គការ ។ ឌុច បានបន្តទៀតថាមុនថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ខ្លួនបានបញ្ជូនចម្លើយ

សារភាពទៅ សុន សេនប៉ុន្តែបន្ទាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ដោយសារមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងមន្ទីរស-២១ ឌុច បានបញ្ជូនចម្លើយសារភាពទៅ នួន ជា វិញ ។ ក្រោយពីបញ្ជូនឯកសារទៅឲ្យប្រធានរបស់ខ្លួនរួចមក ឌុច មិនបានដឹងថា ឯកសារចម្លើយសារភាពទាំងនោះត្រូវបានបញ្ជូនទៅណាទៀតនោះទេ ។ ចំពោះការពិភាក្សាគ្នាលើចម្លើយសារភាពទាំងនោះ ឌុច បានដឹងតែម្តងគត់ គឺករណីចាប់ខ្លួន ឈូក គឺដឹងតាមរយៈ សុន សេន ដោយសារ សុន សេន បានបញ្ជាខ្លួនឲ្យរៀបចំឯកសារ ។ លុះក្រោយពេលប្រជុំ សុន សេន ក៏បានប្រាប់ឲ្យខ្លួនដឹងពីបញ្ហាដែលមាននៅក្នុងកិច្ចប្រជុំនោះ ។ លោកមេធាវី ខាណារ៉ាស បានបន្ថែមលើចម្លើយរបស់ឌុចថា “ដូចនេះដើម្បីឲ្យកាន់តែច្បាស់ជាងនេះ គឺទាល់តែឲ្យ សុន សេន មកបញ្ជាក់នៅទីនេះ?” ។ ឌុច បានឆ្លើយតបនឹងមេធាវីវិញថា បើសិនជាយើងស្វែងរកការពិតតាមរបៀបនេះគឺវាមានលក្ខណៈអរូបិយហើយ ។ លោក ខាណារ៉ាស បានបន្តសំណួររបស់ខ្លួនទៅកាន់ ឌុច ទៀតថា លោកមានស្វែងរកយុត្តិធម៌ទេនៅមន្ទីរស-២១? ហើយតាមទ្រឹស្តី តើមន្ទីរស-២១មានគោលដៅដើម្បីស្វែងរកការពិតឬអត់? ឌុច បានឆ្លើយតបថា បញ្ហាទាំងអស់នេះគឺទុកឲ្យមនុស្សសម័យនេះ និងសម័យក្រោយ ជាអ្នកគិតពិចារណាដោយខ្លួនឯងវិញចុះ យើងមិនវាយតម្លៃខ្លួនឯងទេ ។ លោកមេធាវីបានបន្ថែមទៀតថា ក្នុងនាមជាប្រធានមន្ទីរស-២១ តើភាពទទួលរងការធ្វើទារុណកម្មតាម វិធីក្តៅ ត្រជាក់ និងអន្លាម គឺជាវិធីសាស្ត្រដែល ឌុច ធ្លាប់បានប្រើប្រាស់ដើម្បីស្វែងរកការពិត តើត្រឹមត្រូវដែរឬទេ? ឌុច បានឆ្លើយតបដោយខ្លីថា ដូចដែលខ្លួនធ្លាប់បានជម្រាបជូនកន្លងមកហើយថាមន្ទីរស-២១ ជាអង្គភាពបំពេញភារកិច្ចប្រតិចារកម្ម ។

លោកមេធាវីបានលើកយកបញ្ហាក្មេងនៅក្នុងមន្ទីរស-២១ ដែលជនជាប់ចោទ អៀង សារី ធ្លាប់បានលើកឡើង ។ ចំពោះបញ្ហាកូនក្មេងនេះ ឌុចបានដឹងកាលពីឆ្នាំ១៩៩០ ដោយសារពីមុនមកមិនមាននរណាប្រាប់ខ្លួនអំពីបញ្ហានេះឡើយ ។ ឌុច បានលើកឡើងថាខ្លួនមានការខ្មាសអៀនចំពោះវីរភាពរបស់ អៀង សារី ដែលហ៊ានទុកក្មេងៗដូចជាកូនរបស់មិត្ត តួច ខាំឌឿន កូនរបស់មិត្ត ទាញ កូនរបស់មិត្ត ណាត ឲ្យនៅរស់ ។ ចំណែក ឌុច ខ្លួនឯងវិញ មិនហ៊ានសុំអង្គការបង្កើតមូលដ្ឋានកុមារកំព្រាទេ ដោយសារធ្លាប់មានបទពិសោធនៅមន្ទីរម-១៣រួចហើយ ។ ប៉ុន្តែក្រោយមក ឌុច ឃើញថាក្នុងការប្រតិបត្តិគោលការណ៍ គឺនៅមានចន្លោះ ដូចជាកូនរបស់ ចេង អន នៅរស់ បងប្អូនរបស់ នង ចាន់ផល ចំនួនបីនាក់ក៏នៅរស់ និងកូនរបស់ កែ គឹមហួត ក៏នៅរស់ ។ ឌុច បានបន្តទៀតថា ដូច្នេះគោលការណ៍ចាប់ម៉ែឪ គឺកូនត្រូវតែកម្ទេចប្រហែលជាត្រូវបានអនុវត្តរហូតដល់រាប់ពាន់ប៉ុន្តែនៅសល់ចន្លោះប៉ុណ្ណឹង ។

មុននឹងបញ្ចប់ការសួរដេញដោលសាក្សី ឌុច លោកមេធាវីអន្តរជាតិ ខាណារ៉ាស បានតាំងសំណួរមួយចំនួនទាក់ទងនឹងភាពស្មោះត្រង់ក្នុងការផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ ឌុច បានបំភ្លឺថា ការផ្តល់សក្ខីកម្មកន្លងមកខ្លួនបានធ្វើការពុះពារជាអតិបរមាដើម្បីជម្រាបការពិត និងស្មោះត្រង់ចំពោះសតិអារម្មណ៍របស់ខ្លួន ។ ឌុច បន្តទៀតថា ចុងបញ្ចប់អង្គជំនុំជម្រះជាអ្នកជម្រះសេចក្តី ហើយព្រឹត្តិការណ៍ដែលកើតនៅពេលនេះ ទាំងសកម្មភាពរបស់ខ្លួន រួមទាំងសកម្មភាពរបស់លោកមេធាវីទាំងអស់គ្នា គឺមនុស្សជាតិជំនាន់នេះ និងជំនាន់ក្រោយជាអ្នកវិនិច្ឆ័យ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សី ឌុច បានអះអាងថា “ខ្ញុំជឿថា ខ្ញុំគ្មានដែលបដិសេធមិនឆ្លើយការពិតទាំងស្រុងទេ ប៉ុន្តែអ្នកសួរហ្នឹង ដែលសន្មតថាជាការពិតហ្នឹង វាជាការពិតហើយឬនៅ ។ នោះជាបញ្ហាមួយដែលយើងមិនគួរលើកយកមកនិយាយទេ ។ ឧត្តមគតិខ្ញុំ គឺឆ្លើយការពិតទាំងស្រុង” ។

## ៤.៣) ការចោទសួរដោយមេធាវីការពារក្តីរបស់ ខៀវ សំផន ចំពោះ ឌុច

ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី ខៀវ សំផន ត្រូវបានផ្តល់ឱកាសឲ្យសួរដេញដោលសាក្សី ឌុច រយៈពេលមួយថ្ងៃពេញ ។ ប៉ុន្តែដោយសារក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ចប់ ការសួរដេញដោលរបស់ខ្លួនមួយម៉ោងមុនពេលបញ្ចប់ អង្គជំនុំជម្រះបានប្រគល់ពេលវេលាដែលនៅសេសសល់ជូនតាមសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ដើម្បីសាកសួរ ឌុច បន្ថែម ។

នៅពេលចាប់ផ្តើម មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន គឺលោក អាកទួរ វែកគែន បានប្រាប់ទៅ ឌុច ថា លោកនឹងសួរតែសំណួរណាដែល ឌុច បានដឹងពីរបបកម្ពុជាប្រជាធិបតេយ្យតែ

ប៉ុណ្ណោះ ។ លោកបន្ថែមថា ឌុច មិនមែនជាអ្នកប្រវត្តិវិទូ ឬអ្នកជំនាញឡើយ ដូច្នេះ ឌុច មិនគួរធ្វើអត្ថាធិប្បាយលើឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យដែលខ្លួនមិនធ្លាប់បានដឹងនោះទេ ហើយ ឌុច ក៏មិនគួរចាត់ទុកខ្លួនឯងថាជាសាក្សីផ្ទាល់នៃឯកសារទាំងអស់នោះដែរ ។ លោកមេធាវីបានបញ្ជាក់ថា លោកនឹងសួរសំណួរទូទៅមួយចំនួនទៅកាន់ ឌុច មុននឹងចូលដល់ការសួរអំពីសេចក្ដីថ្លែងការណ៍ដែល ឌុច បានធ្វើនាពេលកន្លងទៅ ។



អាកទួរ វែកកែន

សំណួរដំបូងរបស់លោកមេធាវី គឺថាតើ ឌុច ធ្លាប់មានទំនាក់ទំនងអ្វីជាមួយនឹង ខៀវ សំផន នៅមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែរឬទេ? ឌុច អះអាងថា ខ្លួនមិនដែលបានទាក់ទងជាមួយនឹង ខៀវ សំផន ទេ និងថាគោលការណ៍របស់បក្សគឺអ្នកដែលនៅក្រោមបង្គាប់របស់អ្នកណា អាចជួបត្រឹមតែជាមួយមេផ្ទាល់របស់គេប៉ុណ្ណោះ ។ ខៀវ សំផន មិនមែនជាមេរបស់ខ្លួននោះទេដូច្នេះខ្លួនមិនមានសិទ្ធិទៅជួបនឹង ខៀវ សំផន ទេ ។ ឌុច បន្ថែមថា ខ្លួនធ្លាប់បានឃើញ ខៀវ សំផន ពីចម្ងាយនៅក្នុងបុណ្យថ្ងៃ១៧ មេសា ឆ្នាំ១៩៧៨ ។ បន្ទាប់មកលោកមេធាវី វែកកែន បានបន្តរំឭក ឌុច អំពីសម្ដីដែល ឌុច បាននិយាយនៅក្នុងតុលាការនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ថាខ្លួនមិនដឹងទេ ថាតើចម្លើយសារភាពដែលផ្ញើទៅមេរបស់ខ្លួនត្រូវបញ្ជូនទៅទីណាទៀត ។ បន្ទាប់មកលោកមេធាវីបានស្នើឲ្យ ឌុច ធ្វើការបញ្ជាក់ពីអ្វីដែលខ្លួនបានប្រាប់សហចៅក្រមស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៨ ថា “គ្មានអ្វីដែលអាចបញ្ជាក់ថា ខៀវ សំផន បានអានចម្លើយសារភាពនោះទេ” និងសួរ ឌុច ថាតើ ឌុច នៅតែទទួលស្គាល់អ្វីដែលខ្លួនបាននិយាយដែរឬទេ ។ ឌុច ឆ្លើយតបនឹងសំណួរនេះ ដោយបញ្ជាក់ថា ខ្លួននៅតែរក្សា ជំហរថាខ្លួនមិនបានដឹងថាឯកសាររបស់ស-២១ថ្នាក់លើយកទៅធ្វើអ្វីខ្លះនោះទេ និងថា ខៀវ សំផន មិនបានអានឯកសារទាំងនោះមុនគេ ដូចជា សុន សេន ទេ ។

ឆ្លើយតបនឹងសំណួររបស់លោកមេធាវីទាក់ទងនឹងការចូលរួមប្រជុំរបស់ ប៉ាំង នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ឌុច បានអះអាងថា ប៉ាំង គឺជាអ្នករៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប៉ុន្តែជាគោលការណ៍ ឌុច ជឿថា ប៉ាំង មិនមានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំនោះទេ ។ ឌុច បានបន្តថា ប៉ាំង ត្រូវបានចាប់ខ្លួនបញ្ជូនមកស-២១ និងក្រោយមកត្រូវបានកម្ទេច ។ ឌុច បានបដិសេធថា ខ្លួនមិនដែលនិយាយជាមួយនឹង ប៉ាំង នៅឯស-២១ទេ ប៉ុន្តែភ្លាមៗនោះលោកមេធាវីបានស្នើឲ្យ ឌុច ពន្យល់ហេតុផលអ្វីបានជា ឌុច និយាយប្រាប់ខុត្តមស្នងការអគ្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅក្នុងឆ្នាំ១៩៩៩ថា ប៉ាំង បានប្រាប់ខ្លួនអំពីការផ្លាស់ប្ដូរការអញ្ជើញពី វន វេត ទៅ ខៀវ សំផន ថា ខ្លួននិយាយជាមួយ ប៉ាំង នៅពេលដែល ប៉ាំង ត្រូវបានធ្វើទារុណកម្មបង្ខំឲ្យសារភាព ។ ប៉ុន្តែក្នុងសវនាការពេលនេះ ឌុច បែរ ជានិយាយថាខ្លួនបាននិយាយជាមួយ ប៉ាំង នៅពេលមុនពេលចាប់ខ្លួន ប៉ាំង ទៅវិញ ។ លោកមេធាវីបានសួរ ឌុច ថាតើចម្លើយរបស់ ឌុច នៅក្នុងឆ្នាំ១៩៩៩ និងចម្លើយនៅក្នុងសវនាការនាពេលនេះ មួយណាជាចម្លើយពិត ។ ឌុច ថា ចម្លើយរបស់ខ្លួនដែលធ្វើនៅក្នុងសវនាការគឺជាការពិត ព្រោះ ប៉ាំង បាននិយាយពីបញ្ហានោះនៅពេលដែល ប៉ាំង នៅមានអំណាច ។ ឌុច បានបន្តថា ខ្លួនមិនបានចាំអំពីពេលវេលានៃការចាប់ខ្លួន ប៉ាំង ទេ ប៉ុន្តែបានចាំថា ដូ ជេត ត្រូវបានចាប់ខ្លួនមកស-២១នៅខែមេសា ឆ្នាំ១៩៧៨ ហើយ ប៉ាំង ត្រូវបានចាប់ខ្លួន២ ឬ៣ ខែក្រោយពីពេលចាប់ខ្លួនរបស់ ដូ ជេត ។ ឌុច មិនបានចាំថា ដូ ជេត បានឆ្លើយដាក់ ប៉ាំង ឬយ៉ាងណានោះទេ នៅអំឡុងពេលនៃការសួរចម្លើយ និងក្នុងចម្លើយសារភាពរបស់ ដូ ជេត នៅក្នុងស-២១ ។ ឆ្លើយតបនឹងសំណួរសួរថា តើមានការឃ្លាំមើលពីសំណាក់របបកម្ពុជាប្រជាធិបតេយ្យលើ ប៉ាំង មុនការចាប់ខ្លួន ប៉ាំង ឬទេ? ឌុច

បានអះអាងថា សុន សេន បានអនុញ្ញាតឲ្យអ្នកទោសឆ្លើយដាក់ ប៉ង់ តាំងពី សុន សេន នៅគ្រប់គ្រង និងមុនពេល ដូ ដេត ត្រូវបានចាប់ខ្លួន ។ លោកមេធាវីបានបន្តសួរថា តើ សុន សេន ចង់ឲ្យគេឆ្លើយដាក់ ប៉ង់ ដែរឬទេ? ឌុច បានបញ្ជាក់ថា មានពេលមួយ សុន សេន បានសួរខ្លួនថាហេតុអ្វីបានជាមិនឃើញមានអ្នកទោសឆ្លើយដាក់ ប៉ង់ ។ ឌុច បានឆ្លើយតបវិញថា កាលពីពេលមុនខ្លួនធ្លាប់បានប្រាប់ពីរឿងអ្នកទោសឆ្លើយដាក់ ប៉ង់ ទៅ សុន សេន រួចហើយ ក៏ប៉ុន្តែ សុន សេន បែរជាសើចចំអកឲ្យខ្លួនទៅវិញ ។ ពេលនោះ សុន សេន បានទទួលស្គាល់ថាខ្លួនខុស និងប្រាប់ឲ្យ ឌុច រាយការណ៍មកខ្លួនថា តើអ្នកទោសឆ្លើយដាក់ ប៉ង់ ដូចម្ដេចខ្លះ? ឌុច ឆ្លើយថា បក្សបានឃ្លាំមើល ប៉ង់ ជាហូរហែរហូតដល់ការស្ដាប់ចម្លើយអ្នកដែលឆ្លើយដាក់ ប៉ង់ ។ ឌុច បន្ថែមថា បុគ្គលដែល ប៉ុល ពត និង នួន ជា មិនទុកចិត្តគ្មាននរណាម្នាក់ដឹងខ្លួននោះទេ ហើយថាដរាបណា គណៈអចិន្ត្រៃយ៍មិនទាន់ប្រកាសចាប់ខ្លួន ប៉ង់ ទេ ប៉ង់នៅតែមានតួនាទីជាអ្នកនាំពាក្យ ប៉ុល ពត មកដឹកនាំស-២១ ហើយស-២១ត្រូវតែគោរពការចាត់តាំងនេះ ។ ប្រសិនបើស-២១ធ្វើឲ្យបែកការណ៍ក្នុងការចាប់ខ្លួន ប៉ង់ ស-២១ត្រូវតែមានទោស និងថាគណៈអចិន្ត្រៃយ៍បានបញ្ជាឲ្យខ្លួនមិនត្រូវធ្វើអាកប្បកិរិយាអ្វីដែលធ្វើឲ្យ ប៉ង់ ដឹងខ្លួនឡើយ ។ បន្ទាប់មក ឌុច បានពន្យល់ដោយខ្លីថា រឿងដែលអ្នកទោសឆ្លើយដាក់ ប៉ង់ ស-២១ត្រូវតែធានារក្សាការណ៍សម្ងាត់មិនឲ្យរឿងនេះដឹងដល់ ប៉ង់ ។ លោកមេធាវីបានសួរ ឌុច បន្តទៀតថាតើ ឌុច មិនខ្លាច ប៉ង់ ឆ្លើយដាក់ពីការណ៍ដែលខ្លួនបាននិយាយជាមួយ ប៉ង់ នៅពេលដែល ប៉ង់ ត្រូវបានចាប់ខ្លួនមកស-២១ទេឬ? ឌុច បាននិយាយដោយសម្ដីម៉ឺងម៉ាត់ថា *«បញ្ហានេះទៅមិនរួចទេ តើបុគ្គលិកស-២១ដែលគេសួរចម្លើយ ប៉ង់ ហ្នឹង គេអនុញ្ញាត ប៉ង់ ឆ្លើយដាក់ខ្ញុំទេ? ហ្នឹងទីមួយ ។ ទីពីរ បើសិនជា ប៉ង់ ហ៊ានឆ្លើយ តើខាងលើជឿទេ?»* ក្រោយពីទទួលបានចម្លើយរបស់ ឌុច លោកមេធាវីបានសួរ ឌុច ដោយរំឭកថា កាលពីពេលមុន ណាត ដែលធ្លាប់ជាមេរបស់ ឌុច និងជាអតីតប្រធានស-២១ ក៏ធ្លាប់ត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម និងសម្លាប់ចោលនៅស-២១ដែរ ចុះហេតុអ្វីពេលនេះ ឌុច និយាយថាខ្លួននៅខ្ពស់ជាងគេដោយទទួលបានការការពារដោយសារតែខ្លួនជាប្រធានស-២១ទៅវិញ? ឆ្លើយតបនឹងសំណួរនេះ ឌុច បញ្ជាក់ថា ការឆ្លើយដាក់ ណាត មិនមែនចេញពីស-២១ទេ ។ ការចាប់ខ្លួន ណាត គឺចេញពីសេចក្ដីសម្រេចរបស់ ប៉ុល ពត ផ្ទាល់តែម្ដង ដោយស្នើឲ្យលោកមេធាវីទៅមើលឯកសារសេចក្ដីសម្រេចថ្ងៃទី២១ មេសា ឆ្នាំ១៩៧៦ ។ បន្ទាប់មកលោកមេធាវីបានបន្តរំឭកអំពី វន វេត ឆ្លើយដាក់ ឌុច និងថាទោះបីមានតួនាទីជាប្រធានស-២១ក៏ដោយ ក៏មិនមែនគេចផុតពីការឆ្លើយដាក់ដែរ ។ ឌុច បានទទួលស្គាល់ថា វត វេត ពិតជាបានឆ្លើយដាក់ខ្លួននៅពេលសួរចម្លើយហើយ ឌុច ក៏បានយកចម្លើយសារភាពនោះទៅបង្ហាញ នួន ជា ហើយ ឌុច និយាយថា *«បើបង នួន គាត់ចង់ចាប់ខ្ញុំ គាត់ចាប់ទៅ»* ។ លោកមេធាវីបានបន្តសួរឌុច ថាតើ ឌុច ធ្លាប់មានការភ័យខ្លាចអំពីការចាប់ខ្លួន នៅពេលដែល ឌុច ធ្វើការនៅស-២១ដែរឬទេ? ឌុច បានបញ្ជាក់ថា មានពេលមួយនោះមេរបស់ខ្លួនបានហៅឲ្យទៅជួប ។ ឌុច អះអាងថា ពេលនោះខ្លួនក៏មានការព្រួយបារម្ភដែរ ។ លោកមេធាវីបានកត់សម្គាល់ពីការផ្ទុយគ្នារវាងចម្លើយដែល ឌុច បានឆ្លើយកាលពីពេលមុនថា ខ្លួនមិនដែលភ័យព្រួយនៅពេលដែលខ្លួនមាននាទីជាប្រធាននៅស-២១ទេ ។ ឌុច បានឆ្លើយតបវិញថា មិនមានការផ្ទុយគ្នានោះទេ ព្រោះនៅពេលជួបអ្នកដឹកនាំ ទោះអ្នកនោះមានតួនាទីជាអ្វីក៏ដោយ ក៏ត្រូវតែសម្ដែងការគោរព និងស្មោះត្រង់ ប៉ុន្តែសភាពការណ៍ជាទូទៅនៅពេលនោះ មានព្រឹត្តិការណ៍ជាច្រើនដែលធ្វើឲ្យខ្លួន និងប្រពន្ធមានអារម្មណ៍ភ័យខ្លាច ហើយថាខ្លួនមានអារម្មណ៍ភ័យខ្លាចបំផុតនៅពេលដែលបក្ស គឺ នួន ជា ដែលបានបញ្ជាឲ្យចាប់ វ៉ែត យូ ហៅ ហុង, សូ ជា និង សូ យក់ ។ ឌុច បញ្ជាក់ថា អ្នកទាំងបីនាក់ត្រូវបានចាប់ខ្លួននៅក្រោយថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ។ ឌុច ថ្លែងថា ចំពោះសភាពការណ៍រួមនៅពេលនោះ ខ្លួនក៏មានអារម្មណ៍ភ័យដូចអ្នកដទៃទៀតដែរ ។ លោកមេធាវីបានបន្តសួរ ឌុច ពីការរអ៊ូរទាំរបស់តាម៉ុកចំពោះ ដូ ដេត ។ ឌុច អះអាងថា ខ្លួនសង្កេតឃើញថា តាម៉ុក មិនសូវចូលចិត្ត ដូ ដេត ទេ ។ បន្តមកទៀត លោកមេធាវីបានសួរថាតើ ខៀវ សំផន មានបានចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចចាប់ខ្លួន ដូ ដេត ដែរឬទេ? ឌុច ឆ្លើយតបចំពោះសំណួរនេះថា ខ្លួនបានដឹងអំពីបញ្ហានេះតាមរយៈ ប៉ង់ ដែលថា ប៉ុល ពត បានអញ្ជើញ ខៀវ សំផន ឲ្យចូលរួមប្រជុំជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីពិភាក្សាពីការចាប់ខ្លួន ដូ

ដេត ។ លោកមេធាវី វែកគែន បានសួរថា តើ ប៉ង់ បានពន្យល់ ឌុច ពីមូលហេតុអ្វីខ្លះដែលនាំឲ្យបក្សមិនអញ្ជើញ វន វ៉េត ចូលរួមក្នុង កិច្ចប្រជុំដែរឬទេ? ឌុច អះអាងថា បើតាមអ្វីដែល ប៉ង់ បាននិយាយ វន វ៉េត គឺជាមនុស្សលំបាកធ្វើការងារជាមួយខ្លាំងណាស់ ហើយ ពេលណាដែលមិនត្រូវចិត្តនឹងអ្វីមួយ វន វ៉េត អង្គុយស្ងៀមធ្វើមុខ ក្រញ៉ូវ ។ ហេតុនេះហើយ បានជានៅពេលនោះ ប៉ុល ពត មិនឲ្យគេ អញ្ជើញ វន វ៉េត ចូលរួម ។ លោកសួរទៀតថាតើការមិនអញ្ជើញ វន វ៉េត ឲ្យចូលរួមនេះ គឺជាវិធីសាស្ត្រដែលបក្សចង់ដាក់ទណ្ឌកម្ម លើ វន វ៉េត ឬទេ? ឌុច ឆ្លើយថា ខ្លួនមិនហ៊ានសន្និដ្ឋានចំពោះបញ្ហា នេះទេ ប៉ុន្តែខ្លួនភ្ញាក់ផ្អើលនៅពេលដែលឃើញបក្សមិនអញ្ជើញ បង វន (វន វ៉េត) ដែលជាសមាជិកគណៈអចិន្ត្រៃយ៍មជ្ឈិម ហើយ បែរជាអញ្ជើញបង ហែម (ខៀវ សំផន) ដែលមិនមែនជាសមាជិក អចិន្ត្រៃយ៍មជ្ឈិមឲ្យចូលរួមក្នុងកិច្ចប្រជុំទៅវិញ ។ ឆ្លើយតបនឹង សំណួររបស់មេធាវីទាក់ទងនឹងការជួប វន វ៉េត ចុងក្រោយនៅ ពេលណា ឌុច បានអះអាងថា ខ្លួនបានជួបជាមួយ វន វ៉េត ចុង ក្រោយបង្អស់នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ គឺនៅ មុនពេល វន វ៉េត ត្រូវបានចាប់ខ្លួន ។ ឌុច ឆ្លើយថា វន វ៉េត បានមកដល់ស-២១ ស្របពេលដែល ប៉ង់ ត្រូវបានចាប់ខ្លួន ។ នៅមុនពេលនៃការចាប់ ខ្លួន ប៉ង់ មកស-២១ នួន ជា ធ្លាប់បានបញ្ជាឲ្យ វន វ៉េត ទៅជួប ឌុច ដោយមានលិខិតខ្ទេសនាមមួយផ្ញើឲ្យ ឌុច ដែលអត្ថន័យនៅក្នុង សំបុត្រនោះ គឺបញ្ជាឲ្យ ឌុច ធ្វើការ ជាមួយ វន វ៉េត ។ ឌុច បន្ថែមថា បើមិនមានសំបុត្រនោះទេខ្លួនមិនមានសិទ្ធិធ្វើការជាមួយ វន វ៉េត ឡើយ ។

លោកមេធាវី វែកគែន បានរំឭកអំពីសម្តីរបស់ ឌុច ដែល ធ្វើសក្ខីកម្មនៅក្នុងសវនាការថា ខៀវ សំផន បានគ្រប់គ្រងរោងចក្រ អគ្គីសនីមួយនៅចាក់អង្រែក្រោម តើ ឌុច បានដឹងពីព័ត៌មាននេះ ដោយរបៀបណា? ឌុច ឆ្លើយថា ប្រធានរោងចក្រអគ្គីសនីត្រូវ បានចាប់ខ្លួន និងបញ្ជូនមកស-២១ ហើយបានសារភាពថា ខៀវ សំផន បានបង្រៀនខ្លួនដើម្បីឲ្យក្លាយខ្លួនជាភ្នាក់ងារសេអ៊ីអា ។ ឌុច បញ្ជាក់ថា ព័ត៌មាននោះគឺចេញមកពីស-២១ ។ លោកមេធាវី លើកឡើងពីសម្តីរបស់ ឌុច ដែលបាននិយាយនៅក្នុងសវនាការ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ថា នៅពេលដែលទាហានវៀតណាម ចូលឈ្លានពានមកដល់ភ្នំពេញនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ខ្លួន បានចូលរួមកិច្ចប្រជុំមួយជាមួយ ខៀវ សំផន ។ ឆ្លើយតបនឹងការ លើកឡើងនេះ ឌុច បញ្ជាក់ថា ខៀវ សំផន បានដឹកនាំការប្រជុំអំពី សភាពការណ៍ដែលកងទ័ពយួនចូលមកដល់កម្ពុជា ។ ខៀវ សំផន បានប្រាប់ទៅអ្នកចូលរួមថាកុំមានការភ្ញាក់ផ្អើល និងធ្វើការដូច ធម្មតាទៅ ព្រោះមានមិត្ត រឿន និងមិត្ត សាន ទប់ទល់បានហើយ ។ បន្ទាប់មកលោក មេធាវីបានសួរ ឌុច ថា តើការណ៍ដែល ឌុច និយាយថា ខៀវ សំផន ជាអ្នកគ្រប់គ្រងឃ្លាំងរដ្ឋគ្រាន់តែជាការ សន្មតរបស់ ឌុច មែនដែរឬទេ? ឌុច ឆ្លើយថា វាគ្រាន់តែជាការ សន្និដ្ឋានរបស់ខ្លួនប៉ុណ្ណោះ ។ លោកមេធាវីបាន បន្តសួរ ឌុច អំពីកិច្ច ប្រជុំនៅពេលនោះ ឌុច បញ្ជាក់ថា ប្រធានអង្គប្រជុំគឺ ជាមេរបស់អ្នកដែលចូលរួមអង្គប្រជុំនោះ ។ លោក មេធាវីបន្តសួរ ឌុច ទៀតថា ខៀវ សំផន មិនមែនជា ប្រធានផ្ទាល់របស់ ឌុច ទេ ហេតុអ្វី ឌុច មានវត្តមាន នៅក្នុងកិច្ចប្រជុំនាពេលនោះ? ឌុច ពន្យល់ថា ខ្លួន មានការស្ទាក់ស្ទើរក្នុងការចូលរួមកិច្ចប្រជុំនោះ ព្រោះ ខៀវ សំផន មិនមែនជាអ្នកដឹកនាំផ្ទាល់របស់ ខ្លួន ប៉ុន្តែសមមិត្ត លិន បានហៅខ្លួនឲ្យចូលទៅក្នុង កន្លែងប្រជុំនោះ ដោយជឿថា មិត្តលិន នឹងមិនធ្វើ ផ្តេសផ្តាសទេ បើមិនមានបញ្ជាពី ប៉ុល ពត ។ ឌុច បន្តថា អ្វីដែលធ្វើឲ្យខ្លួនយល់ថា ខៀវ សំផន គឺជា



ប្រធានឃុំវង្ស គឺផ្អែកលើអ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំនោះ ហើយ ឌុច បានរំឭកទៀតថា នៅក្នុងពេលប្រជុំនោះ ខៀវ សំផន មិនបាននិយាយអ្វីជាមួយខ្លួននោះទេ សូម្បីតែញញឹមក៏ ខៀវ សំផន មិនបានញញឹមដាក់ខ្លួនដែរ ។ លោកមេធាវីបានសង្ខេបនូវសម្តីរបស់ ឌុច ឡើងវិញអំពីមូលដ្ឋានដែលនាំឲ្យ ឌុច សន្និដ្ឋានថា ខៀវ សំផន ជាប្រធានឃុំវង្ស ដោយកត់សម្គាល់ឃើញមានបីចំណុច ទី១ គឺដោយសារ ឌុច ត្រូវបានបង្ខំឲ្យចូលរួមកិច្ចប្រជុំនោះ ទី២ គឺកិច្ចប្រជុំនោះមាន ខៀវ សំផន ជាប្រធានកិច្ចប្រជុំ និងទី៣គឺដោយសារយ៉ាងហោចណាស់មានចម្លើយសារភាពមួយចេញពី ស-២១បានភ្ជាប់ ខៀវ សំផន ទៅនឹងអ្នកទទួលខុសត្រូវម្នាក់នៅរោងចក្រអគ្គិសនីនោះ ។ ឌុច បានទទួលស្គាល់ថា ការសង្ខេបរបស់លោកមេធាវីគឺត្រឹមត្រូវ ។

បន្ទាប់មកលោកមេធាវី វ៉េកកែន បានស្នើឲ្យ ឌុច ពន្យល់ពីភាពខុសគ្នារវាងសេចក្តីថ្លែងការណ៍មួយដែលធ្វើឡើងដោយ ឌុច ក្នុងឆ្នាំ២០០២នៅចំពោះមុខតុលាការយោធា ដែលពេលនោះ ឌុច បានអះអាងថា ខ្លួនមិនដែលបានជួបនឹង ខៀវ សំផន និងការផ្តល់សក្ខីកម្មរបស់ ឌុច នៅក្នុងសវនាការដែលស្ថិតក្រោម ការធ្វើសម្បថ ។ នៅត្រង់ចំណុចនេះ ឌុច បានពន្យល់ថា នៅពេលដែលខ្លួនផ្តល់ចម្លើយទៅតុលាការយោធាថា មិនដែលបានជួបនឹង ខៀវ សំផន គឺចង់មានន័យថា ខ្លួនមិនមែនជាកូនចៅរបស់ ខៀវ សំផន នៅពេលនោះទេ ។

ទាក់ទងនឹងលិខិតដើរផ្លូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានអះអាងថា អ្នកដែលចុះហត្ថលេខានៅលើលិខិតដើរផ្លូវរបស់ខ្លួន គឺ ស៊ុន សេន ដែលឈ្មោះនៅលើលិខិតដើរផ្លូវនោះ ស៊ុន សេន បានប្រើឈ្មោះថា ឃឹម ។ ឌុច បន្តថា ខ្លួនធ្លាប់បានឃើញលិខិតដើរផ្លូវរបស់ ប៉ង់ ដែលចុះហត្ថលេខា ដោយ ខៀវ សំផន ដោយប្រើឈ្មោះថា ខាង នៅលើលិខិតដើរផ្លូវនោះ ។ លោកមេធាវីបានសួរថា ហេតុអ្វីបានជាមិនឃើញមានឈ្មោះ ប៉ុល ពត និងនួន ជា ចុះហត្ថលេខានៅលើលិខិតដើរផ្លូវ ។ ឌុច បានឆ្លើយថា ប៉ុល ពត និង នួន ជា មានតំណែងធំណាស់ ត្រឹមលិខិតដើរផ្លូវមិនចាំបាច់ចុះហត្ថលេខា ដោយអ្នកទាំងពីរនោះទេ ត្រឹម ខៀវ សំផន គឺគ្រប់គ្រាន់ហើយ ។

បន្ទាប់មកលោកមេធាវីបានសួរថា តើនរណាជាអ្នកទទួលខុសត្រូវនៅក្នុងក្រសួងការបរទេសក្នុងការបញ្ជូនអ្នកទោសទៅ ស-២១? ឌុច បានឆ្លើយដោយសម្តីខ្លាំងៗថា បដិសេធមិនឆ្លើយនឹងសំណួរនេះទេ ប៉ុន្តែ ឌុច បានបញ្ជាក់ដោយខ្ចីថា ជាទូទៅអ្នកដែលបញ្ជូនអ្នកទោសទៅស-២១ គឺសមមិត្ត លីន ។ បន្ទាប់មកលោកមេធាវីបានព្យាយាមសួរបញ្ជាក់ ឌុច ថា តើ ឌុច ដឹងថាឈ្មោះ រឿង ដែលខ្លួនជឿថាជាកូនចៅរបស់ ខៀវ សំផន ធ្វើការនៅឃុំវង្ស ដោយរបៀបណា? ហើយហេតុអ្វីបានជា ឌុច ដឹងពីបញ្ហានេះ? ឌុច ឆ្លើយថាខ្លួនធ្លាប់បានជួបឈ្មោះ រឿង នៅអំឡុងពេលនៃការប្រារព្ធពិធីខួបថ្ងៃទី១៧ មេសា និងដឹងថា រឿង ធ្វើការនៅភូមិភាគខាងត្បូង ។ ក្រោយពីបញ្ចប់សំណួរនេះ លោកមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បានបញ្ចប់ការសួរដេញដោលរបស់ខ្លួនលើ ឌុច ។ ដោយនៅសល់ពេល អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី នួន ជា បន្តសាកសួរសាក្សី ឌុច សំណួរមួយចំនួនដែលក្រុមមេធាវីការពារក្តីមានបំណងចង់សួរបញ្ជាក់បន្ថែមឲ្យបានច្បាស់ ។

ដើមដំបូងមេធាវីជាតិការពារក្តី នួន ជា គឺលោក អរុណ បានចោទសួរ ឌុច ចំនួនពីរសំណួរដោយសំណួរទីមួយ លោកបានលើកឡើងពីសម្តីដែល ឌុច បានឆ្លើយតបនឹងសំណួររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ថា មានលិខិតមួយពី នួន ជា បញ្ជាឲ្យ ឌុច ធ្វើការជាមួយនឹង វ៉ន វ៉េត និង សួរ ឌុច ថា តើលិខិតនោះមាននៅសល់ដល់ពេលបច្ចុប្បន្នដែរឬទេ ។ ទីពីរ តើ ឌុច ជឿថាបញ្ជានោះជា របស់ ប៉ុល ពត ឬជាអន្តរាគមន៍របស់ នួន ជា ។ ឌុច បានឆ្លើយតបនឹងសំណួរទាំងនេះថា នៅពេលដែល នួន ជា ផ្ញើលិខិតនោះមកឲ្យខ្លួន គឺបានបញ្ជាឲ្យខ្លួនធ្វើការជាមួយ វ៉ន វ៉េត និងថានៅលើលិខិតនោះ ចុះហត្ថលេខាដោយឈ្មោះ បួន ដោយ ឌុច អះអាងថា ឈ្មោះ បួន នេះ គឺជាឈ្មោះសម្ងាត់របស់ នួន ជា សម្រាប់ទាក់ទងជាមួយខ្លួន ។ រីឯសំបុត្រនោះខ្លួនមិនបានរក្សាទុកនោះទេ គឺកម្ទេចចោលបាត់អស់ទៅហើយ ។ ឆ្លើយតបចំពោះសំណួរទីពីរ ឌុច អះអាងថាជាគោលការណ៍ ប៉ុល ពត គឺជាអ្នក សម្រេច ហើយ នួន ជា គឺជាអ្នកតាមដានការអនុវត្ត ។ ឌុច ជឿថា ប៉ុល ពត គឺជាអ្នកសម្រេចចំពោះបញ្ហានេះគ្រាន់តែ ប៉ុល ពត មិនចេញមុខ ហើយទុកឲ្យ នួន ជា

ជាអ្នកសរសេរលិខិតនេះ ។

បន្ទាប់មកលោកមេធាវី អរុណ បានសួរបន្តថា ឌុច មាននាទីត្រឹមតែជាប្រធានគុកម្នាក់ដែលមានឋានៈស្មើនឹងលេខាស្រុកប៉ុណ្ណោះ ហេតុអ្វីក៏ ឌុច ដឹងពីរឿងរបស់គណៈអចិន្ត្រៃយ៍ច្រើនម៉្លេះ ។ ឌុច បានបញ្ជាក់ថា ខ្លួនធ្លាប់បានរស់នៅជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាតាំងពីឆ្នាំ១៩៧១ និងបានរៀនពីលក្ខន្តិកៈរបស់បក្សអស់រយៈពេលជាច្រើនឆ្នាំ ។ ដូច្នេះខ្លួនដឹងរឿងរបស់បក្សច្រើន ។ ឌុច បន្ថែមទៀតថា ខ្លួនបានទទួលចំណេះដឹងច្រើនពីការអានសៀវភៅបដិវត្តន៍របស់ប្រទេសចិន ។

លោកមេធាវីបានសួររកភស្តុតាងពី ឌុច ចំពោះការណ៍ដែល ឌុច អះអាងថា ប្រសិនបើ ប៉ុល ពត អវត្តមាន នួន ជា គឺជាអ្នកជំនួសដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងប្រសិនបើ ប៉ុល ពត ជាអ្នកសម្រេច នួន ជា ជាអ្នកតាមដានការអនុវត្ត ។ ជាការឆ្លើយតប ឌុច បានអះអាងថាគឺខ្លួនយោងទៅលើឯកសារមួយដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៧៥ ។

ឆ្លើយតបនឹងសំណួររបស់លោកមេធាវី អរុណ ទាក់ទងនឹងថាតើមានឯកសារផ្លូវការណាមួយដែលបញ្ជាក់ថា នួន ជា ជាអ្នកទទួលខុសត្រូវជំនួសកន្លែង សុន សេន ក្នុងឋានៈជាប្រធានរបស់ ឌុច ។ ឌុច បានឆ្លើយថា ខ្លួនមិនបាននិយាយប្រទិតទាក់ទងនឹងបញ្ហានេះទេ ប៉ុន្តែ ឌុច បានសារភាពថាខ្លួនមិនមាន ឯកសារផ្លូវការណាមួយដើម្បីបញ្ជាក់ឡើយ ។ លោកមេធាវីបានបន្តសំណួររបស់ខ្លួនទាក់ទងនឹងទង់បដិវត្តដោយចោទសួរថា តើ ឌុច សម្អាងលើអ្វីដែលថាទស្សនាវដ្តីទង់បដិវត្តមានជាឯកសារថតចម្លង និងថាតើ ឌុច មានដឹងថាតើទង់បដិវត្តនេះបច្ចុប្បន្ននៅរក្សាទុកទីណាដែលឬទេ? ឌុច បានឆ្លើយតបនឹងសំណួរនេះថា ខ្លួនធ្លាប់បានអានទង់បដិវត្តចាប់តាំងពីចុងឆ្នាំ១៩៧១ ដល់ដើមឆ្នាំ១៩៧២ និងតរៀងមក ដូច្នេះទង់បដិវត្តប្រែប្រួលដូចម្តេចក៏ខ្លួនបានដឹងដែរ ។ ឌុច អះអាងថា ខ្លួនមិនបានឃើញគេថតចម្លងឯកសារទង់បដិវត្តផ្ទាល់ភ្នែកទេ ប៉ុន្តែខ្លួនជឿថាឯកសារដែលតុលាការប្រើគឺថតចម្លងពីច្បាប់ដើម ។ ឌុច បន្តថាច្បាប់មួយចំនួនគឺចេញពីស-២១ តែបច្ចុប្បន្ននេះច្បាប់ដើមគឺនៅរក្សាទុកជាមួយនឹងលោក ឆាំង យុ ។

មុននឹងបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានសួរក្រុមមេធាវីការពារក្តីថា តើកូនក្តីរបស់ខ្លួនមានបំណងចង់សាកសួរទៅកាន់សាក្សីដែរឬទេ? មេធាវីការពារក្តីអន្តរជាតិឲ្យជនជាប់ចោទ នួន ជា បានក្រោកឡើងបញ្ជាក់ជូនអង្គជំនុំជម្រះថា កូនក្តីរបស់ខ្លួនមានបំណងអានសេចក្តីថ្លែងការណ៍ឆ្លើយតបចំពោះការលើកឡើងរបស់ ឌុច នៅក្នុងសវនាការ ។ សម្រាប់ក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន បានអះអាងថា កូនក្តីរបស់ខ្លួនមិនមានសំណួរអ្វីសួរទៅកាន់សាក្សី ឌុច ទេ ។


និល ណុន

បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រកាសផ្អាកដំណើរការនីតិវិធីសវនាការដោយគ្រោងនឹងបន្តកិច្ចដំណើរការសវនាការនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ក្រោយពេលថ្ងៃប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ និងប្រកាសថាការអានសេចក្តីថ្លែងការណ៍របស់ នួន ជា នឹងធ្វើនៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ។

## ៥) នួន ជា ធ្វើសេចក្តីថ្លែងការណ៍ឆ្លើយតបចំពោះការផ្តល់សក្ខីកម្មរបស់ ឌុច

នៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ដូចជាអ្វីដែលបានគ្រោងទុក អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសឲ្យជនជាប់ចោទ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍តបចំពោះការផ្តល់សក្ខីកម្មរបស់ ឌុច ដែលបានធ្វើនៅក្នុងសវនាការជិតពីរសប្តាហ៍កន្លងទៅ ។ ខាងក្រោមគឺជាសេចក្តីថ្លែងការណ៍ទាំងស្រុង របស់ នួន ជា ដែលបានអាននៅក្នុងសវនាការដោយចំណាយពេលប្រហែល៥នាទី ។

“សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង

បងប្អូនរួមជាតិជាទីគោរព ។ ខ្ញុំមានមតិខ្លីទេ តែជាមតិពិត និងយុត្តិធម៌ ។ ខ្ញុំសូមប្រកាសជូនបងប្អូនប្រជាជនខ្មែរទាំងអស់ថា ខ្ញុំមិនដែលមានពេលណាមួយនោះទទួលខុសត្រូវលើមន្ទីរសន្តិសុខ ស-២១ នោះទេ ។ អ្វីដែល ឌុច និយាយចោទប្រកាន់មកលើរូបខ្ញុំ


នួន ជា ធ្វើសេចក្ដីថ្លែងការណ៍

គឺជាការភូត បំភ្លើសការពិត និងអយុត្តិធម៌មកលើរូបខ្ញុំប៉ុណ្ណោះ ។ ខ្ញុំមិនដែលបញ្ជាទទួលឯកសារស្អីទេ ពីឌុច ហើយក៏មិនដែលធ្វើជាមេរបស់ ឌុច នោះដែរ ។ ឌុច ជាមនុស្សពូកែខាងវោហាដ៏មានបទពិសោធន៍ណាស់ ។ តាមរយៈសវនាការកន្លងមក ឌុច មានការភាន់ច្រឡំ វិលវល់ មិនអាចកំណត់ចំណារឲ្យបានច្បាស់លាស់នោះ គាត់កែច្នៃចំណាររបស់ ប៉ុល ពត ថាជារបស់ខ្ញុំ ។ ខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះច្រានចោលនូវការចោទប្រកាន់ទាំងប៉ុន្មានរបស់ ឌុច មកលើរូបខ្ញុំ ។ បើ ឌុច មានចំណាររបស់ខ្ញុំមែន សូមឲ្យ ឌុច យកមកបង្ហាញខ្ញុំចំពោះមុខតុលាការ ។ ខ្ញុំក៏សូមជម្រាបបញ្ជាក់ជូនអង្គជំនុំជម្រះថាខ្ញុំគ្មានបំណងឆ្លើយនឹងសំណួរពីភាគីផ្សេងៗនៅពេលនេះទេ ។ សូមអរគុណ.....លោកប្រធាន ។»

## បញ្ហាផ្សេងៗ :

១) សវនាការថ្ងៃទី១៩-២១ ខែមីនា ឆ្នាំ២០១២នេះ ធ្វើឡើងខុសពីការគ្រោងទុករបស់អង្គជំនុំជម្រះ ដោយសារតែជនជាប់ចោទ នួន ជា បង្ហាញជំហរមិនឆ្លើយតបសំណួរអំពីអង្គហេតុដែលនឹងត្រូវយកមកជំនុំជម្រះក្នុងដំណាក់កាលទី២ ។ តាមគម្រោងអង្គជំនុំជម្រះមានបំណងស្ដាប់ចម្លើយរបស់ នួន ជា នៅថ្ងៃទី១៩ និង២១ ហើយស្ដាប់សក្ខីកម្មរបស់ ឌុច នៅថ្ងៃទី២០ និង២២ ខែមីនា ។ ដោយជនជាប់ចោទ នួន ជា បង្ហាញជំហរមិនឆ្លើយតបនឹងសំណួរ ដូចនេះអង្គជំនុំជម្រះបានសម្រេចប្ដូរការស្ដាប់សក្ខីកម្មរបស់ ឌុច ភ្លាមៗមកពេលរសៀលថ្ងៃទី១៩ ដល់ទី២១ ខែមីនាវិញ ។

២) សវនាការថ្ងៃទីមួយ ឌុច បានមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងសម្លៀកបំពាក់ជាទណ្ឌិត(អាវខៀវ និងខោខៀវ ដោយមានឆ្នូតពណ៌ស) ។ នៅពេលបញ្ចប់សវនាការថ្ងៃទីមួយនេះ ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានបង្គាប់បញ្ជាទៅប្រធានមន្ទីរឃុំឃាំងឲ្យប្ដូរសម្លៀកបំពាក់ ឌុច នៅពេលផ្ដល់សក្ខីកម្មនៅថ្ងៃបន្ទាប់ដោយអនុញ្ញាតឲ្យ ឌុច មានសិទ្ធិស្លៀកពាក់ដូចសាក្សីទូទៅដែរ ។ លោកប្រធានអង្គជម្រះបានផ្ដល់សំអាងហេតុថា ឌុច គួរទទួលបានការស្លៀកពាក់សមរម្យ ក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។

៣) នៅសវនាការថ្ងៃទី២គឺថ្ងៃទី២០ ខែមីនា បន្ទាប់ពីប្រធានអង្គជំនុំជម្រះប្រកាសសម្រាកវគ្គទី៣ ជនជាប់ចោទ នួន ជា ស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្លួនចូលរួមសវនាការពីចំងាយតាមរយៈប្រព័ន្ធសោទស្សន៍នៅបន្ទប់រង់ចាំ ព្រោះដោយសារខ្លួនមានបញ្ហាសុខភាពមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។ អង្គជំនុំជម្រះបានសម្រេចយល់ព្រមតាមសំណើ ហើយបង្គាប់ឲ្យមេធាវីការពារក្ដីប្រគល់ឯកសារលះបង់សិទ្ធិចូលរួមដោយផ្ទាល់ ដោយមានការចុះហត្ថលេខារបស់ជនជាប់ចោទអំពីការលះបង់សិទ្ធិនេះ ។ ផ្ទុយមកវិញ លោកមេធាវីអន្តរជាតិ ម៉ៃឃើល ផេស្ដមេន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា កូនក្ដីរបស់ខ្លួនមិនមានបំណងចូលរួមសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍នោះទេ គឺមានបំណងចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែដោយសារបញ្ហាសុខភាពមិនអាចតាមដាននីតិវិធីរបស់តុលាការបានទើបកូនក្ដីរបស់ខ្លួនស្នើសុំសម្រាក ។ ដូចនេះដើម្បីធានាដល់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់កូនក្ដីរបស់ខ្លួន អង្គជំនុំជម្រះគប្បីផ្អាកកិច្ចដំណើរការនីតិវិធីស្ដាប់សក្ខីកម្មរបស់ ឌុច សិន ។ បន្ទាប់ពីបានស្ដាប់ការលើកឡើងបែបនេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យគ្រូពេទ្យធ្វើការពិនិត្យសុខភាពរបស់ នួន ជា ដើម្បីយកធ្វើជាមូលដ្ឋានក្នុងការសម្រេច ។ ក្នុងកំឡុងពេលនៃការពិនិត្យសុខភាពនេះ លោក ផេស្ដមេន បានចាកចេញពីបន្ទប់សវនា

ការដោយមិនបានបញ្ជាក់ពីមូលហេតុ និងគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះ ។ ដោយមើលឃើញទង្វើបែបនេះ អង្គជំនុំជម្រះបានបញ្ជាក់ប្រាប់លោក ផេស្តមេន ថា “លោកមេធាវី ផេស្តមេន បើសិនលោកទៅពាក់ព័ន្ធជាមួយកិច្ចដំណើរការបំពេញភារកិច្ចរបស់វេជ្ជបណ្ឌិតក្នុងការពិនិត្យសុខភាពរបស់ជនជាប់ចោទដោយឯករាជ្យ ប្រសិនបើមានព័ត៌មាន ឬការរាយការណ៍ណាមួយថា លោកបានទៅជ្រៀតជ្រែកក្នុងការបំពេញវិជ្ជាជីវៈនោះ លោកនឹងមានបញ្ហា” ។ យោងតាមការសម្រេចនេះ លោក ផេស្តមេន លើកឡើងថា ខ្លួនពិតជាបានចូលទៅបន្ទប់គ្រូពេទ្យនៅពេលពិនិត្យសុខភាពរបស់ នួន ជា មែន ប៉ុន្តែវាគឺជាសិទ្ធិរបស់មេធាវីការពារក្តីក្នុងការអនុវត្តកាតព្វកិច្ចការពារកូនក្តីរបស់ខ្លួន ហើយខ្លួនមិនបានធ្វើសកម្មភាពណាមួយជ្រៀតជ្រែកដល់កិច្ចការរបស់គ្រូពេទ្យឡើយ ។ ឆ្លើយតបនឹងការលើកឡើងរបស់លោក ផេស្តមេន លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានបញ្ជាក់ថា សិទ្ធិនិងកាតព្វកិច្ចរបស់មេធាវីការពារក្តីគឺមានដែនកំណត់ ពោលមេធាវីមិនអាចចូលទៅជ្រៀតជ្រែកកិច្ចការរបស់គ្រូពេទ្យបានឡើយ ។

៤) បញ្ហាមួយទៀតដែលមេធាវីរបស់ជនជាប់ចោទ ខៀវ សំផន បានលើកឡើងជាញឹកញាប់នោះ គឺការបកប្រែភាសា ។ លោកស្រីមេធាវី អង់តា ហ៊្គីសេ បានលើកឡើងថា នៅពេល ឌុច ផ្តល់សក្ខីកម្ម ការបកប្រែពីភាសាខ្មែរទៅជាភាសាបារាំងគឺមានការបាត់ខ្លឹមសារជាច្រើន ដែលបញ្ហានេះធ្វើឲ្យលោកស្រីមានការពិបាកតាមដានកិច្ចដំណើរការនីតិវិធី ដោយសារតែ ឌុច និយាយលឿនពេក ។

៥) នៅពេលចាប់ផ្តើមសវនាការ មេធាវីរបស់ នួន ជា ស្នើសុំឲ្យកូនក្តីរបស់ខ្លួនធ្វើសេចក្តីថ្លែងការណ៍ដែលនឹងត្រូវចំណាយពេលប្រមាណ៥នាទី ។ ភ្លាមៗនោះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក បានឌីគី បញ្ជាក់ថា ខ្លួនមិនជំទាស់ចំពោះការធ្វើសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទឡើយ តែជនជាប់ចោទ នួន ជា អះអាងថា ខ្លួនប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួររបស់ភាគី ។ ដូច្នេះជនជាប់ចោទមិនអាចប្រកាន់ជំហរ ម្តងនៅស្ងៀម ម្តងស្នើសុំធ្វើសេចក្តីថ្លែងការណ៍ឡើយ ។ ការអនុញ្ញាតឲ្យជនជាប់ចោទធ្វើបែបនេះ គឺមិនមានយុត្តិធម៌សម្រាប់ភាគីផ្សេងៗនៅក្នុងរឿងក្តីឡើយ ព្រោះវិធានផ្ទៃក្នុងតម្រូវឲ្យភាគីមានសិទ្ធិស្មើគ្នាក្នុងអំឡុងដំណើរការនីតិវិធី ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រធានអង្គជំនុំជម្រះនៅតែអនុញ្ញាតឲ្យ នួន ជា មានសិទ្ធិធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន តែធ្វើបាននៅពេលដែលភាគីទាំងអស់សួរ ឌុច ចប់សព្វគ្រប់ជាមុនសិន ។

៦) មុនពេលអង្គជំនុំជម្រះប្រកាសសម្រាក បន្ទាប់ពីក្រុមមេធាវីរបស់ នួន ជា សួរ ឌុច បញ្ចប់ លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មិត ស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ថា នៅពេលដែល ឌុច មកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ តើរាល់ឯកសារដែលមានការពាក់ព័ន្ធនឹង ឌុច ទាំងអស់ត្រូវយកមកដាក់ចំពោះមុខអង្គជំនុំជម្រះឬទេ? ប្រសិនបើតម្រូវដូច្នេះ ខ្លួននឹងដាក់ឯកសារទាំងអស់ដែលជាប់ព័ន្ធនឹង ឌុច ។ បន្ថែមលើនេះ លោកមេធាវី ផេស្តមេន ស្នើសុំអង្គជំនុំជម្រះបញ្ជាក់ថាតើកំណត់ហេតុស្តាប់ចម្លើយរបស់ ឌុច ទាំងអស់ត្រូវយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ? មេធាវីរបស់ជនជាប់ចោទ ក៏ស្នើសុំអង្គជំនុំជម្រះបញ្ជាក់បញ្ហាដូចគ្នា ដោយមេធាវីការពារក្តីទាំងបីក្រុមបានលើកឡើងនូវកង្វល់របស់ខ្លួនថា សំណុំរឿង០០២ត្រូវបានបែងចែកជាផ្នែកៗ ហើយមេធាវីការពារក្តីមិនត្រូវបាន អនុញ្ញាតឲ្យសួរសាក្សីក្រៅពីអង្គហេតុដែលត្រូវយកមកជំនុំជម្រះក្នុងដំណាក់កាលទី២ឡើយ ។ លោក មេធាវី គង់ សំអុន បន្ថែមថា ចម្លើយរបស់ ឌុច មានច្រើនដែលបានធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេត ដែលមានចម្លើយមួយចំនួនមិនស្របនឹងអង្គហេតុដែលត្រូវយកមកជំនុំជម្រះក្នុងសំណាក់កាលទីពីរនេះ ។ ភ្លាមនោះ លោកស្រីមេធាវី ស៊ីម៉ូណូ ហ៊្វុត អះអាងថា កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុច ត្រូវបានចាត់ទុកថាដាក់ចំពោះមុខភាគីតាំងពីដំណាក់ចៅក្រមស៊ើបអង្កេតមកម្ល៉េះ ។ ឆ្លើយតបនឹងសំណើរបស់ភាគីអង្គជំនុំជម្រះសម្រេចថា កំណត់ហេតុស្តាប់ចម្លើយសាក្សី ឌុច ក្នុងអំឡុងពេលដំណើរការសំណុំរឿង០០១ និង០០២ ត្រូវបានចាត់ទុកថាបានដាក់ចំពោះមុខអង្គជំនុំជម្រះទាំងស្រុង ហើយភាគីអាចសួរ ឌុច អំពីអង្គហេតុដែលមានក្នុងកំណត់ហេតុទាំងនោះ រីឯប្រតិចារិកដែលមាននៅក្នុងសំណុំរឿង០០១ គឺយកតែផ្នែកណាដែលមានការពាក់ព័ន្ធតែប៉ុណ្ណោះ ។

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ខ៊ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ស-២១ ៈ មន្ទីរសន្តិបាលស-២១ គឺជាមន្ទីរសន្តិសុខសម្ងាត់របស់នគរបាលដែលមានទីតាំងនៅទីក្រុងភ្នំពេញ ។

អគ្គសេនាធិការ ៈ ទីបញ្ជាការជាន់ខ្ពស់នៃកងទ័ពបដិវត្តកម្ពុជាដែលដឹកនាំដោយ សុន សេន ស្ថិតនៅទីក្រុងភ្នំពេញ ។

ក-១ ៈ លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ ប៉ុល ពត ។

ក-២ ៈ លេខកូដសម្គាល់សម្រាប់ក្រសួងសង្គមកិច្ច ។

ក-៣ ៈ លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ នួន ជា និង ខៀវ សំផន ។


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៈ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៈ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៈ dccam@online.com.kh

គេហទំព័រ ៈ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

**ឈុនលី** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លីម ជ័យទ័ត្ត**

**ជ័យទ័ត្ត** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ចាន់ ប្រាថ្នា**

**ប្រាថ្នា** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។




ភាន់ ពីនី ទស្សនកិច្ចប្រទេសអាល់បាលនី

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែឧសភា ឆ្នាំ២០១២